# សិល្បៈខ្មុកកាស្មាច់ខ្មែរ



រៀបរៀងដោយ នាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម

ឆ្នាំ ២០១៨

នាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌
នាយកដ្ឋានសិល្បៈសូនរូប និង សិល្បៈសិប្បកម្ម

សៀវភៅ

# សិល្បៈឆ្លាក់ស្នាចខ្មែរ

រក្សាសិទ្ធិ ឆ្នាំ ២០១៨

# មាតិកា

អារម្ភកថា........................................................................................................៣
សេចក្ដីផ្ដើម........................................................................................................៥
ឧទ្ទិស...............................................................................................................៦
ទ្រឹស្ដីសិល្បៈ
I និយមន័យ....................................................................................................៧
II ប្រភព..........................................................................................................៧
III កម្មវត្ថុសិល្ប..................................................................................................៨
ផលប្រយោជន៍សិល្បៈ..........................................................................................៨
លក្ខណពិសេសរបស់សិល្បករ...............................................................................១០
គ្រឹះមូលដ្ឋាន......................................................................................................១១
ទស្សនចំពោះសិល្បៈ...........................................................................................១៣
ស្ដាបត្យកម្ម.......................................................................................................១៤
ទ្រឹស្ដីពណ៌........................................................................................................១៥
ជីវប្រវត្តិតួអង្គ....................................................................................................២៨
ស្នាប់.................................................................................................................៣៦
សំលៀកបំពាក់....................................................................................................៤៥
ក្បាច់.................................................................................................................៤៦
ពណ៌សំលៀកបំពាក់.............................................................................................៤៦
ការវិវឌ្ឍនខ្នុក.....................................................................................................៤៧
ខ្នុកសម័យ..........................................................................................................៤៩
ប្រភេទ...............................................................................................................៥០
បច្ចេកទេសលើថ្ងូ................................................................................................៥១
របៀបខាត់..........................................................................................................៥១
គូរ.....................................................................................................................៥១

ប្រៀបធៀបខ្មុកបូរាណ សម័យ..........................................................................................៥៣
អវសានបទ......................................................................................................................៥៥

# អារម្ភកថា

សៀវភៅសិល្បៈខ្នុកស្នាច់នេះបានរៀបរៀងចងក្រងឡើងក្នុងគោលបំណងថែរក្សាឲ្យបានគង់វង្សនូវកេរតំណែលសិល្បៈរបស់ដូនតា។ យើងសង្កេតឃើញថាជាច្រើនតំណមកហើយយើងពុំដែលឃើញមានការចងក្រងជាឯកសារកត់ត្រាអំពីប្រវត្តិនិងបច្ចេកទេសនៃការធ្វើមុខខ្នុកនិងវិធីលាបម្រក្សរបស់ខ្មែរយើងឡើយដូចនេះសៀវភៅនេះជាចំណុចចាប់ផ្តើមមួយនិងឈានទៅរកការសិក្សាស្រាវជ្រាវផ្សេងៗទៀតនៃសិល្បៈខ្នុកស្នាច់ខ្មែរ រីឯអ្នកសម្តែងល្ខោនខោលរំពឹងលើអ្នកធ្វើមុខខ្នុក។ ដូចនេះទាមទារឲ្យអ្នកធ្វើមុខខ្នុកស្គាល់តួអង្គយក្ស ស្វា ទេវតា ឲ្យបានច្បាស់ក្នុងរឿងរាមកេរ្តិ៍ ពិសេសពណ៌សំបុរ និងគ្រឿងប្រដាប់រចនារបស់តួអង្គនិមួយៗ។

រាល់ឯកសារសិក្សាស្រាវជ្រាវនៅក្នុងសៀវភៅនេះអាចមានការខ្វះខាតច្រើនដូចនេះក្រុមការងារស្រាវជ្រាវរបស់នាយកដ្ឋានសិល្បៈសូនរូប និងរង់ចាំទទួលស្វាគមន៍រាល់មតិរិះគន់ដើម្បីបំពេញបន្ថែមឲ្យសៀវភៅនេះអាចយកជាផ្លូវការបាន និងទុកជាឯកសារស្រាវជ្រាវដ៏ពិសេសំរាប់មនុស្សជាតិទូទៅ។

មនុស្សជារូបធាតុដ៏តូចមួយក្នុងចំណោមរូបធាតុជាច្រើនទៀតតែដោយការប្រព្រឹត្តទៅនៃអន្តរកម្មគីមីនិងចលនាធម្មជាតិបានរុញច្រានមនុស្សចូលក្នុងប្រព័ន្ធចំនេះដឹង ដោះស្រាយដោយពលកម្មការងារ។

ពលកម្មបានផ្តល់ជោគវាសនា ដល់មនុស្សនូវតម្លៃដ៏ពិសិដ្ឋទាំងស្មារតីទាំងសម្ភារសម្រាប់បំពេញសេចក្តីត្រូវការ។ នេះគឺជាទ្រង់ទ្រាយមួយដែលធ្វើឲ្យគេចេះស្តី ចេះស្តាប់ ចេះរៀបចំ ចេះបង្កើត មិនតែប៉ុណ្ណោះថែមទាំងធ្វើឲ្យមានទស្សនប្លែកទៀត ដែលមនុស្សខ្លួនឯងពុំស្មានដល់។ ទន្ទឹមនឹងនេះគឺភាសាបានធ្វើឲ្យមនសិការមនុស្សផ្ទុះបញ្ចាំងតថភាពបរានុមតិច្នៃរចនាសម្ព័ន្ធគ្រប់មជ្ឈដ្ឋានទាំងឡាយ ច្នៃចេញជារូបរាងឡើង។

ដោយមនសិការប្រកបទៅដោយអធិភាពត្រូវបានគេចាត់ទុក មនុស្សជាកម្មវត្ថុនយោបាយសិល្បៈ ទស្សនវិជ្ជា នឹងជាប្រធាននៃគំនិតបញ្ញាទាំងឡាយ។ រហូតមកដល់ពេលនេះគេក៏បានជំរុញខ្លួនទៅក្នុងប្រព័ន្ធពិភពលោក ក្នុងនោះធ្វើឲ្យគេចេះច្នៃរចនា

*សម្ព័ន្ធ ក្រោមអង្គការ ស្ថាប័ននានាព្រមទាំងផ្តល់នូវតម្លៃល្អៗតាមគំនិតតាមសកម្មភាពតាមភាសារទៅកាន់មនុស្សគ្រប់គ្នា។*

*ដូចនេះ ការលូតលាស់នៃមនសិការ ធ្វើឲ្យមានការរីកចម្រើនគ្រប់បែបយ៉ាងទាំងស្បង់ ទាំងតិចនិច សិល្បៈ ទស្សនជាដើមទន្ទឹមនឹងចរន្តរីកលូតលាស់ក្នុងផ្លូវគំនិត មនុស្សក៏ត្រូវការជាចាំបាច់នូវផ្លូវចិត្តផលដែរ នូវការអប់រំជាពិសេសមនុស្សក៏ត្រូវការសុខសិទ្ធិភាពខំកសាង សោភ័ណ្ឌផ្លូវចិត្ត សោភ័ណ្ឌរូបរាងកាយ សោភ័ណ្ឌគំនិតទុក្ខដាក់បានយ៉ាងត្រឹមត្រូវរហូតមកដល់ពេលនេះ។*

*ឃើញជនជាតិដើម ដែលមានកំនើតចាស់ជាងគេនៅក្រោយឥណ្ឌូចិនច្រើនពាន់ឆ្នាំមុនគ្រឹះសករាជ បានសាងស្នាដៃប្រកបដោយអរិយធម៌ខ្ពង់ខ្ពស់នោះ បានធ្វើឲ្យជនជាតិគ្រប់មជ្ឈដ្ឋានកោតភ្ញាក់ផ្អើលមិនតិច ចំពោះស្នាដៃទាំងនោះ។ តើស្នាដៃទាំងនោះបានទទួលអ្វីខ្លះ តាំងពីចាប់ផ្តើមកកើតរូបរាង?*

*ពិតជាបានទទួលនូវគ្រប់សម័យកាលនីមួយៗក្នុងការប្តូរអរិយធម៌បរទេសទៅវិញទៅមក។ ប៉ុន្តែដោយខ្មែរជាជាតិប៉ិនប្រសប់បានយកមកកិនទំពារលម្អិត បញ្ចេញរូបរាងជាខ្មែរពិតប្រាជកគ្មានជាតិណាមួយមានដូចឡើយ។*

*ក្នុងន័យដ៏ទូលាយយើងឃើញថាខ្មែរទទួលវប្បធម៌បរទេសជាច្រើនដូចជា ចាម ជ្វា ភូមា ក្វូឡា ចិន ជាពិសេសឥណ្ឌាចម្រុះគ្នាមកក្នុងដែនដីខ្លួន។ ដោយសារការទទួលវប្បធម៌ដទៃច្រើនយ៉ាងនេះហើយបានជាមានមតិជនខ្លះពោលថា ខ្មែរគ្មានសិល្បៈ សិល្បៈខ្មែរជាសិល្បៈឥណ្ឌា ហើយក៏ខំភ្ជាប់ខ្លួនទៅនិងវប្បធម៌នៃជនជាតិដទៃទៅវិញ។ ការពិតនាំឲ្យយើងពិបាកជួនវាធ្វើឲ្យយើងបាត់បង់អេតិភ័ណ្ឌជាតិដោយមិនដឹងខ្លួនក៏មាន ជួនវាធ្វើឲ្យស្អប់សិល្បៈជាតិខ្លួនក៏មាន ហើយថែមទាំងពិបាកសិក្សាទៀតផង។*

*ក្នុងន័យចង្អៀតនេះជាការទទួលយកវប្បធម៌បរទេស មិនមែនជាកត្តាត្រូវហាមឃាត់ទេ សំខាន់គឺត្រូវធ្វើយ៉ាងណាឲ្យវប្បធម៌នេះក្លាយជាខ្មែរពិតប្រាកដ ប៉ុន្តែកុំប្រឡំឲ្យសោះពីបញ្ហាយកធាតុបរទេសទាំងស្រុងហើយខំពន្យល់ថាជាខ្មែរនោះ គឺមិនមែនជាការបង្កើតខ្លឹមសារជាតិឡើយ។*

# សេចក្តីផ្តើម

នៅក្នុងលោកយើងនេះជាតិសាសន៍ណាក៏ដោយសុទ្ធសឹងតែមានសិល្បៈវប្បធម៌របស់ខ្លួនជាមូលដ្ឋានរៀងៗខ្លួន។ ប្រទេសណាដែលមានវប្បធម៌លូតលាស់ជឿនលឿនត្រូវបានចាត់ទុកជាអារ្យប្រទេស។ ខ្មែរមានវប្បធម៌របស់ខ្លួនយ៉ាងជាក់លាក់ខ្ពង់ខ្ពស់ហើយល្បីសុះសាយលើសកលលោក។ បុព្វបុរសខ្មែរបានកសាងប្រាង្គប្រាសាទជាច្រើនបន្សល់ទុកសម្រាប់កូនចៅជំនាន់ក្រោយរួមទាំងសិល្បៈអរូបីជាច្រើនទម្រង់ដូចជា សិល្បៈ គំនូរ ចម្លាក់ ខ្មុកស្មាច់ តម្បាញ ដេរប៉ាក់ របាំ ចម្រៀង តូរ្យតន្ត្រី។ល។

សិល្បៈគ្រប់ទម្រង់ទាំងឡាយនេះកំពុងតែរស់រានជីវិតនឹងបន្តសកម្មភាពរហូតមកដល់បច្ចុប្បន្នតាមរយៈការបង្ហាត់បង្រៀនបន្តរបស់អ្នកមានចំណេះជំនាញពីឪពុកទៅកូននិង ពីតំបន់មួយទៅតំបន់មួយ។ ប៉ុន្តែការបន្តនូវចំណេះដឹងទាំងឡាយនេះពុំមានលក្ខណៈវិទ្យាសាស្ត្រគ្រប់គ្រាន់សំរាប់ការអភិរក្សនិង អភិវឌ្ឍន៍វិស័យវប្បធម៌ជាតិឡើយព្រោះ ៖

-ចាស់ព្រឹទ្ធាចារ្យអ្នកចេះដឹងជំនាញសិល្បៈតាមជនបទត្រូវបានទទួលមរណៈភាពទៅតាមអាយុកាល

-ក្មេងៗជំនាន់ក្រោយរៀនតៗគ្នាពុំមានសៀវភៅឯកសារក្បួនខ្នាតច្បាស់លាស់និងពុំបានធ្វើការសិក្សាស្រាវជ្រាវអំពីប្រវត្តិច្បាស់លាស់។

-កត្តាទាំងនេះហើយដែលជុំរុញឲ្យនាយកដ្ឋានសិល្បៈសូនរូបស្វះស្វែងរកគ្រប់មធ្យោបាយសិក្សាស្រាវជ្រាវចងក្រងនូវវិជ្ជាសិល្បៈសូនរូបនឹងសិប្បកម្មគ្រប់ទម្រង់ទុកជាប្រទីបសម្រាប់បំភ្លឺដល់អ្នកសិក្សាស្រាវជ្រាវទាំងបច្ចុប្បន្ននិងទៅអនាគត។

## ឧទ្ទិស

យើងខ្ញុំដែលជាកុលបុត្រ កុលធីតា នឹងជាអ្នកបន្តវេនបដិវត្ត សូមលំអោនកាយគោរព បញ្ញាញ្ញាណដែលប្រកបដោយពុទ្ធិ របស់ពលករកំពូលនាសម័យមហានគរ។ ដែលអស់លោកបុព្វបុរស បានពលិកម្មមិនចេះនឿយហត់ ប្តូរដោយឈាមនឹងទឹកភ្នែក ប្រយោជន៍ចង់ឲ្យទឹកដីនៅតែស្រស់ញញឹម មានអរិយធម៌ភ្លឺស្វាងទើបខិតខំកសាងសមិទ្ធិផលជាសំណង់សិល្បស្គឹមស្គៃទុកដាក់ថែរក្សារហូតមកទល់បច្ចុប្បន្នភាពនេះ។

នឹងមិនភ្លេចទាល់តែសោះនូវគុណូបការវិសេសវិសាល របស់អ្នកម្តាយវៀតណាមដែលសុខចិតផ្តល់កូនប្តីមករំដោះយើងខ្ញុំឲ្យឃើញពន្លឺភ្លឺមកវិញ ក្នុងការកសាងវប្បធម៌ជាតិទៅមុខទៀត។

ជាពិសេស គុណដ៏លើសលុបរបស់លោកអ្នកមានគុណ លោកអ៊ុំសាស្ត្រចារ្យ គ្រូបង្រៀនបច្ចេកទេសទូទៅ គ្រូទទួលបន្ទុក គ្រូឯកទេស ដែលលោកបានចំណាយគំនិតកម្លាំងសព្វបែបយ៉ាងផ្តល់ដល់រូបខ្ញុំ និងមិត្តជាច្រើនជាកូនខ្មែរក្នុងការបន្តវប្បធម៌ជាតិទៅអាណាគត់។

យើងខ្ញុំទាំងអស់ជាសិស្ស កូនចៅស្រករក្រោយសូមគោរពធ្វើតាមវត្តប្រតិបត្តិនេះធ្វើត្រៀមខ្លួនបន្តវេនដ៏ថ្លៃថ្លា របស់បុព្វជន សាស្ត្រាចារ្យ គ្រូ និង មិត្តភក្តិដែលពលីក្នុងសង្គ្រាម ទៅមុខទៀតរហូតអវសាន្តជីវិត ក្នុងដំណាក់ឈាមចុងក្រោយបំផុត។

# *ខ្លឹមសារ*

## *សិល្បក្នុងសង្គម*
## *ទ្រឹស្តីសិល្បៈ*

### I *និយមន័យ*

*សិល្បជាអ្វី? ជាវិធីសាស្ត្រមួយប្រកបដោយទេពកោសលយ៉ាងប៉ិនប្រសប់ និង ទ្រង់ទ្រាយនៃសញ្ញាណសង្គម។ សិល្ប គឺជាទេពកោសលអាចកំបាំងយ៉ាងប៉ិនប្រសប់ផ្សារ ភ្ជាប់ទៅនឹងទំនាក់ទំនងនយោបាយ សេដ្ឋកិច្ច សាសនា ទំនៀមទំលាប់ ប្រពៃណីនៃជាតិមួ យៗ។ ប៉ុន្តែខុសគ្នាទៅតាមភូមិសាស្ត្រ ប្រវត្តិសាស្ត្រ សាសនា សេដ្ឋកិច្ចរបស់ជនជាតិមួយៗ ទៀតផងដែរ។ សិល្បប្រព្រឹត្តឡើងក្នុងតថភាពសង្គម ស្តីអំពីកម្រងជីវិតពិតៗរស់រវើករបស់ មនុស្សទៅតាមសង្គមប្រវត្តិ ហើយចាំបាច់បំផុតគឺទាញមនុស្សមកធ្វើជាកម្មវត្ថុសិក្សាវែក ញែក នឹងជាប្រធានប្រកបដោយសិល្ប៍សោភ័ណ្ឌក្នុងការដោះស្រាយបញ្ហាទៀតផង។*

### II *ប្រភព*

*សិល្បចេញពីមនុស្សតាមរយៈខួក្បាល នឹងផ្នត់គំនិតពុំចេញពីអទិទេពណាមួយ ឡើយដោយសារសកម្មភាពដែលផលិតដោយបញ្ញាពលកម្ម និងហត្ថពលកម្មមនុស្សអាច ផ្សាយចេញជាល្បែងកំសាន្ត ជាការតុបតែង ជាបច្ចេកទេសក្នុងការរស់នៅទាំងអស់នេះ យើងឲ្យឈ្មោះសិល្បដូច្នេះ សិល្បពិតជាប្រសូត្រចេញពីពលកម្មរបស់មនុស្សនេះតែម្តង ព្រោះថាដើម្បីបន្ថយការនឿយហត់ពីការងារ គេបានជម្រុញខ្លួនគេទៅប្រកពពុទ្ធិសិល្ប៍ យ៉ាងសុក្រឹតបំផុតនូវសម្ភារបង្កើបង្កើនឡើង ដោយមនសិការបែកជាផ្ញៃផ្កា ស្តីអំពីបាតុភូតជុំ វិញលោកបរានុម័ត ជាពិសេសក្នុងសកម្មភាពការងារទាំងឡាយនេះបានធ្វើឲ្យគេនូវចិត្ត រំភើបចង់បាន ចង់កំសាន្តរីករាយ និងដើម្បីបំពេញសំណូមពរនេះ គេក៏ចាប់បង្កើតចេញជា សិល្បៈអក្សរសិល្ប៍ល្បែងកំសាន្តនេះឡើង។*

III *កម្មវត្ថុសិល្បៈ*

*គ្រាន់តែមានរូបរាងភ្ញាម សិល្បក៏បានសង្កត់ខ្លួនចូលទៅក្នុងប្រព័ន្ធពុទ្ធិផ្សេងៗក្នុងការជួយផ្សាយនូវមនោគមវិជ្ជា វប្បធម៌ សតិអារម្មណ៍ សញ្ចេតនាផ្សេងៗដល់មនុស្សហេតុនេះហើយ បានជាគេឃើញមនុស្សមានសន្ដានចិត្តបរិសុទ្ធមានចិត្តទូលាយ ចង់បានសុខសន្តិភាពដល់សង្គមដល់គ្រួសារក៏ដោយសារសិល្បវិធីរបស់សិល្បផងដែរ។*

*អាស្រ័យហេតុនេះ ហើយបានជាពេលនេះសិល្បដាច់ខាតត្រូវតែផ្សាយបន្តរទៅទៀតដោយទាញយកវត្ថុសិក្សាដូចជា៖*

- *ជួយបណ្ដុះផ្នត់គំនិតបញ្ចូលមនោគមវិជ្ជាកុំមុយនីស*
- *អប់រំតាមរយៈសិល្បសោភ័ណ្ឌ តាមវិធីសាស្ត្រផ្សេងរបស់អ្នកនិពន្ធ អប់រំឲ្យគេកែប្រែចិត្តគំនិតទុទិដ្ឋិនិយមហើយចាប់យកសុខមកវិញតាមរយៈសិល្ប៍នេះឯង*
- *កែប្រែបោះជំហានទៅរកទិសដៅ ដែលមនុស្សចង់បានប្រាប់ពីគោលគំនិតទៅថ្ងៃមុខតាមរយៈមនោសញ្ចេតនារបស់សិល្បនេះ និងសិល្ប៍ប្រកបសុធន្ទះល្អបំផុតក្នុងគោលគំនិតមនុស្សថ្មី។*

*សំខាន់ជាងនេះសិល្ប ត្រូវតែរួមចំណែកស្វែងរកសច្ចភាពក្នុងតថភាពប្រកបទៅដោយគុណធម៌ល្អៗសម្រាប់មនុស្សក្នុងលោក ដោយបង្កប់ទៅតាមរយៈសោភ័ណ្ឌភាពព្រោះថា សច្ចៈ និងគុណធម៌ពុំអាចចេញមុខបានទាំងដុលនោះទេ ត្រូវតែសំងំលាក់ខ្លួនក្នុងសិល្ប៍សោភ័ណ្ឌទើបរស់ស្ថិតស្ថេរបាន។*

## *ផលប្រយោជន៍សិល្បៈ*

*សិល្បដែលមានខ្លឹមសារល្អនេះ គឺសិល្បៈដែលមាននិយាយភាពពិតដែលស្ថិតក្នុងសង្គមប្រវត្តិនីមួយៗ ដូច្នេះសិល្បក៏តែងតែមានវណ្ណៈទៅតាមកម្រិតដើម្បីការពារផលប្រយោជន៍វណ្ណៈខ្លួនជានិច្ចនេះគេក៏ខំបញ្ចូលទ្រឹស្ដីសង្គមវិជ្ជា មនោគមវិជ្ជា និងប្រយុទ្ធទៅតាមផ្នត់គំនិត វណ្ណៈខ្លួនជានិច្ច។ ផ្នែកនេះធំទូលាយយើងទុកវាសិន ប៉ុន្តែយើងឃើញថាសិល្បតែងតែយកខ្លួនទៅប្រយុទ្ធជានិច្ចក្នុងក្របខ័ណ្ឌនៃវណ្ណៈ ព្រោះវាជាអាវុធដ៏ពិសិដ្ឋរបស់*

វណ្ណៈនីមួយៗក្នុងនេះ យើងក៏ដឹងខ្លះដែរថាសិល្បខុសពីធម្មតា វាជាជីវិតអាចកំបាំងវាជាទេព កោសល មិនមែនជាមុខរបរឡើយ ហើយជាសិល្ប៍ដែលចេះលួងលោមខ្មោចព្រាយបិសាច លួងលោមមនុស្សកាចសាហាវឲ្យស្ថិតក្នុងផ្នត់គំនិតសុទិដ្ឋិនិយមពិតៗទៀតផង។

សិល្បមិនមែនជាការកំសាន្តសប្បាយឯណា វាមានខ្លឹមសារអប់រំពុទ្ធិរំដោះកែប្រែក សាងតាមរយៈសិល្ប៍វិធីរបស់អ្នកនិពន្ធ។ ចំពោះសិល្បណាដែលអប់រំត្រង់ៗពេក សម្ញែង ពេក ពុំសូវបានផលគាប់ប្រសើរឡើយ ពីព្រោះសិល្បត្រូវតែមានសិល្ប៍អាស្រ័យហេតុនេះ បានជាអ្នកនយោបាយ សាសនា គ្រូបង្រៀនប្រើសិល្បភ្ជាប់ជានិច្ច។ ដូចជាភ្លេង កុន វិទ្យុ ដើម្បីអប់រំ អក្សរសិល្ប៍ដើម្បីអប់រំ គម្ពីលោកទេសពេលបុណ្យក៏ដើម្បីអប់រំ។ល។

សិល្បបណ្តុះសន្តានចិត្ត នឹងព្រលឹងឲ្យមនុស្សចេះភ្ជាប់ចេះរំភើប គឺជាគ្រឿង ពិសេសក្នុងការបំពេញសន្តានចិត្តរបស់មនុស្សឲ្យទៅជាមនុស្សមែនទែន (ប្លែកពីមនុស្ស ម៉ាស៊ីន) ដូចគ្នា និងផ្នែកអក្សរសិល្ប៍ ទស្សនវិជ្ជា សីលធម៌ នឹងផ្នែកផ្សេងៗទៀតដែរ។

សិល្បបណ្តុះព្រលឹង មនុស្សថ្មី សង្គមថ្មីឲ្យមានចិត្តអាណិតមេត្តា ករុណាបាន ច្រើនជាងផ្នែកដែលអត់សិល្ប៍។

ឧទាហរណ៍ រឿងទុំទាវពេលដែលគេសម្លាប់ទុំធ្វើឲ្យយើងអាណិតទុំហើយឈឺចាប់ នឹង វណ្ណៈជិះជាន់សិល្ប និងឈ្នះពាក្យ ភូតកុហក់ ជាពាក្យរបស់លោកសុសនីតអ៊ីន អ្នក រង្វាន់ណូបែ៉ល អក្សរសាស្ត្រឆ្នាំ ១៩៧០។ សិល្បៈ គឺឈ្នះពាក្យ ភូតកុហក់គ្រប់បែបយ៉ាងដែល គេប្រព្រឹត្តអំពើឃោរឃៅព្រៃផ្សៃលើមនុស្ស ដូចគ្នាបានដោយសារគេប្រើធម៌ឲ្យមនុស្ស ទទួលជឿរលុះសិល្បកំណត់ធម៌នេះបាន សិល្បពិតជាឈ្នះអំពើឃោរឃៅទាំងឡាយនេះ ជាស្វ័យប្រវត្តិ។

សិល្បមានធាតុបីសំខាន់ គឺសច្ចៈ គុណធម៌ និងសោភ័ណ្ឌធាតុពីរខាងដើមត្រូវគេ ផ្ទប់ កំទេចចោលព្រោះសម្ញែងពេកត្រង់ស្លូតពេកសល់ទីបី ប៉ុណ្ណោះដែលទម្លុះរនាំងចេញ រួចហើយផ្សាយខ្លួនវាបង្កប់ទៅដោយធាតុពីរខាងដើមជាមួយគ្នាផង។ សិល្បដែលមិនពិតគឺ ត្រូវរលាយប្រាណឯកឯងផុយទៅវិញបើសិល្បប្រកបដោយគំនិតអច្ឆរិយពិបាកវាស់បាន គឺ អាចធ្វើឲ្យរស់ក្នុងគំនិតនៃអ្នកមើលជាប់រហូតបំភ្លេចមិនបានឡើយ។

ឧទាហរណ៍ រឿងធនញ្ជ័យ ចំណែករឿងជ័យនាងវតវិញមានតែមួយរយៈកាល ហើយត្រូវគេបំភ្លេចចោលបាត់ទៅ។

សិល្បអាចធ្វើឲ្យមតិអន្តរជាតិ មតិសាធារណជន ស្គាល់ជាតិតាមរយៈសិល្បវាជាកម្លាំងខ្លះខ្ចារមួយទៅដល់បរទេសទៀតផងជាពិសេស គឺវាមានការប្តូរទំនាក់ទំនងវប្បធម៌គ្នាទៅវិញទៅមក។ ម្យ៉ាងទៀតគេអាចស្គាល់សង្គមជាតិមួយតាមរយៈសិល្ប។ ឧទាហរណ៍ ប្រាសាទអង្គរវត្ត ធ្វើឲ្យគេស្គាល់ខ្មែរ។

ទំហំតម្លៃប្រកបដោយគំនិតបញ្ញា គឺជាទេពកោសលរបស់មនុស្សក្នុងការបង្កប់ដួងចិត្ត ក្នុងសិល្បគេអាចពោលយ៉ាងសង្ខេបថា "អ្នកបច្ចេកទេសវិទ្យាសាស្ត្រជាវិស្វករនៃរាងកាយចំណែកសិល្បករជាវិស្វករនៃដួងប្រលឹង" តម្លៃនៃរាងកាយសម្ភារប៉ុនណាក៏ដោយ ក៏យើងបានឃើញបានដឹងដែលថា ដួងចិត្តទេ ដែលជាចង្កូតដឹកនាំរាងកាយឲ្យរស់។

## លក្ខណពិសេសរបស់សិល្បករ

ការទទួលស្គាល់ដោយយល់ព្រមថាខ្លួនជាសត្វនយោបាយជាន់ខ្ពស់ពិតជាការពិបាក ក៏ប៉ុន្តែចំពោះសិល្បករត្រូវតែឈ្នះ តាមរយៈស្នាដៃខ្លួនដោយត្រូវគោរព នយោបាយមានប្រព័ន្ធ ពុទ្ធិគ្រប់គ្រាន់បម្រើឲ្យវណ្ណខ្លួន នឹងមាគ៌ាបក្សក្នុងក្របខណ្ឌមហាជនប្រជាជន។

មានជំនឿមុតមាំក្នុងឧត្តមគតិ កុំមុយនីសរស់ដើម្បីប្រយុទ្ធយកជ័យជំនះដល់មាតុភូមិ មានឆន្ទះយល់ដឹងស្រលាញ់សមូហភាពមានតុល្យភាពការងារ និងផែនការច្បាស់លាស់ប្រកបដោយទិន្និផលខ្ពស់រួមចំណែកស្តារខឿនសេដ្ឋកិច្ច ជម្រុញនិងស្ថាបនាខឿនឧស្សាហកម្មទំនើបមានសាមគ្គីទូលំទូលាយជាតិ និងខ្នាំងសត្រូវគ្មានសញ្ចេតនាចំពោះជនក្រៅសង្គមជនឥតប្រជាជាតិ តស៊ូស្វិតស្វាញបង្កើតស្នាដៃកសាងមាតុភូមិ សន្តិភាព ឯករាជ្យ ប្រជាធិបតេយ្យរីកចម្រើន។

ក្នុងសកម្មភាព អ្នកនិពន្ធត្រូវបង្កើតគំនិតអរិយធម៌ខ្ពស់ បញ្ចូលសិល្បវិធីទាក់ទាញជំនឿមហាជនមកលើបក្ស មកលើភាពល្អបរិសុទ្ធឲ្យគេប្រកាន់ភ្ជាប់នូវលទ្ធិម៉ាក្សប្រឆាំងនិងឥទ្ធិពលមនោគមវិជ្ជា មូលធន ជំនឿនិយម ជាតិនិយមចង្អៀតចង្អល់នៃពួកវណ្ណជិះជាន់។

អត្ថបទត្រូវផ្អែកលើកម្លាំងបដិវត្ត សង្គមនិយមកុំមុយនីសគាំទ្រ និងរួមចំណែកផ្សាយមាគ៌ាបក្សវណ្ណកម្មករពិតៗពេលនោះអ្នកនិពន្ធហ៊ានចេញមុខការពារ និងបម្រើផលប្រយោជន៍នៃវណ្ណកម្មករដែលផ្អែកទៅលើមូលដ្ឋានច្បាស់លាស់ចម្រើនជឿនលឿន។

ប្រពៃណីចាស់មួយសម័យ និងគំនិតអភិរក្សនិយមកេងប្រវ័ញ្ចលើប្រយោជន៍នៃអ្នកដទៃ ការពារផលប្រយោជន៍ខ្លួនជាមូលធន់សិល្បករ ត្រូវហ៊ានបើកមុខវាយកំទេចការជិះជាន់អស់ទាំងនេះ។

ពិសេសត្រូវបញ្ចូលមនោគមវិជ្ជាកុំមុយនីយ ផ្តល់ការអប់រំល្អៗបណ្តុះចិត្តគំនិតឲ្យគេមានឆន្ទះបដិវត្តស្នេហាជាតិមាតុភូមិ។ សិល្បករត្រូវឈរនៅលើចុងខ្ពស់នៃបញ្ញាញាណពលករស្មោះដែត្រូវតែប្រកបដោយកម្លាំងខ្លាំងក្លារបស់មហាជន។

## គ្រឹះមូលដ្ឋាន

ប្រាសាទដ៏វិចិត្រដែលបានផុសចេញពីបញ្ញាញាណនៃពលករកម្ពុជា លូតលាស់ផុតចុងវុឌ្ឍជាតិ អួតបញ្ចេញរាងយ៉ាងសង្ហារ សបញ្ជាក់ជាជូនតាដ៏អស្ចារ្យក្នុងសម័យរុងរឿងពិតជាមានគំនិតសាងសង់ឡើងដើម្បីប្រាប់ជនអន្តរជាតិទាំងឡាយជាខ្មែរ ពុំមែនជាជាតិគ្មានវប្បធម៌អរិយធម៌នោះទេ។ លក្ខណដ៏សំបើមល្អឆើតគួឲ្យចាប់អារម្មណ៍ តើមានមូលដ្ឋានយ៉ាងណាខ្លះដែរ?

ខ្មែរជាជាតិមានដើមកំនើតចាស់ជាងគេនៅលើជ្រោយឥណ្ឌូចិន តាំងពីច្រើនពាន់ឆ្នាំមុនគ្រឹះសករាជ។ ទឹកដីដ៏ស្រស់ល្អឯកដែលជាអំណោយផលធម្មជាតិល្អផ្ដាច់មុខផ្ដល់ឲ្យចំពោះខ្មែរ បានធ្វើឲ្យទីតាំងដ៏ពិសិដ្ឋនេះមានទំនាក់ទំនងនៅលើឆាកអន្តរជាតិ។

មហាអំណាចធំដែលជាបេសកជនខាងនយោបាយ ខាងសាសនា សង្គមកិច្ច វប្បធម៌ អ្នកជំនួញបានធ្វើដំណើរតាមសមុទ្រមកឈប់សំចតស្នាក់អាស្រ័យ ទាក់ទងខាងផ្លូវសេដ្ឋកិច្ចនៅកំពុងផែអូកែវ ព្រោះថាបើយើងគិតតាមផ្លូវសមុទ្រទីតាំងនេះនៅចំកណ្ដាល ធ្វើឲ្យមានការស្រួលឈប់សំចត។ អាស្រ័យហេតុនេះហើយទើបខ្មែរមានទំនាក់ទំនងបរទេសជាពិសេសមហាអំណាចចិន និងឥណ្ឌាជំរុញឲ្យក្លាយជាមជ្ឈដ្ឋានបើកជំហរទទួលយក

អរិយធម៌បរទេស គឺជាទីដែលចរន្តគំនិតមកចម្រុះគ្នា។ ដូច្នេះអាស្រ័យទៅដោយមូលដ្ឋានភូមសាស្ត្រនេះហើយទើបជំរុញកត្តារអភិវឌ្ឍនសិល្បឈានឡើង។

ក្រៅពីនេះនៅដើមសតវត្សរ៍ទី០១ជនជាតិអារ្យដែលដឹកនាំដោយហ៊ុន ទៀនមកពីឥណ្ឌាចូលលុកលុយនគរហ្វូនន់ដាក់ជាចំណុះពេលនោះបានផ្តល់វិបាកដល់សង្គមខ្មែរ គឺគេបានជំរុញឲ្យជនជាតិដទៃ កាត់ពូជជាមួយជនជាតិដើមរលាយមកជាខ្មែរសព្វថ្ងៃ។ ទាំងអស់នេះសុទ្ធតែជាភស្តុតាងបញ្ជាក់ឲ្យឃើញថា ធាតុបរទេសចូលពីក្រៅផ្សំជាមួយ និងធាតុខាងក្នុងបង្កើតបានជាមូលដ្ឋានប្រវត្តិសាស្ត្រក្នុងការចម្លងអរិយធម៌។

ឈរលើមូលដ្ឋានទាំងពីរនេះ ភូមិសាស្ត្រប្រវត្តិសាស្ត្របានធ្វើឲ្យខ្មែរមានទំនាក់ទំនង និងបរទេសជិតស្និទ្ធជំរុញឲ្យសិល្បដើម រួមជាមួយសិល្បបរទេសទៅជាសិល្បចម្រុះឥទ្ធិពលបរទេស។

ដោយសារទំនាក់ទំនងតាមផ្លូវទូត សាសនា ការបរទេសបានធ្វើឲ្យខ្មែរទទួលយកអរយិធម៌បរទេសចម្រុះក្នុងគ្រប់កាលសម័យមាន ជ្វា ចិន ចាម ឥណ្ឌា ភូមា។ល។

ម្យ៉ាងទៀតដោយសារសាសនាខ្មែរមានទំនាក់ទំនង និងលំនាំដូចគ្នានឹងឥណ្ឌាបានធ្វើឲ្យខ្មែរទទួលយកសាសនាពីឥណ្ឌារួមផ្សំសាសនាម្ចាស់ស្រុក ឥទ្ធិពលសាសនាខ្លាំងក្លាណាស់នៅក្នុងសង្គមខ្មែរ។ គេសាងលំនៅដ្ឋានអទិទេពប្រកបដោយក្បូរក្បាច់រស់រវើក រីឯបដិមារសុទ្ធតែសំបើមៗ។ ស្នាដៃសិល្បសុទ្ធតែបញ្ជាក់ពីសាសនាជាប់ទាក់ទងជាមួយគ្នា ទោះបីជាគេក្រយ៉ាងក៏គេហ៊ានធ្វើពលិកម្មដើម្បីសាសនាដែរ ដូចជាលំនៅដ្ឋានខ្ទមប្រក់ស្លឹកព្រះវិហារវិញធ្វើពីថ្មធំៗអស្ចារ្យ ប្រាសាទសុទ្ធតែសំបើមៗម្ល៉ោះហើយទើបជាស្នាដៃសិល្បជាប់ទៅនឹងសាសនានេះឯង។ រហូតដល់មានមតិខ្លះពោលថា សិល្បសាសនា។ ជាការពិតណាស់សិល្បសាសនាមែនព្រោះវាជាប់ជាមួយសាសនា តែបើគេសង្កេតឲ្យមែនទែនមានការពុំពិតខ្លះដែរព្រោះសិល្បមានលក្ខណមនុស្សនិយមច្រើនជាងសាសនា ទោះជាមានសាសនាក្នុងនេះក៏សាសនាមនុស្សនិយមដែរ។ ដូច្នេះសាសនាមានឥទ្ធិពលខ្លាំងណាស់ចំពោះសិល្បខ្មែរ។ គេខិតខំសង់សំណង់សំបើមដើម្បីអទិទេពនៃមនោគតិអ្នកស្រុក។

គ្រឹះដែលនាំឲ្យមានការជឿនលឿនផ្នែកសិល្បស្ថាបត្យកម្មផ្អែកទៅ មូលដ្ឋានទាំងបីនេះហើយគឺ ភូមិសាស្ត្រ ប្រវត្តសាស្ត្រ សាសនាដែលជាកត្តារជំរុញអភិវឌ្ឍន៍សិល្បខ្មែរ។

ដោយសារតែទេពកោសលកំពូលរបស់ពលករខ្មែរក្នុងការទទួលយកអំណោយបរទេស ចម្រុះគ្រប់មែកធាងអរិយធម៌មកកិនទំពារលម្អិតមកជាលក្ខណជាតិមួយពិតប្រាកដ។

**ទស្សនចំពោះសិល្បៈ**

អ្នកប្រាជ្ញលើពិភពលោក បានចូលមកសិក្សាស្ថាបត្យកម្មខ្មែរបានផ្តល់មតិវិនិច្ឆ័យប្លែកៗគ្នា។

មតិខ្លះយល់ថា សិល្បខ្មែរជាសិល្បឥណ្ឌាព្រោះគេសម្អាងលើប្រាសាទខ្មែរបូរាណនិងរូបចំលាក់ដែលមានលក្ខណប្រហាក់ប្រហែលគ្នា និងឥណ្ឌាទាំងក្បូរក្បាច់ ទាំងបដិមាករ គឺដូចគ្នាបះបិទតែម្តង។ តាមពិតសិល្បខ្មែរទទួលឥទ្ធិពលពីឥណ្ឌាខ្លះមែន។

មត្តិខ្លះយល់ថាខ្មែរជាជនជាតិចាស់នៅលើជ្រោយឥណ្ឌូចិន ដូចនេះសិល្បៈខ្មែរមានយូរមកហើយ រួចវាវិវឌ្ឍនលូតលាស់ទៅតាមមនសិការរបស់មនុស្ស ដូច្នេះសិល្បៈខ្មែរគឺជារបស់ខ្មែរសុទ្ធសាធ គឺគ្មានចម្លងពីឥណ្ឌា ឬជាតិណាមួយឡើយ។ គំនិតពុំទាន់ត្រឹមត្រូវទេ ព្រោះសិល្បរីកចម្រើនលុះត្រាតែមានទំនាក់ទំនងជាមួយបរទេសទៅវិញទៅមក។

អ្នកខ្លះយល់ថាសិល្បខ្មែរជាលទ្ធផលនៃការបូកបញ្ចូលគ្នារវាងខ្មែរនឹងឥណ្ឌា ប្តូរបចនាសម្ព័ន្ធគ្នាទៅវិញទៅមក។ ពេលដែលឥណ្ឌាចូលមកខ្មែរក៏មានសិល្បខ្លួនមួយរួចទៅដែរ គឺមានអរិយធម៌ ស្ថាប័នរដ្ឋ អង្គការនយោបាយរួចស្រេចដល់មានឥណ្ឌាចូលមកខ្មែរទទួលយកមកច្នៃជាសិល្បជាតិខ្លួនព្រមទាំងបានបង្កើតជាលទ្ធផលអស្ចារ្យក្នុងការកវិវឌ្ឍនពីបរទេសមកខ្មែរ។ មតិទាំងឡាយនៅពុំទាន់គ្រប់គ្រាន់នៅឡើយទេ ព្រោះថាពេលនេះខ្មែរមានទំនាក់ទំនងជាមួយប្រទេសជាច្រើនមាន ចិន ចាម ជ្វា ឥណ្ឌា ឥណ្ឌូនេស៊ីជាដើម។ ឥទ្ធិពលទាំងឡាយបានហូរចាក់មកខ្មែរ គាត់ក៏បានផ្សែផ្សំជាតុបរទេសនឹងជាតុចាស់ចេញជាស្នាដៃខ្មែរនេះ។ ទាំងអស់នេះសបញ្ជាក់ថាខ្មែរពុំមែនជាជាតិល្ងង់គ្មានអរិយធម៌ឡើយ បើសិនជាគ្មានគឺពុំអាចទទួលអរិយធម៌បរទេសច្នៃជារបស់ខ្លួនបានឡើយគឺ ពិតជាទទួលទាំងដុលជាមិនខាន។

## ស្ថាបត្យកម្ម

ខ្មែរដែលមានទេពកោសលសិល្បបានរិះរកគំនិតច្នៃប្រឌិតកំពូល និងគ្រប់មធ្យោបាយប្រកបដោយទស្សនអភិវឌ្ឍន៍សកម្មប្រយុទ្ធ ឧស្សាហ៍ព្យាយាមគ្រប់សម័យនៃប្រវត្តិសាស្ត្រ។ សមស្រប និងបំណងនេះគេសង្កេតឃើញស្នាដៃជាច្រើន សង់ឡើងជារូបចំលាក់ជាក្បាច់ពិសេសរបស់ស្ថាបត្យកម្ម និងចំលាក់។ សូម្បីតែស្នាដៃដែលជាវិស័យដទៃយើងពុំបានដឹងដំដោយ ក៏យើងអាចយល់ឃើញទៅតាមស្ថាបត្យកម្មនេះដែរ។

ស្ថាបត្យកម្មបញ្ជាក់នូវ បញ្ញាញាណនៃពលករខ្មែរ បញ្ជាក់ពីការរីកចម្រើនផ្នែកវប្បធម៌អរិយធម៌ដើម។ ប៉ុន្តែសំណង់ទាំងឡាយច្រើនតែជាលំនៅដ្ឋាននៃសាសនាក្នុងគោលបំណងរបស់អ្នកស្រុកគេសាងសង់លំនៅអទិទេពយ៉ាងល្អឯកសុទ្ធតែនៅទីកន្លែងខ្ពស់ស្រឡះ ស្ថាបត្យកម្មដែលជាសំណង់បដិមាករក្នុងលំហអាកាស។ គេដំរាបថ្មភក់ ឬឥដ្ឋរំលេចរូបរាងខ្ពស់ពោរពេញទៅដោយបង្ហប្រហែលៗគ្នា គឺជាលំនាំទៅតាមមនោគតិសាសនា។

ស្ថាបត្យកម្មមានលំនាំជារាងកាតបាត យកទិសទាំងបួនជាអក្សបែរមុខទៅខាងកើត (លើកលែងតែអង្គរវត្ត) មានខឿនច្រើនជាន់។ តាមកំពែងពុំសូវមានក្បាច់រំលេចប៉ុន្មានទេ មានទ្វារនៅចំអក្សទាំងបួន។ វត្ថុជាតុសំខាន់ គឺប្រាសាទច្រើនមានរូបបដិមាករនៅចំកណ្តាលពីខាងក្រៅក្នុងល្វែងកណ្តាលមាន សសរស្តម្ភមានរាងបួនជ្រុងស្មើរទៅតាមទម្រង់បែរទោរកទិសបានបញ្ជាក់កំនត់មក។ ល្វែងកណ្តាលសសរស្តម្ភ ទាក់ទងមកខាងក្រៅជួនកាលដោយសារទ្វារពីរឬក៏បួនយើងឃើញថា ប្រាសាទជាច្រើនមានតែច្រកទ្វារចេញចូលមួយប៉ុណ្ណោះ នៅទិសខាងកើត ឯចំណែកទ្វារទាំងបីទៀតត្រូវផ្ទប់ជិតដោយទ្វាបញ្ចញបង្ហ។ នៅនឹងខឿនជណ្តើរប្រាសាទ ជាទូទៅគេតែងមានទ្រនាប់ជើងមួយត្រង់ថ្នាក់ជណ្តើរទីមួយ នៅលើប្រាសាទដែលសង់នៅលើទៃនទ្រស្ថិតនៅលើខឿនតូចមួយ។ ជាន់ខាងលើ គឺជាលំនៅដ្ឋានអទិទេពបរិស័ទពុំអាចចូលបាន មានសិទ្ធិត្រឹមទីលានដើម្បីគោរពបូជាសាសនាជុំវិញប្រាសាទ។

ចាប់ពីសតវត្សរ៍ទី០៧មកសំណង់ពីឈើត្រូវផ្អាក ចាប់ផ្តើមដោយឥដ្ឋបូកបាយអរ ប្រកបដោយក្បាច់រចនា។ ចុងសតវត្សរ៍ទី០៩គេឈប់ប្រើថ្មភក់ លើកលែងតែកន្ទេងមុខមាត់ គ្រឹះពីថ្មបាយក្រៀម។

គេបានបង្កើតប្រាសាទភ្នំមានពាងជាសាជីរ មានជណ្តើរបួនត្រង់អក្សរ័មានប្រាង្គ មួយឬប្រាំ។ ប្រាង្គមានការវិវឌ្ឍនជាលំដាប់។

ការវិវឌ្ឍននៃថែវមានចាប់ពីប្រាសាទបន្ទាយស្រី (ស.ត ទី១០) កាលនោះថែវបាន ចាប់កំណើតរួចវិវឌ្ឍនមកដល់បាយ័នដែលសង់នៅលើគោលការណ៍ចាស់ ប្រកបដោយ ខឿនត្រួតគ្នា និងថែវប្រកបដោយក្បាច់រចនាគោលការណ៍ថ្មី គឺគេបានធ្វើប្រាង្គមានមុខបួន ធំៗប្រាង្គមុខបួនមានបែបផែនជាព្រហ្មវិហាធម៌របស់ខ្មែរ។

គំនិតដំបូងក្នុងការរកបូង់ គឺនៅក្នុងរចនាបថឃ្លាំងដែលស្ថាបត្យកម្មចាប់ប្រែប្រួល រហូតមកដល់អង្គរវត្តដែលជាប្រាសាទភ្នំល្អវិចិត្រ។

ប្រាសាទជាច្រើនមានលក្ខណដូចគ្នា គេសង្កេតឃើញប្រាសាទនាគព័ន្ធមានស្រះ ជាច្រើន ទុកជាមាកែតបង្រួមពីភ្នំហេមពាន្ត អង្គរធំ និងព្រះខាន់បង្ហាញពីការកូរសមុទ្រទឹក ដោះរកទឹកអំម្រឹត។

សំណង់ពីឈើត្រូវបានរលាយក៏ពិតមែន តែសំណង់ពីថ្មក៏បានបញ្ជាក់យ៉ាង ក្បោះក្បាយខ្លះដែរ សូម្បីតែប្រាសាទខ្លះត្រូវខូចបាក់បែកដែលហេតុពិបាកក្នុងការសិក្សា ស្រាវជ្រាវក៏វាអាចផ្តល់នូវពន្ទឺជាមេរៀនស្តីអំពីស្ថាបត្យកម្មខ្មែរដែរ។

## ទ្រឹស្តីពណ៌

ក. វិធីប្រើ

ក្នុងការប្រើពណ៌លើក្រដាស់ពុំមែនជាការងាយស្រួលទេ បើយើងពុំស្គាល់វិធីប្រើ វានឹងនាំឲ្យខូចខាតជាមិនខានវិធីប្រើក្នុងនេះមានៈ

១. គំនូសខ្មៅដៃឬ ស្នាមដែលនៅលើបូង់ត្រូវលប់ស្អាតលាបពណ៌ស្តានកុំឲ្យ ឃើញស្នាមជក់ បើសិនមានស្នាមគឺពណ៌ពុំបានលាយស ជៀសវាងការទាញជក់ដដែលៗ ពេលពណ៌ពុំទាន់ស្ងួត។

២. សរសេរអក្សរឲ្យបានល្អ អក្សរត្រូវរត់ទៅតាមលំនាំនៃប្ញង់ និងគំនូររបស់យើង។

៣. ស្អាតជានិច្ច ជៀសវាងក្រខ្វក់កុំទម្លាប់លប់ច្រើនការលប់ច្រើននាំឲ្យខ្វេចក្រដាស់ ទឹកគួរត្រូវឧស្សាហ៍ដូរចេញជាញឹកញាប់។

៤. កុំលាបពណ៌ផ្សេងលើពណ៌ដែលទើបលាបរួច ព្រោះវាមិនទាន់ស្ងួតចាំស្ងួតសិនសិមសាបទើបស្មើ។

៥. លាបពីខ្ចីទៅចាស់ (ពណ៌ទឹក) លាបបីចាស់មកខ្ចី (ពណ៌ថ្នាំ)

៦. ឧស្សាហ៍លាងជក់ និងចានដាល់ពណ៌។

៧. មុនដំឡើងត្រូវព្រាង Esquire ជាមុនតាំងពីការរៀបចំអក្សរ ពណ៌ ទឹកន្ទៃង ប្ញង់លីង ឡើងវិញ។

៨. មានចានដាក់ពណ៌មានជក់កាត់សសៃមានតេ។

៩. ប្រើទានលីងកាត់បន្ទាត់មុនប្រើពណ៌។

១០. ការប្រើពណ៌លើរង្វង់ក្រូមាទិចត្រូវមានក្តៅមានត្រជាក់។

<u>ពណ៌</u>

អ្នកប្រាជ្ញធំៗលើសកលលោកបាន ធ្វើការស្រាវជ្រាវពីពណ៌ក្នុងធម្មជាតិបានមានមតិថា ពណ៌ដែលគេរកឃើញដុសចេញពីបាតុភូតនៃធម្មជាតិ (ឥន្ទធនូ) បន្ទាប់មកគេក៏បានបង្កើតជារបៀបបង្ហាញយ៉ាងងាយស្រួល ដល់អ្នកសិក្សាដោយគូរជារង្វង់ក្រូមាទិចប្រកបដោយ សោភ័ណ្ឌភាពដោយបានកំណត់ពណ៌ដើមដូចមាន ពណ៌បីដែលជាមេរៀន មេពណ៌ ឬពណ៌បឋមដូចជា ក្រហម លឿង ខៀវ។

ពណ៌បឋម គឺពណ៌ដែលគេពុំអាចយកពណ៌អ៊ីមកលាយចេញបាន។ តាមការវិវឌ្ឍនពណ៌ត្រូវបង្កើតជាពណ៌បីទៀតដោយបូកបញ្ចូលគ្នា នឹងពណ៌ទាំងបី។ ផលបូកនេះជៀសវាងការប្រើពណ៌មិនស្មើគ្នា (ពាក់កណ្តាល)

- ពណ៌ក្រហម បូក ពណ៌លឿង នាំឲ្យចេញពណ៌ទឹកក្រូច
- ពណ៌លឿង បូក ពណ៌ខៀវ នាំឲ្យចេញពណ៌បៃតង
- ពណ៌ខៀវ បូក ពណ៌ក្រហម នាំឲ្យចេញពណ៌ស្វាយ

លទ្ធផលនៃផលបូកពណ៌ទាំងបីមានឈ្មោះថាពណ៌បន្ថែម។ ពណ៌បន្ថែមបង្កើតបានជាពណ៌ប្រាំមួយទៀតដោយធ្វើការបូកផ្សំជាមួយពណ៌ដើម៖

- ពណ៌លឿង បូក ពណ៌លឿងទុំ ឲ្យចេញពណ៌លឿងទុំចាស់
- ពណ៌លឿងទុំ បូក ពណ៌លឿងទុំ ឲ្យចេញពណ៌លឿងក្រហម
- ពណ៌ស្វាយក្រហម បូក ពណ៌ក្រហម ឲ្យចេញពណ៌ស្វាយចាស់
- ពណ៌ស្វាយខៀវ បូក  ពណ៌ស្វាយ ឲ្យចេញពណ៌ខៀវចាស់
- ពណ៌ខៀវ បូក ពណ៌លឿង ឲ្យចេញពណ៌បៃតង
- ពណ៌បៃតង បូក ពណ៌ខៀវ ឲ្យចេញពណ៌បៃតងចាស់។

<u>គំនូរមើលឃើញ</u>

គំនូរនេះពិបាកសិក្សាណាស់ ព្រោះវាតម្រូវឲ្យយើងប្រើដៃច្រើនជាងគំនិងពិសេសនៅលើភ្នែក។ លក្ខណពិសេសរបស់វាគឺ៖

១. ត្រូវសង្កេតមើលឲ្យច្បាស់នូវទម្រង់រូបវាជារាងត្រីកោណ ជារាងការ៉េ ជាស៊ីឡាំង ស្គមឬធាត់ ចាស់ឬក្មេង។

២. ត្រូវសំឡឹងមើលលីង ជំហរនៃរូប កំពស់សំខាន់នៅលើចម្ងាយ។

៣. ប្លង់ត្រូវរៀបចំច្បាស់លាស់ គឺយកប្រជុំទម្ងន់ឲ្យនៅចំកណ្តាល កុំលើ កុំក្រោម ពេក ខាងពេក។

៤. ខ្នាតជាចំណុចពិសេស អ្នកគួរត្រូវវិភាគបានយ៉ាងច្បាស់ពីខ្នាត។

៥. ត្រូវមានវិធីកាន់ខ្មៅដៃគូរ មិនត្រូវកាន់ដូចសរសេរអក្សរឡើយ។

៦. ឧស្សាហ៍ជ្រួគី ចាប់រាងទម្រង់ខ្នាត់ បន្ទាត់ដើម្បីឲ្យដៃរស់មានជីវិត។

៧. មានវិធីចែកស្រមោលរូប។

៨. កុំទម្លាប់ប្រើស្រមោលខ្មៅពេក ត្រូវធ្ងន់ដោយស្ថិតទៅតាមសារជាតិរបស់វា ថ្មឬ ឈើ ឬដី។

៩. ក្នុងផ្ទាំងគំនូរត្រូវជ្រើសរើសប្រធាន ហើយវិភាគទៅតាមប្រធានដោយបញ្ចូលសិល្ប៍ក្នុងនោះផងដែរ។

ក្បាច់បូរាណ

ក្បាច់ខ្មែរមានរាងយ៉ាងសង្ហារពត់ពែន ទៅតាមលំនាំរស់រវើកបង្កប់ទៅដោយសោភ័ណ្ឌភាពដ៏ល្អត្រកាល ហើយមានលក្ខណប្រកបដោយតុល្យភាពទៀតផង។ រាប់រយសតវត្សរ៍កន្លងមកក្បាច់បានលេចរូបរាងយ៉ាងជាក់ច្បាស់ និងឡើងដល់កំពូលអរិយធម៌នៅសម័យអង្គរ ក្បាច់បានក្លាយជាលំនាំពិតប្រាកដហើយរស់ដោយគ្មានជនបរទេសណាម្នាក់បន្ទំថាជាក្បាច់របស់អ្នកណាមួយក្រៅពីជាតិខ្មែរឡើយ។

ប្រភព

យើងពុំសូវបានដឹងច្បាស់លាស់ទេ តើយើងគ្រាន់តែបញ្ជាក់ថាក្បាច់មានប្រភពដើមពីរុក្ខជាតិ ជាវល្លិ៍ ជាស្លឹក ជាផ្កា ជាផ្លែ នៅក្នុងធម្មជាតិជុំវិញខ្លួនគេ ដូចជាក្បាច់ដកចន្ទន៍ ចេញពីសំបកចន្ទន៍ដែលគេច្រើនយកសំបកមក បិទលម្អផ្ទះ។ ក្បាច់ដំបូងឡើងមានរាងជាវល្លិ៍ដែលស្រង់ចេញដើមទំពាំងបាយជូរ លុះក្រោយមកក៏ក្លាយជាក្បាច់ភ្ញីវល្លិ៍ រហូតដល់ក្បាច់ភ្ញីទេសជាក្បាច់ចុងក្រោយ។ ចំណែកក្បាច់អង្គរគេឃើញវិវឌ្ឍនពីស្លឹកពោធិ៍ ពីត្របកឈូក រួចទើបគេបំបែកទៅតាមលំនាំតិចនិករបស់ខ្លួនបន្តរទៅទៀត។
ក្បាច់បានក្លាយចេញជាបីប្រភេទប្លែកគ្នា មានលក្ខណពិតប្រាកដណាស់។ ដូចជាៈ

១. ក្បាច់ភ្ញីទេស មានរាងជាវល្លិ៍ជាចង្កើល ជាខ្នែង ជាមុនីពន្ធ ជាធ្មេញក្របី ជាពងត្រី ក្បាច់ទាំងអស់មានរាងខុសៗគ្នា។

២. ក្បាច់អង្គរមានរាងពីត្របកឈូកពីស្លឹកពោធិ៍ពីហាន។

៣. ភ្ញីភ្លើងមានរាងដូចអណ្តាតភ្លើង។

កម្មវត្ថុ

ការប្រើប្រាស់ក្បាច់ពុំមែនចេះតែប្រើទៅដោយគ្មានវិធីការត្រឹមត្រូវឡើយ គឺមានវិធីប្រើប្រាស់ត្រឹមត្រូវទៅតាមលក្ខណក្បាច់នីមួយៗដូចជាៈ

ក្បាច់ភ្ញីទេស ជាក្បាច់សាមញ្ញគេច្រើនប្រើនៅតាមហោផង ភោជនីដ្ឋាន លើវត្ថុប្រើប្រាស់តុ ទូ កែវ ចាន និងប្រដាប់ផ្សេងៗទៀត ឬក៏គេយកទៅចាក់ចេកធ្វើក្នុងពិធីបុណ្យផ្សេងៗ

ក្បាច់អង្គរ ពុំមាននៅលើវត្ថុប្រើប្រាស់ទេគេច្រើនប្រើវានៅកន្លែងមុខមាត់ធំៗដូចជា ៖ នៅហោងជាងព្រះវិហានៅតាមសសរស្តម្ភ នៅលើគេហដ្ឋានកិត្តិយស នៅតាមបល័ង្គ ឬកន្លែងកំសាន្តមនោរម្យ។

ក្បាច់ភ្ញីភ្ញើង មាននៅកន្លែងណាដែលសហាវដូចជានៅក្នុងពិធីបុណ្យខ្មោច ចាក់ចេក ឬនៅក្នុងស៊ីននគបាល កន្លែងសំណាក់មានអំណាចខ្លាំងជាដើម។

នៅប្រភេទក្បាច់ច្រើនទៀតដែលយើងពុំទាន់ស្គាល់ឈ្មោះដូចជា ក្បាច់ហាន និងក្បាច់រាក់រយ ក្បាច់មួយរយស្រទាប់ នឹងក្បាច់ខ្លះដែលកប់ជ្រៅហើយពុំសូវឃើញសិល្បករណាទឹកនាដល់។

<u>គំនូរបូរាណ</u>

យើងពុំបានលើកយកឯកទេសបូរាណមកបរិយាយនោះទេ វគ្គនេះយើងសិក្សាពីវិធីខ្លះៗដើម្បីឲ្យស្គាល់ពីគំនូរបូរាណខ្មែរថាតើវាមានវិធីប្រើ និងរបៀបយ៉ាងណាខ្លះ?

- ខ្មៅដៃត្រូវចិតឲ្យបានវែង (ខ.ម.ប) ត្រូវប្រើក្រដាស់ខាត់រលីងសម្រាប់សំណង់ខ្មៅដៃ។
- រៀនកាត់សរសៃឲ្យបានតូចហើយស្អាត យកល្អត្រូវមានក្រដាស់ព្រៀង ឬក្រដាស់កាល់ទើបល្អ។
- ត្រូវស្គាល់ខ្នាតនៃក្បាច់នីមួយៗ។
- ពេលគូរមិនត្រូវគូរដូចសរសេរអក្សរឡើយ គឺប្រើវិធីកាន់ខ្មៅដៃប្រយោលដើម្បីឲ្យរស់ខាងចុង។
- រកទម្រង់របស់ក្បាច់គូរចេញជាលំនាំរូបរាងសិន សិមលម្អិតយកល្អតែម្តង
- សរសេរអក្សរឲ្យស្អាតហើយស្ថិតក្នុងលំនាំក្បាច់។
- ប្រើពណ៌ឋានត្រូវប្រយ័ត្នកុំឲ្យចូលក្នុងក្បាច់ បើពណ៌បូរាណតែម្តងត្រូវឲ្យ
- ចើរៗ។
- គំនូរបូរាណគេតម្រូវយកការកាត់សរសៃរឲ្យតូច ហើយស្មើគ្នាទៀតផងអាស្រ័យយ៉ាងនេះ យើងត្រូវឧស្សាហ៍ស្រលាងខ្មៅដៃឲ្យបានញឹកញាប់បន្តិច។

គំនូរស្អាត

ត្រូវយកខ្មៅដៃមានគុណភាពល្អពីរដើម មួយរឹងល្មមដែលមានលេខ N3 ឬ HB មួយទៀតរឹងខ្លាំងដែមានលេខ N,4,2,H3,3

- ជ័រលុបត្រូវមានពីរ មួយសម្រាប់លុបខ្មៅដៃ និងទឹកខ្មៅ
- ត្រូវមានដែកឈាងប្រដាប់គូរបន្ទាត់ (ទារលីង)
- តេ (TE) មានប្រវែងស្មើនិងក្តារគូរ ឬវែងជាងក្តារគូរ
- បន្ទាត់កែងពីរមួយមាន45⁰ មួយទៀត 60⁰
- បន្ទាត់វែង (ឌុបដេស៊ីម៉ែត្រ)
- ទឹកខ្មៅគូរ (បារីយ៉ង់) ឬ ខ្មៅដុស
- ប្រដាប់វាស់មុំ (រាប់ព័រទ័រ)
- ដែកគោលសម្រាប់ចុកក្រដាស់ ឬស្កុត
- ប្រដាប់សម្អាតខ្មៅដៃ ត្រូវមានក្រណាត់សម្រាប់សម្អាត សម្ភារ

២. ជំបូន្មានក្នុងការប្រើ

ត្រូវចិតខ្មៅដៃឲ្យមានប្រវែង 20mm ប្រវែងនៃបណ្តូលខ្មៅដៃមានពី 6-8mm ត្រូវសម្លៀងជាញឹកញាប់ដើម្បីស្រួលក្នុងការគូរលើក្រដាស់។

ជ័រលុបត្រូវសង្កត់ឲ្យបានស្រាល លើគំនូរដើម្បីកុំឲ្យដាច់ក្រដាស់ចំពោះតេ ការគូរត្រូវកែងគ្នាជានិច្ច ដើម្បីឲ្យក្បាលតេរត់ស្រួលលើជ្រុងខាងឆ្វេង មិនត្រូវប្រើតេបញ្ឈរគូរបន្ទាត់ជាដាច់ខាតនៅជ្រុងខាងលើ។ បន្ទាត់កែងសម្រាប់គូរខ្សែស្រប ដែកឈាងសម្រាប់គូររង្វង់ និងវាស់ប្រវែង ទារលីងដាក់ទឹកខ្មៅនៅចំពុះប្រើក្នុងការគូរបន្ទាត់។

មុននឹងគូរត្រូវសម្អាតខ្មៅដៃ ត្រូវសម្អាតជានិច្ចតេបន្ទាត់តៃ ទារលីងឌុបដេស៊ីម៉ែត្ររាប់ព័រទ័រ។ មិនត្រូវដាក់អ្វីលើក្រដាស់គូរក្រៅពីតេ និងបន្ទាត់ជៀសវាងក្នុងការច្រត់ដៃលើក្រដាស់ ឬយកក្រដាសបោស។

ត្រូវប្រើក្រដាស់គូរទំហំ A4 = 210mm X 297mm ក្រដាស់គំនូរត្រូវដូរតាមខ្នាតនៃគំនូរចំពោះការដាក់ផ្ទាកត្រូវដាក់នៅខាងក្រោមក្រដាស់ខាងស្តាំ។

បច្ចេកទេសខ្នុកស្នាច់

សិល្បខ្នុកជាវិជ្ជាមួយដែល មានកម្មវត្ថុសិក្សាច្បាស់លាស់ដោយតួរអង្គក្នុងរឿងរាមកេរ្តិ៍ មកធ្វើជាវត្ថុសិក្សាដែលជាលក្ខណបម្រើសេចក្តីត្រូវការរបស់សិល្បករល្ខោន និងប្រជាជន។ មិនតែប៉ុណ្ណោះ ខ្នុកក៏មានរូបរាងនៅលើវត្ថុប្រើប្រាស់សំណង់បដិមាករស្ថាបត្យកម្ម នឹងសម្ភារសិកសង្គ្រាមជាដើម។ ខ្នុក គឺជាសិល្បដែលគេនិយមចូលចិត្តជាងគេបង្អស់នៅក្នុងចំណោមសិល្បទាំង ១២ ព្រោះវាជាសិល្បសាមញ្ញដែលបម្រើតម្រូវការបានគ្រប់ជាន់ថ្នាក់នៃមនុស្សសិល្បខ្នុកបានរីកផ្សាយខ្ចួនពាសពេញផ្ទៃប្រទេស ប៉ុន្តែសិល្បពុំទាន់មានការរីកចម្រើននៅឡើយនៅសម័យដើម គេឃើញមានភស្តុតាងខ្វះៗបញ្ជាក់ពីកម្មវត្ថុនេះដូចជា ធុងទឹក បំពង់ទឹកត្នោត អ្នករបាំ ប្រអប់ស្លា ដងកណ្តៀវ តាមរទេះគោរ រទេះសេះ និងតាមគេហដ្ឋាននៃវណ្ណជាន់ខ្ពស់ជាដើម។

១. ប្រភេទ

ដោយខ្នុកជាវិជ្ជាពិបាកសិក្សាព្រោះវាតម្រូវការខាងផ្នែកសម្ភារ ច្រើនដូចនេះយើងបានបែងចែកមុខវិជ្ជានេះជាបីប្រភេទផ្សេងគ្នាះ

ក. ស្នាច់

ជំពូកនេះជាវិជ្ជាសាមញ្ញបំផុត ព្រោះវាគ្រាន់តែធ្វើឡើងដោយក្រដាស់ស្នាច់រួចយើងតែងជាគ្រឿងជាការបញ្ចប់។ ប៉ុន្តែវាអាចយកលំនាំរូបរាងកំប្លែង ឬតួអង្គក្នុងរឿងមកធ្វើជាវត្ថុសិក្សាដែរមិនសូវខុសពីខ្នុកប៉ុន្មានទេ។

ខ. ខ្នុក

គេបានធ្វើវាដោយមានការស្នាច់បូកជាមួយ និងការតុបតែងមានលក្ខណខុសគ្នាពីស្នាច់ត្រង់ខ្នុកប្រើជ័រតាកោ និងជ័រម្រក្សំដោយមានការតុបតែងជាក្បាច់បិទបញ្ជាក់ បិទ ខ្យង់ហើយគេច្រើនប្រើម្សៅហុងតែនលាងពីលើខ្នុក។ ឯកទេសនេះយើងត្រូវចំណាយសម្ភារច្រើនទាំងការតុបតែងទាំងការរៀបចំ ព្រោះជាផ្នែកដែលយើងត្រូវសិក្សាវែងឆ្ងាយជាស្នាច់។

គ. ខ្នុកទំនើប

វិជ្ជានេះបានកើតក្រោយមកហើយប៉ុន្តែវាមានការសុក្រិតជាង៉ខ្នុកបូរាណ។ គេច្រើនធ្វើវានៅលើវត្ថុប្រើប្រាស់នៅលើគេហដ្ឋានលើសំណង់ តុ ទូ កៅអី ទ្វា បង្អួច និងជាផ្ទាំងគំនូរវិចិត្រកម្ម តុបតែងផ្ទះសម្បែងជាដើម។ ហើយវាអាចផលិតចេញដោយចំណាយពេលឆាប់រហ័សជាងខ្នុកបូរាណ ចំណែកសម្ភារពុំសូវច្រើនជាងខ្នុកបូរាណឡើយ។

២. កម្មវត្ថុ

លក្ខណនេះសិល្បខ្នុកបានប្រាប់បញ្ជាក់ពីតួអង្គក្នុងរឿង វាបានធ្វើតម្រូវទៅតាមរឿងក្នុងការបម្រើសេចក្តីត្រូវការរបស់សិល្បករល្ខោន មិនតែប៉ុណ្ណោះបានផ្តល់នូវសោភ័ណ្ឌមួយកម្រិតទៀតក្នុងតួរ គឺគេបានធ្វើឲ្យតួអង្គកាចកាន់តែកាចសាហាវ ហនុមានមានរិទ្ធិខ្លាំងសែនខ្លាំងព្រមទាំងបានផ្តល់នូវការតុបតែងស្អាត បានទៅតាមទម្រង់រូបរាងរបស់ដូនតាខ្មែរ និងផ្នត់គំនិតរបស់ខ្មែរទៀតផង។

ទោះបីជាមានការចម្លងចេញពីបូរាណក៏ដោយក៏ខ្នុកបានបញ្ជាក់ពីការច្នៃ បង្កើត និងការអំណត់យ៉ាងប៉ិនប្រសប់របស់ខ្មែរផងដែរ។ រូបនីមួយៗបានបញ្ជាក់យ៉ាងច្បាស់ពីអរិយធម៌ពីវប្បធម៌ឆ្លុះបញ្ចាំងសង្គមការណ៍ ប្រវត្តិការណ៍ទៅតាមផ្នត់គំនិតរបស់សិល្បករខ្នុកតាមរយៈស្នាដៃរបស់ខ្លួន។ មកដល់ពេលនេះគេនៅតែកោតសរសើរមិនដាច់ពីមាត់អំពីការព្យាយាមរបស់ដូនតា ហើយថែមទាំងបានធ្វើឲ្យគេភ្ញាក់ចំពោះផ្នត់គំនិតខ្មែរទៀត។ ដោយសារការភ្ញាក់ផ្អើលនេះហើយទើបយើងឃើញ មានការជឿនលឿនមួយតាមរយៈស្នាដៃសិល្ប និងទេពកោសលរបស់សិល្បខ្មែរ។

ខ្នុកបានផ្តល់លក្ខណសាមញ្ញដោយផលិតបានតាមចិត្តចង់ ផ្តល់ទាន់ពេលវេលានឹងសេចក្តីត្រូវការរបស់មនុស្សទាំងសម្ភារទាំងស្មារតី ព្រោះថាខ្នុកមិនធ្វើតែសម្ភារផ្សេងៗប៉ុណ្ណោះទេ គេក៏ចូលរួមបង្កើតដោយគូររំលេចជាគំនូរវិចិត្រកម្ម គំនូរបូរាណផ្សាយមនោគវិជ្ជាវណ្ណដល់អ្នកទស្សនាទៀតផង។ ទាំងអស់សបញ្ជាក់ថា ខ្នុកជាវិជ្ជាមួយមិននៅស្ងៀមគឺវាតែងតែវឌ្ឍនទៅតាមកាលទេសសង្គម ហើយក៏ជាវិជ្ជាមួយចូលរួមចំណែកយ៉ាងសកម្មក្នុងការជួយទ្រទ្រង់សុខសន្តិភាពជូនប្រជាជនទៀតផង។

*លក្ខណពិសេស*

ដើម្បីឲ្យយើងស្គាល់ច្បាស់ពីលក្ខណពិសេសរបស់សិល្បខ្ចុក យើងត្រូវសិក្សាពីសិល្បខ្ចុកបរទេសសិនយើងនឹងឃើញ លក្ខណពិតរបស់ខ្ចុកខ្មែរជាមិនខាងឡើយ។

*ខ្ចុកបរទេស*

នៅលើពិភពលោកយើងសង្កេតឃើញជាច្រើនពីសិល្បខ្ចុក ដូចជានៅសហភាពសូវៀតជាដើម ខ្ចុករបស់គេធ្វើឡើងដោយពុំប្រើជ័រម្រក្សំ ផ្ចុំ បិត បញ្ជាក់ដូចអាស៊ីឡើយ។ ចំណែកខ្ចុកនៅវៀតណាមសូម្បីតែមានលក្ខណដាំខ្យង់ ដាំកំពាក់ ស្នាច់ក៏មានលក្ខណជាតិទៅតាមទំនៀមទំលាប់ប្រពៃណីរបស់ជាតិ របស់គេទៅតាមចំណង់ចំណូលចិត្តនៃប្រជាជន។ ដោយឡែកជាតិថៃឡង់ដែលមានប្រពៃណីសាសនាទំនៀមទំលាប់ដូច ខ្មែរដែរនោះក៏មានសិល្បៈខ្ចុកខុសប្លែកគញនាស្រឡះពីខ្មែរដែរ។ ក្បាច់ក្បូរទាំងការតុបតែង គឺខុសស្រឡះពីខ្មែររហូតដល់ក្បាលម៉ាល់ក៏ធ្វើខុសពីលំនាំរបស់ជាតិខ្មែរយើងដែរ។

*ខ្ចុកខ្មែរ*

រហូតមកដល់ពេលនេះយើងដឹងភ្វាមថាខ្ចុកខ្មែរ មានលក្ខណមួយខុសគេគឺនៅលើពិភពលោកគ្មានខ្ចុកណាដូចខ្មែរដូចខ្ចុកម៉ាស់ ខ្ចុកតោក ខ្ចុកម្កុដ និងគ្រឿងបរិក្ខាផ្សេងៗទៀតសុទ្ធតែបញ្ជាក់ថាបរទេសមិនមានដូចឡើយនេះជាលក្ខណពិសេសទី១។

- ខ្មែរបានទាញកម្មវត្ថុច្បាស់ច្បាស់ដោយយកតួអង្គក្នុងរឿងមករៀបចំ។ យកផ្នត់គំនិតខ្មែរមកលម្អ យកក្បាច់ដ៏វិចិត្រមករចនា សូម្បីតែមានលក្ខណខ្វះស្រដៀង វៀតណាមក៏ដោយក៏ខ្ចុកខ្មែរមានលំនាំក្បាច់ និងការតុបតែងខុសគ្នាស្រឡះទាំងពណ៌ទាំងសាច់ម្រក្សំ ទាំងប្ញង់ និងរបៀបរៀបចំ ឧទាហរណ៍ដូចជាតោកដាំកញ្ចក់ថាតើមានជាតិណាមានតោកដាំកញ្ចក់ដូចខ្មែរដែលឬទេ ត្រង់នេះហើយទើបយើងឲ្យតម្លៃថាខ្មែរបានផ្តល់នូវពុទ្ធិវត្ថុតាមរយៈទេពកោសលដែលស្វរដោយប៊ិនប្រសប់របស់មនសិការខ្មែរជំនាន់ដើម និងបច្ចុប្បន្ន។
- គេបានបញ្ជូននូវពុទ្ធិសិល្ប៍តាមរយៈពុទ្ធិប្រធានផ្តល់ឲ្យ ចំពោះគេក្នុងអង្គវត្ថុដោយបានធ្វើឲ្យមានលំនាំកាយសំបើម សាក់សមមានតុល្យភាពពិតប្រាកដ និងផែនការច្បាស់លាស់។

សាច់រឿងមួយៗធ្ងន់ ហើយហក់ទៅមុខមិនស្ពឹកស្រពន់ ឬនៅស្ងៀមឡើយ។ គេធ្វើតោកសមតម្រូវចិត្តប្រជាជនចង់បានធ្វើឲ្យគេរិតតែស្រឡាញ់ចូលចិត្តថែម គេបានបង្កប់អរិយធម៌ បង្កប់វប្បធម៌ បង្កប់ពីសង្គមមួយទៅសង្គមមួយពីការជឿនលឿនផ្នែកគំនិតរបស់ខ្មែរក្នុងសម័យមហានគរ ទាំងអស់គឺជាសោភ័ណ្ឌភាពពិតរបស់ខ្មែរ។ បើនិយាយអំពីការតុបតែងវិញបានធ្វើឲ្យគេព្រឺរន្ធត់ និងស្នាដៃនឹងគំនិតសិងលែងជឿថាមនុស្សធ្វើបានឡើយ ឬមួយមិនយល់ថាតើគេធ្វើដូចម្តេចបានជារូបមានរាងយ៉ាងនេះ។ ចូលរួមក្នុងនេះដែរ គឺខ្ចុកសម័យបានទាញពីគំនិតនយោបាយពីសង្គមពីជីវភាពប្រជាពលករជួយបណ្តុះគំនិត ជឿនលឿនដល់អ្នកប្រើប្រាស់សម្ភារនេះទៀតផង។ រូបមួយសុទ្ធតែប្រាកដឡើងដោយតុល្យភាពមានលំនឹងមានបន្ទាត់ និងផែនការច្បាស់លាស់។

ទាំងអស់នេះហើយដែលជាតម្លៃសិល្បៈ ដែលបង្ករលក្ខណពិសេសរបស់ខ្លួនតាមរយៈស្នាដៃរបស់មនុស្ស សិល្បករក្នុងការបណ្តុះពុទ្ធិវត្ថុ ពុទ្ធិសិល្ប៍លើមូលដ្ឋាននៃពុទ្ធិប្រធានបញ្ចូលទៅក្នុងស្នាដៃបង្កើតឡើងជាសោភ័ណ្ឌ ជាលក្ខណពិសេសរបស់ជាតិមួយឡើង ហើយសឹងមិនហ៊ានជឿថាមនុស្សអ្នកធ្វើទៀតផង។

ខ្ចុកខ្មែរមានលំនាំកាតសំញែងរិទ្ធិ បញ្ចេញរាងយ៉ាសង្ហាបើហនុមានវិញ ហាមាត់បញ្ចេញធ្មេញចង្កូម ក្បាលហក់ទៅមុខមិនស្ពឹកស្រពន់ឡើយ។ រូបកំប្លែងគួរចង់សើចមានលក្ខណស្របទៅនិងជីវភាពពិតៗនៃប្រជាជន។ ខ្មែរប្រសព្វដាំខ្យងញ្ចេញជាក្បាច់ប្រដេញពណ៌មានរាងទន់ទៅតាមតុល្យភាពនៃក្បាច់តោកផងទេ សុទ្ធតែរំលេចឡើងដោយមានក្បួនខ្នាតច្បាស់លាស់របស់ខ្មែរ។ នេះហើយជាសោភ័ណ្ឌពិតៗដែលខ្មែរផ្តល់លក្ខណពិសេសដល់វា។

ក្បាច់មួយៗសុទ្ធតែមានឈ្មោះច្បាស់លាស់ ហើយបានបង្កដោយត្បូង ឬមាសជួនកាលទៀតមានទាំងដាំកញ្ចក់រំលេចពណ៌ដេញពន្លឺទៅតាមភ្លើងផងដែរ។

លក្ខណពិសេសសំខាន់បំផុតរបស់ខ្ចុកខ្មែរ គឺនៅត្រង់ខ្នាតនៃរូប និងលំដាប់ថ្នាក់នៃរាងរបស់វា ឧទាហរណ៍ដូចជាតោកតែងមានពេជន៍ ល្បៈ លំហួត ត្របកឈូកជាដើម។ ចំពោះខ្ចុកក្បាលវិញក៏តែមានក្បួនខ្នាតច្បាស់លាស់ដែរ (មើលនៅទំព័រស្នាច់)។ បើយើងនិយាយអំពីពណ៌វិញយើងដឹងភ្លាមថាខ្មែរចូលចិត្តពណ៌ធ្ងន់ ពណ៌ចាស់មិនស្រាល

ពណ៌មួយៗសុទ្ធតែលាយផ្សំទៅតាមជាតុអាកាស និងធម្មជាតិស្រុកទេសរបស់ខ្មែរ ទោះបីជាហនុមានមានពណ៌សក៏ដោយ ក៏មានពណ៌ដទៃទៀតសង្កត់យ៉ាងធ្ងន់ដែរ។ តោកខ្មែរដែលមានពណ៌ខ្មៅតាមពិតមិនខ្មៅទេគឺពណ៌ខ្មៅពងក្រហមយើងសួរម្រក្សលាយលក្ខណ៍ជំក្រឡងបណ្តាលឲ្យមានពណ៌ក្រហមយ៉ាងល្អវិចិត្រ ផ្សំជាមួយសំបកខ្យងដែលមានពណ៌ធម្មជាតិប្រដេញគ្នាស្រាប់ផងនោះ បានបន្ថែមសំរស់ខ្នុកខ្មែរឲ្យកាន់តែមានសោភ័ណ្ឌភាពមួយកម្រិតទ្វេឡើងទៀត។

ដូច្នេះខ្នុកខ្មែរធ្វើឡើងទៅតាមភូមិសាស្ត្រ ទៅតាមជីវភាពរស់នៅ ទៅតាមអរិយធម៌ជាតិ និងពណ៌សំបុល ទៅតាមតម្រូវចិត្តនៃប្រជាជនខ្មែរដែលនិយមយកទំនៀមទំលាប់តាមបែបពុទ្ធិនិយមសម្ភារគ្រឿងបរិក្ខាទាំងអស់ជូនតម្រូវទៅតាមសាសនា ជូនតម្រូវទៅតាមអទិទេពនៃផែនដី ប៉ុន្តែដោយស្នាដៃទាំងនេះមនុស្សខ្មែរពិតជាការពារនូវគំនិតខ្មែរ និងស្នាដៃខ្លួនជាមិនខាន។

ទាំងអស់នេះ សុទ្ធតែជាលក្ខណាចាំបាច់ពិសេសបំផុតរបស់ខ្មែរក្នុងការកសាងស្នាដៃសម្រាប់ជាតិនីមួយៗ នឹងដើម្បីបញ្ជាក់ប្រាប់បរទេសថាខ្មែរមិនអន់ ខ្មែរមានវប្បធម៌អរិយធម៌មុនហ៊ុនទៀន លីវយើចូលមកទៀត គឺមុនគ្រឹះសករាជទីមួយមកម្ល៉េះ។ ព្រោះថាខ្មែរជាជាតិចាស់នៅឥណ្ឌូចិន គេមានរបបគ្រប់គ្រងមានសាសនា មានស្ថាប័នរដ្ឋ មានវប្បធម៌រួចបាត់ទៅហើយមុនឥណ្ឌាចូលមកនៅគ.សទី០១នេះ។ បើគ្មានតើគេមានទ័ពឯណាទៅទប់ទល់និងហ៊ុនទៀន។ ប៉ុន្តែដោយសាសនាឥណ្ឌា និងខ្មែរគោរពជុំថ្ម ទើបគេអាចរស់នៅជាមួយគ្នាបានទៅហើយក៏ទទួលយកអរិយធម៌ទៅវិញទៅមករហូតជាតិឥណ្ឌា និងជាតិអ្នកស្រុករលាយជាខ្មែរនៅសម័យចេនឡាមកដល់សព្វថ្ងៃនេះ។

ទាំងអស់នេះគឺជាលក្ខណាពិសេសពិតប្រាកដរបស់សិល្បខ្មែរ ដោយផ្អែកទៅលើមូលដ្ឋានសំខាន់ៗដូចបានបញ្ជាក់ខាងលើនេះ។

<u>សិក្សាវត្ថុអង្គ</u>

ដោយវិជ្ជានេះបានយកតួអង្គមកធ្វើជាកម្មវត្ថុសិក្សាខ្លះនោះដូច្នេះ ដើម្បីឲ្យស្គាល់ពីបុគ្គលិកលក្ខណារបស់តួនីមួយៗក្នុងរឿង យើងត្រូវសិក្សាពីតួអង្គ និងពណ៌សំបុលហើយ

និងតួនាទីរបស់តួឯកនីមួយៗ។ ក្នុងតួទាំងអស់មានចំនួនច្រើនតែក្នុងជីវប្រវត្តិដើម្បីកុំឲ្យវែងអន្ទាយពេកយើងគ្រាន់តែប្រាប់ពីលក្ខណតួសំខាន់ ដែលជាតួរឯកហើយត្រូវការជាងគេក្នុងនេះមកបរិយាយតែប៉ុណ្ណោះ។

ជាបឋមយើងរៀបរាប់ឈ្មោះតួស្វាដែលមានមេបញ្ជាការ និងសេនាជំនាញទាំងអស់ ១៨ ក្នុងនោះមានៈ

១. ហុនមាន ពណ៌ស ពាក់មុដជាក្បាំងមានព្រុយខាងលើក្បាល

២. សុគ្រីព ពណ៌ឈាមជ្រូក មុដនាយោង

៣. អង្គត់ ពណ៌បៃតង មុដកន្ទុយហង្ស

៤. និលឯង ឈាមជ្រូកចាស់ (ពណ៌ខ្មៅ) ពាក់ក្បាំង

៥. និលផាត់ដីលែងពណ៌ស្រដៀងសាច់ ពាក់ក្បាំង

៦. និលនន្ទ ពណ៌ដីលែងសាច់ ពាក់ក្បាំង

៧. និខ្នននន្ទ ពណ៌ដីលែងខ្ចី ពាក់ក្បាំង

៨. និលពេជពណ៌ ស្វាយខៀវ ពាក់ក្បាំង

៩. និលខន្ធ ពណ៌ទឹកក្រូច ពាក់ក្បាំង

១០. ខុននិល ពណ៌ខៀវចាស់ ពាក់ក្បាំង

១១. ខុនកហនុមាន ពណ៌ដីលែងខ្ចី ពាក់ក្បាំង

១២. ពិពិត្រពានរ ប្រផេះពាក់ក្បាំង

១៣. ខុសភ ដីលែង ពាក់ក្បាំង

១៤. កេសរ ពណ៌ផ្កាឈូក ពាក់ក្បាំង

១៥. សតពាសី ពណ៌បៃតង មុដនារោង

១៦. រុក្ខរ ពណ៌ស ពាក់ក្បាំង

១៧. មហាជំម្ពូរ ពណ៌ក្រហម មុដនារោង

១៨. ជំម្ពូពាន ក្រហមលឿង ពាក់ក្បាំង

ទ័ពខាងយក្សរាពណ៍ ឬទសមុខ

១. រាពណ៍ ពណ៌បៃងចាស់ ម្កុដមុខដប់

២. ក្រុងខ បៃតងខ្ចី ម្កុដក្រើស

៣. ឥន្ទជិត បៃតងចាស់ ម្កុដក្រើស

៤. បូល្លូណាសាច់ ម្កុដមុខដប់

៥. វ៉ៃរ្យាព្យ បៃតងខ្ចី ម្កុដកន្ទុយហង្ស

៦. ពិភេត បៃតងខ្ចី ម្កុដសរសេ

៧. វិបុលចំប្បាំង ខៀវខ្ចី ម្កុដកន្ទុយហង្ស

៨. នន្ទយក្សា ខៀវខ្ចី ម្កុដកន្ទុយហង្ស

៩. សូរិយ្យាភាព សាច់ចាស់ ម្កុដកន្ទុយហង្ស

១០. មុក្ខរាល លឿងខ្ចី ម្កុដកន្ទុយហង្ស

១១. កុំវរុនរាជខៀវខ្ចី ម្កុដកន្ទុយហង្ស

១២. កុំបិន ពណ៌សាច់ ម្កុដកន្ទុយហង្ស

១៣. សែងព្រះអាទិត្យ សាច់ចាស់ ម្កុដកន្ទុយហង្ស

១៤. សត្តឡុង ក្រហមខ្ចី ម្កុដកន្ទុយហង្ស

១៥. វៃដាល ខៀវខ្ចីពងប្រផេះ ម្កុដសរសេរ

១៦. ចម្បូណាសូរ ក្រហមខ្ចី នាយរោង

១៧. កុវ៉េបាន់ បៃតង

១៨. គុជគីរីវន្ទបៃតងខ្ចី

១៩. គ្រុឌ ប្រផេះ ម្កុដនារោង

២០. មនុស្សរោះ ពណ៌ខ្មៅ

## ជីវប្រវត្តិតួអង្គ

- ហនុមាន

ករីទើបនឹងបង្ហាញយើងឲ្យស្គាល់ "ហនុមាន" នៅក្នុងរឿងរាមកេ្តិ៍ខ្មែរទាំងពីខ្មែរទី ០៥ យើងអាចប្រមូលជីវប្រវត្តិរបស់តួអង្គរនេះមានប្រភពដូចតទៅះ

ហនុមានជាបុត្រព្រះពាយ នឹងនាងអញ្ជនទេវីត្រូវជាក្មួយក្រុងពាលី នឹងសុគ្រីព នៅនាកន្ទលពន។ ក្នុងមាត់ហនុមានមានក្រយៅព្រះអាទិត្យ ១២ ភ្លឺដូចសូន្យកាន្តមានរស្មីទៅលើរហូតដល់ភវគ្គព្រហ្មទៅក្រោមដល់ឧទកបរិយន្ត។ កាលសុគ្រីពមានទុក្ខទៅលាក់មុខក្នុងគុហាមគង្គបព៌តដោយរត់អំពីពាលី ហនុមានក៏ទៅកំដរ។

កាលព្រះរាមព្រះលក្សណ៍ ត្រាច់តាមរកនាងសិតាឈប់សម្រាកផ្ទំក្រោមដើមស្វាយកើយលើឱរុព្រះលក្សណ៍ ហេតុបារមីព្រះអង្គព្រះអាទិត្យក៏បញ្ឈប់រថ ដូចជាបាំងឆ័ត្រថ្វាយ។ បុព្វនិមិត្តនេះនាំឲ្យសុគ្រីពយល់ថា មានអ្នកមានបុណ្យបារមីមកដល់ទើបបញ្ជូនហនុមានឲ្យទៅទតមើល។ ហនុមានទៅដល់ទីសម្រាកព្រះរាមក៏ឡើងលើដើមស្វាយពិនិត្យមើលស្គាល់លក្ខណព្រះអង្គថាជាអ្នកមានបុណ្យ ក៏បេះស្លឹកឈើថ្វាយស្តុតីបោះបាចមកលើព្រះរាម។ ព្រះលក្សណ៍មិនឈ្នះនឹងបោសចេញក៏លើកធ្នូរបាញ់ តែព្រះរាមភ្ញាក់ទាន់តើនឡើងសាកសួរហេតុការណ៍ ហើយឃាត់ព្រះលក្សណ៍ព្រោះទ្រង់យល់ថាជាស្វាចម្លែក។ ហនុមានក៏ចុះមកថ្វាយធ្នូសរ ហើយទូលនូវជីវប្រវត្តិរបស់ខ្លួន និងហាមាត់ស្វាបបង្ហាញសុរិយាទ័យ និងទូលព្រឹត្តិការណ៍រវាងសុគ្រីប និងពាលីឲ្យព្រះរាមជ្រាបសព្វគ្រប់។ ការជួយគ្នារវាងសុគ្រីព និងព្រះរាមក៏កើតមានឡើងហើយព្រះរាមព្រមទាំងជួយប្រហាក្រុងពាលីឲ្យក្សិនក្ស័យទៅ។

កាលសុគ្រីពនាំពានពលចិតសិបអក្ខោភិនីទៅថ្វាយព្រះរាម ដើម្បីធ្វើសង្គ្រាមរំលាយលង្កាក៏យកហនុមានទៅថ្វាយដែរ។ ចាប់ពីពេលនោះមកហនុមានក៏បានបំពេញបេសកម្មធំៗជូនព្រះរាមរហូតមកដល់បានជោគជ័យក្នុងការរំលាយលង្កា។

- ឥន្ទ្រជិត

ឥន្ទ្រជិតជាបុត្រច្បងនៃក្រុងរាពណ៍ បានជាមានឈ្មោះយ៉ាងនេះព្រោះមានរឿងតំណាលថា សម័យមួយក្រុងរាពណ៍លើកទ័ពទៅច្បាំង និងព្រះឥន្ទ្រឯឋានសួគ៌ ឥន្ទ្រជិត

បានផ្ទេងស សិល្ប៍សក្តិមាយាចាប់ចងព្រះឥន្ទ្របាន ទើបមានឈ្មោះថាឥន្ទ្រជិតបានសេចក្តី "អ្នកឈ្នះព្រះឥន្ទ្រ"។ ឥន្ទ្រជិតជាអ្នកមានរិទ្ធិមែនព្រោះគាត់បានបំពេញមុខងារជាមេទ័ព មានថ្វីដៃជាច្រើនលើទ័ពព្រះរាមគឺ កាលហនុមានទៅក្រុងលង្កា ក្រោយពីបានជួបនាងសិតាហើយក៏ធ្វើអុកឡុកចលាចលរហូតកើតប្រយុទ្ធ និងពលយក្សរបួសនឹងស្លាប់ជាច្រើន ទាល់តែក្រុងរាពណ៍ប្រើឥន្ទ្រជិតទៅតរិទ្ធិទីបំផុតក៏បាញ់សនាគទៅតតាំងទៀតរហូតចង ហនុមាន បានមកថ្វាយរាពណ៍បាន។

កាលកុម្ភការណ៍ត្រូវសព្រះលក្សិនក្ស័យ ហើយនោះរាពណ៍បញ្ជាឥន្ទ្រជិតទៅតតាំងទៀតបានប្រយុទ្ធ និងព្រះលក្សណ៍ និងទ័ពស្វាដោយចោលមោទសក្តិទៅត្រូវហនុមានស្ទុតជង្គង់ទីបំផុតឥន្ទ្រជិតថ្ងៃងសនាគបោសចងព្រះលក្សណ៍ទៀត កាលព្រះលក្សណ៍និងពលស្វារួចចំណងហើយចំប្បាំងព្រះលក្សណ៍ និងឥន្ទ្រជិតស្វិតស្វាញណាស់នៅទីបំផុតក៏ហោះទៅក្នុងស្រទាប់មេឃត្រូវសរព្រះលក្សណ៍ធ្លាក់ក្សិនក្ស័យទៅហោង។

- **ក្រុងរាពណ៍**

ពាក្យថាក្រុងរាពណ៍ក្តី រាពណាសូរក្តី ទសមុខក្តីទសកណ្ឋក្តី គឺជាឈ្មោះបុគ្គលតែម្នាក់សំដៅយកស្តេចក្រុងលង្កា។ រាពណ៍ជាកូនចៅនរណាមួយមានកោត្តនាមយ៉ាងដូចម្តេចយើងពុំបានដឹងព្រោះរាមកេរ្តិ៍ខ្មែរពុំបានពោលដល់។ រាពណ៍មានអនុភាពខ្លាំងធំ សម្បូរដោយកោតទ្រព្យ នឹងកងទ័ពខ្លាំងពូកែ។ រាពណ៍កេរ្តិ៍ខ្មែរទើបតែនាំយើងឲ្យក្រុងរាពណ៍តាំងពីខ្សែទី០៣ យើងសូមប្រមូលរឿងរ៉ាវរាពណ៍ដូចតទៅះ

ក្រុងរាពណ៍មានអគ្គមហេសីនាមមណ្ឌោគីរី មានរាជបុត្រនាមសហស្សកុមារ ដែលកើតពីព្រះនាងនេះនៅមានរាជបុត្រប្រាំបួននាក់ទៀត គឺឥន្ទ្រជិត មហោទរ អតិកាយ ត្រិសិរ នរាត័ក មហាក្បាល ទូរមុខ មុខរក្ខស កម្ភក្រទាធរទាំងប្រាំបួននាក់នេះប្រហែលកើតពីមាតាផ្សេងគ្នា ឬយ៉ាងណាយើងពុំបានដឹងដល់។ រាពណ៍មានបុត្រទាំងអស់១០អង្គរួមទាំងសហស្សកុមារផង ហើយមានប្អូនជាច្រើន គឺក្រុងខរ ខុនទូសល៍ កុម្ភការណ៍ ពិភេត នាងសូរបនខា នាងវិកតាសី។

ក្រៅពីនាងមណ្ឌោគីរី ជាមហាទេពី រាពណ៍មាននាងស្នំច្រើនអនេកទៀត សឹងជាអសុរនារី ទេពកញ្ញា ទេពទេពី ដែលរាពណ៍ប្រើអំណាចរាជសក្តិលួចយកមកធ្វើជាស្រី ស្នំក្រមការ ស្រីផ្តាររបស់ខ្លួន។ ទោះសំបូរស្រីស្នំបម្រើតាមចំណង់ហើយក្តី ក៏នៅមិនថ្អែតចួនចិត្តឡើយ។ ថ្ងៃមួយនាងសូបរខា បន្ទាប់ពីបរាជ័យនៃក្រុងខរ ចំពោះព្រះរាមព្រះលក្សណក៏ហោះទៅលង្កាទូលរាពណ៍ពីដំណើរការណ៍ព្រះលក្សណធ្វើទោសទណ្ឌ នឹងការស្លាប់នៃក្រុងខរ ខុន ទូសណ៍ ត្រីសិន នឹងអសុរយោធាទាំងឡាយ នាងធៀតក្រាបទូលដល់រូបសម្បត្តិ ចរិយាសម្បត្តិរបស់ព្រះនាងសិតាដល់រាពណ៍។ រាពណ៍ចង់បាននាងសិតា ទើបបញ្ជាដោយបង្ខិតបង្ខំមហារឹកជាអាមាត្យឲ្យក្លែងអាត្មាជាម្រឹកមាសទៅបញ្ឆោតព្រះរាម រល់តាមបាញ់ម្រឹកមាសទាំងព្រះលក្សណដែលនាងសិតាឲ្យជួយព្រះរាម។ រាពណ៍បានឱកាសក៏ក្លែងខ្លួនជាព្រហ្មណ៍ចូលទៅជួបនាងសិតា។ ក្រោយពីនិយាយចែចង់នាងពុំបានក៏ប្រែប្រាណទៅជាយក្សវិញ ហើយឆក់នាងសិតាយកទៅទាំងអំណាច។ រយៈផ្លូវអាកាសរាពណ៍បានប្រហារជតាយុបក្សី និងទម្រង់នាងសិតា ទាល់តែបាក់ស្លាបធ្លាក់មកដីព្រោះឃាត់ដំណើរដើម្បីយកនាងសិតាថ្វាយព្រះរាម។

ទណ្ឌកណ្ឌយកនាងសិតាទៅទុកនាប្រសាទក្នុងអសោនឧស្សាន ហើយបានប្រលោមស្នេហាដោយប្រការផ្សេងៗតែមិនសម្រេចតាមបំណង តាំងពីលួចឆក់នាងសិតាមក រាពណ៍ចាក់ឲ្យយាមល្បាតក្នុងសង្កត់ផ្លូវផ្សេងៗ ទាំងផ្លូវគោក ផ្លូវទឹកដូចខុននន្ទក្រាបទូលព្រះរាមថា "បពិត្រពីមុនមកណា ផ្លូវទៅលង្កាពុំដែនកម្រដល់ម្ល៉េះ"។ ពីដូចរាពណ៍បានទេពីនោះ រាពណ៍រិតរឹងរិះប្រយ័ត្នសព្វមាត់ឋាន ប៉ុន្តែទោះរាពណ៍បានប្រយ័ត្នយ៉ាងណាក្តីក៏ពុំបានផលល្អដែរ គឺបានតែសេចក្តីទុក្ខ រហូតដល់សេចក្តីវិនាស ព្រោះតែអំពើយង់ឃ្នងរបស់ខ្លួនដូចព្រឹត្តិការណ៍ដូចតទៅនេះ៖

សិង្ហអសុរក្តី សម្ពតាលនាគក្តី នាងវិកតាលីក្តី ត្រូវហនុមានជាសេនាឯកព្រះរាមយកជ័យជំនះបានទាំងអស់។ រាពណ៍កំពុងផ្ទំជាមួយនាងមណ្ឌោគីរីត្រូវហនុមានចងសក់ភ្ជាប់គ្នា ហើយមានកម្រិតថាទាសីតែទេពីយកដៃឆ្វេងទះក្បាលប្តីទើបរួចចំណងសក់។ ក្រុងលង្កាប្រាង្គប្រាសាទពលយក្សជាច្រើនត្រូវហនុមានធ្វើឲ្យឆេះស្លាប់អស់ ទុកវេទនាទាំងសហកុមារក៏ត្រូវស្លាប់ ទាំងរាពណ៍ក៏ត្រូវរត់នឹងអគ្គីភ័យអាប់យសអស់តម្លៃយ៉ាងអាមាស។

ក្រោយមកបានប្រមូលទ័ពច្រើនអនេកឲ្យពិភេតគន់គូរតាមក្បួនហោរ។ កាលពិភេតទូលថា ការឆក់យកនាងសិតាមក ជាហេតុធ្វើឲ្យអាសុរវង្ស នឹងក្រុងលង្ការវិនាសរលាយគួរថ្វាយនាងសិតាទៅព្រះរាមវិញទើបសុខ។ រាពណ៍ក៏ក្រោធខឹងទំនាយថា ពិភេតមើលងាយព្រះ ចេស្តារ ហើយដេរផ្តាសារយកស្បែកជើងវាយក្បាលកណ្តាលជំនុំ ដែលជាហេតុឲ្យពិភេតរត់ចូលខាងព្រះរាមព្រះលក្សណ៍។ រាពណ៍បរពលតាមមិនទាន់រឹតតែធូន់ ក៏យាងទៅជំនុំមុខមន្ត្រីដើម្បីគិតការសង្គ្រាមវិញ។ មន្ត្រីយក្សទាំងឡាយអត់ហ៊ានជំទាស់បំណាងរាពណ៍ទេ មានតែនាងមណ្ឌោគីរីអគ្គទេពីក្រាបទូលថា "បពិត្រព្រះភស្តារពិភេតជាអ្នកចេះសិល្បសាស្ត្រ ឈ្លាសវៃ ទាយចុតទៀងប្រាកដណាស់ គាត់បារម្ភខ្លាចសូន្យពិភពលង្កា ខ្លាចព្រះអង្គនឹងប្រជានុរាស្ត្រវិនាសអន្តរាយ ទើបទាយយ៉ាងនេះ ព្រះអង្គពុំគួរក្រោធដល់ទៅដោះសុពណ៌បាទ វាយក្បាលគាត់កណ្តាលជំនុំ ពុំអាសូគាត់ដែលរួមមាតាជាមួយព្រះអង្គ គាត់មានសេចក្តីអៀនខ្មាស់ទើបប្រាសរត់ទៅ នឹងព្រះរាមទៅជាអ្នកហោរាធិបតី ហើយវិលមកយាយីប្រល័យលង្កាវិញ"។ រាពណ៍ខឹងយ៉ាងខ្លាំង ហើយថាយើមណ្ឌោគីរី មីម្តេចទៅអួតសត្រូវយករាជ្យនិងនាងតារាទេពីឲ្យសុគ្រីពចាំមើលអញធ្វើសង្គ្រាមបូរសរគ្នានិងព្រះរាមឲ្យឃើញសខ្មៅម្តង។ នាងមណ្ឌោគីរីទូលទាស់ថា "សូមព្រះអង្គកុំអាលក្រោធព្រះរាមធោតបាញ់ បញ្ចេតកលព្រះអង្គ ព្រោះប្រើមហារីកឲ្យក្លាយជាម្រឹកមាសឲ្យព្រះរាមផ្ទៃងស ទាំងព្រះលក្សណ៍ក៏ទៅតាមព្រះរាម ព្រះអង្គកៀសខ្លួនជាព្រហ្មណ៍លួចឆក់យកនាងសិតាបានមក ហើយជាក្សត្របានជ័យចេញពីធ្វើសង្គ្រាមប្រយុទ្ធប្រលងចេស្តារគ្នា ចង់ធ្វើឲ្យព្រះរាមព្រះលក្សណ៍ក្ស័យបានដោយលួចនាងសិតាមកនេះជាហេតុឲ្យលង្កាដូចពិភេតថាប្រាក់ដមែន"។

ក្រុងរាពណ៍ស្តាប់ទេពីទូលយ៉ាងនេះក៏រឹតតែឆេះឆួលខ្នួលក្តៅក្រៅវិចារណញ្ញាណបានពោលនិងនាងថាដោយក្រោធ ទើបប្រើវិរុឡ្ហសេនសេនាឲ្យនាំពលយោធាយក្សរាប់សែនទៅតំបន់ព្រៃព្រឹក្សការពារប្រយ័ត្នសង្កាត់ផ្លូវតាមឆ្នេរសមុទ្រ មិនឲ្យពលពានរបេះផ្លែឈើបរិភោគបាន។ ព្រះរាមចង់ថ្នល់កាត់សមុទ្របញ្ជាក្រុបិន្ទរាជឈ្មោះរុក្ខរឲ្យនាំពលប្រាំម៉ឺនទៅរកបេះផ្លៃឈើធ្វើស្បៀង។ ពលស្វាជួប និងពលយក្សប្រទះគ្នាតាំងប្រយុទ្ធគ្នាជាកោលាហល វិរុឡ្ហសេនមេទ័ពយក្ស និងរុក្ខរមេទ័ពស្វាបានប្រយុទ្ធគ្នាយ៉ាងស្វិតស្វាញទីបំផុតក៏ស្លាប់

ទាំងអស់គ្នា។ ពលស្វាស្លាប់ដែល តែនៅសល់ច្រើនឯពលយក្សស្លាប់អស់គ្មានសល់ រត់រួចម្នាក់បានមកទូលអតិកាយ ដោយកន្ទ័ប្រទ្បំព្រោះវាយល់ថារុក្ខរថាហនុមាន ហើយទាំងពីត្រូវស្លាប់ក្នុង សង្គ្រាមគឺ ហនុមាន និងរុក្ខសេន។ ព្រះរាមឮថាហនុមានក្ស័យក៏លើកទ័ពថយទៅហើយ។

អតិកាយឮក៏ទូលទៅរាពណ៍តាមបានស្តាប់ រាពណ៍ត្រេកអរណាស់តាំងអួតកាងក្រទារសើចហ៊ោហោះហាយថា "មីមណ្ឌោគីរីសរសើរពិភេត មុទ្បោចោពាល និងកលល្បិចកិច្ចចំបាំងពូកែនៃព្រះរាម អីលូវព្រះរាមដោះទ័ពរត់រលាស់រលាំងភាំងទិតភ័យ" ទសមុខអរអួតក្អេងក្អាងហើយលើកច័ត្រជ័យខ្ពស់លលៃងងឹតទាំងអាកាសត្រាស់សួរប្រហេតហោថា "អីលូវព្រះរាមព្រះលក្សណដកទ័ពថយទៅហើយឬ" ប្រហេតហោទូលថា "នៅឡើយទេអីលូវព្រះរាមផ្ទុំលើភ្លៅសុគ្រីពព្រះបាទទាំងពីរគងលើពានរហនុមានទ្រព្រះហត្ថស្តាំ អង្គទទ្រព្រះហត្ថឆ្វេង" រាពណ៍ឮប្រហេតហោរទូលខុសពីពាក្យអតិកាយ ក៏ក្តៅក្រោធបើកនេត្រាក្រឡោកក្រឡោកត្រាស់ នឹងប្រហេតហោរថា "អញ់ឮអតិកាយថារុក្ខសេនសេនាច្បាំងនឹងហនុមានស្លាប់ទាំងអស់គ្នាហើយ ម្តេចឡើយក៏ក្បួនហោរថា ហនុមានរស់? ព្រះរាមណាលើកទ័ពថយ ព្រះរាមណានៅម៉េចក៏មកនិយាយកុហក់យ៉ាងនេះ?

អតិកាយទូលថា "ទូលបង្គំមិនហ៊ានបង្វែងពលរុក្ខសេនឯងបានជួយច្បាំងឃើញច្បាស់ និងភ្នែកប្រហែលជាវាឃើញស្វាដទៃហើយម៉ែជាហនុមានទេដឹង?"

ប្រហេតហោរទូលដោះថា "ពានរដែលប្រយុទ្ធ និងរុក្ខសេនសេនាឈ្មោះ រុក្ខរ" ជាត់ជំក្លាហាន ក៏សមល្មមនិងពាក្យអតិកាយទូល។ សូមជ្រាបថាស្វាទាំងឡាយជាពលព្រះរាមនោះសឹងធំៗក្លាហានចេះសិល្ប៍សាស្ត្រ នឹងថាត្រកូលពានររាជចំនួន ១៨នាក់មានសិទ្ធិអំណាចដូចហនុមានដែរ។ រាពណ៍សួរប្រហេតហោរថា "អីលូវព្រះរាមព្រះលក្សណកំពង់គិតដូចម្តេច"ប្រហេតទូលថា ព្រះរាមកំពង់ឆ្មេចព្រះនេត្រម្ខាងពត់សរឈ្មោះអរិទ្ធិច័ន្ទ សម្ទឹងឆ្ពោះអាកាស អីលូវប្រែព្រះភ័ក្តទៅក្រោយ ប្រឹក្សានិងពិភេតហើយប្រែមើលមកអាយនឹងកោះសារមកហើយ។ ប្រហេតថា មិនទាន់ផុតពីមាត់ក៏លឺសូរហាក់ដូចរន្ទះទាំងសែនកក្រើតផែនពហុធារ។

ពេលនោះក្រុងរាពណ៍សម្ដែងរិទ្ធិ គង់អស្សរថនាំនាងសិតាហោះមកថ្កើនព្រះរាម ដោយលើឆ័ត្រជ័យយ៉ាងថ្កើនថ្កាន។ ព្រះរាមជ្រាបតាមពិភេតក៏ក្រោធហើយទ្រង់កោះសរពាយវាសបំផ្លាញទង់ជ័យឆ័ត្រជ័យវិនាសខ្ចាត់ខ្ចាយ រាពណ៍ហៅពិស្ណុការមកកែអស្សរថរៀបទង់ឆ័ត្រល្អដូចដើម ហើយវររថមកថ្កើនព្រះរាមទៀត ព្រះរាមខ្ញាល់ទ្រង់យកមន្តមាយាមហានុភាពនៃព្រះឥសូហើយចង្អុលទៅរាពណ៍ៗហក់ផ្ទៃសន្ធប់ញ័រប្រាណចំប្រប់ប្រះលើរាពណ៍គិតថា "ឱអាត្មាអញ់សមនឹងក្ស័យជីវិតនេះ ដ្បិតបារមីទ្រង់ទើបរស់ធ្វងមកដល់ឋានឱព្រះរាមនេះ គឺព្រះនរាយមានអំណាចមន្តពូកែណាស់ ច្បាស់ជាលើទ័ពមកលង្កា អាត្មាអញ់ម្ដេចនឹងទប់បាននេះព្រោះលង្កាមានគ្រោះកាច ដូចពិភេតថាមែនអញ់ខឹងគាត់បណ្ដេញគាត់ៗរត់ទៅនឹងព្រះរាមបានជាក្មែកប្រមុះគេរិះ ជំនុំឲ្យគេមានជ័យ សមអញ់នឹងក្ស័យលង្កានឹងបានដៃគេមិនខាន ព្រោះតែសិតានាំឲ្យរលាយព្រះរាជវង្ស សេនាយោធាអាមាត្យទាហាន រាជបុត្រសុទ្ធតែហៅហ៊ានសមនឹងក្ស័យ។

ក្រោយពីគិតដូចខាងលើនេះរាពណ៍បាន ក្ដំពលសេនា អនេក អនន្ត គណនាមកគាល់នៅព្រះរោងរាជមន្ទីរដ៏រុងរឿងដូចព្រះឥន្ទ្រនៅព្រៃត្រៃត្រឹង្ស គាល់ថ្វាយដោយទេពតាទាំងឡាយ។ រាពណ៍បានទទួលអាប់យល់អស់តម្លៃ នឹងក្ស័យយោធាសេនាដោយសារអង្គទរាជទូតព្រះរាមម្ដងទៀតគឺ កាលអង្គទនាំរាជសារទៅថ្វាយរាពណ៍ៗបានប្រើអាមាត្យឲ្យមើលដឹងថាអង្គទ ក៏បញ្ជាពលយក្សឲ្យយាមរាំងទ្វារគ្រប់កន្លែងដែលនាំឲ្យអង្គទជាក់ទ្វារឆ្ងាយ បាក់ស្លាប់ពលយក្សអស់ប្រាំពាន់ ក្រោយពីធ្វងកំពែងបន្ទាយមួយទៅកំពែងបន្ទាយមួយអង្គទ បានប្រយុទ្ធនិងកក្ខនេសជាក្លាំងមឿង ធ្វើឲ្យកក្ខនេសចាញ់រត់ចូលក្នុងអាស្រមសម្ងំនៅ។ ទសមុខកាលលឺសូរស័ព្ទ កក្ខនេស និងអង្គទប្រយុទ្ធគ្នា ក៏បញ្ជាអាមាតឲ្យរត់ទៅមើល។ អាមាត្យម្នាក់មើលមិនទាន់មកទូលរាពណ៍ជាពានរចាញ់តេជដៃព្រះកក្ខនេសស្លាប់ទៅហើយ អាមាត្យមួយទៀតមកទូលថាព្រះកក្ខនេសចាញ់អង្គទ រត់ទៅជ្រកក្នុងអស្រមអង្គទនេះនាំសារធំអំពីព្រះរាមមកអីលូវឈរនៅសាលាឃុនខាងស្ដាំ។ រាពណ៍លឺថាសារព្រះរាម ក៏ឲ្យរៀបចំរោង រតន៍ប្រយ័ត្នបារមីរៀបគជសិល្ប៍ រាជសារ រាជសីល្ប៍ រាជរថពាជី និងពលយក្សកាន់អាវុធគ្រប់ដៃ បណ្ដាក់គ្រប់ចន្លោះផ្លូវ ហើយហៅអាមាត្យឲ្យហៅអង្គទនាំរាជសារចូលមកប្រញាប់។

រាពណ៍បានធ្វើបន្ទប់ទទួលអង្គទ ហើយឲ្យពលយក្សប្រុងបៀបរាបប្រយ័ត្នកាលបើបានឱកាសត្រូវសម្លាប់អង្គទឲ្យបាន។

តែគំនិតទសមុខ ពុំបានផលឡើយកាលអង្គទចូលទៅពលយក្សក៏ហូតអាវុធជ្រូងជ្រាង អង្គទដឹងថាគេប្រុងសម្លាប់ក៏ស្រែសន្ធាប់យ៉ាងខ្លាំង ពលយក្សក៏ស្លុតស្ញាំងភាំងភ័យប្រកាច់គ្នាឯងដំរីរាជសីល៍រត់ផាន់ជល់គ្នាឯងស្លាប់បាត់ទៅហើយ ក៏បើកបង្អួចមើលឃើញពលស្លាប់ទើបរាពណ៍មិតភ្នែកបង្គាប់ឲ្យឈប់ប្រយុទ្ធ។ អង្គទក៏ដើចូលយ៉ាសង្ហា ឡើងលើប្រាសាទរំលងឥន្ទ្រជិត ហើយថ្វាយកន្ទុយអង្គុយឲ្យបានកំពស់ស្មើនឹងរាពណ៍នាំឲ្យរាពណ៍ខឹងខ្លាំងសំឡឹងសំឡក់ ក្រលួចក្រឡៀទៅអង្គទថា "បារឯងជាបុត្រនាងមណ្ឌោគីរី អញ់ជាប្តីម្តាយបារជាឪពុកចុង ហេតុអ្វីក៏បាមិនកោតក្រែង បើមិនលើកដៃសំពះក៏គួរអង្គុយត្រង់កន្ទៃងសមគួរនឹងអាត្មាបើគិតដល់ពូជពង្ស បារពុំមានសក្តិស្មើនឹងស្តេចទេបើមិនសំពះអញ់គួរគោរពម្តាយឯងចុះ"។ ថាហើយរាពណ៍ឲ្យអាមាត្យអញ្ជើញនាងមណ្ឌោគីរីមក អង្គទស្គាល់មាតាក៏លើកដៃឆ្វេងគោរព ហើយទុកដៃស្តាំកាន់ព្រះរាជសារ ហើយពោលថា "ទសមុខឯងមានគុណអ្វីនឹងអញ់ប្រតិបត្តិតាមពិតមានតែទោសធ្វើបទទារការ កាលបិតាអញ់នៅលោកចាប់យកទៅទុកជាជើងអង្រឹងឲ្យយោអញ់ បើអញ់លើកដៃសំពះទៅចំមហាឆ្កួតព្រោះទៅសំពះ ឯជើងអង្រឹងឯង"។ ព្រះរាមប្រើអញ់មកឲ្យដំណឹងឯងថាព្រះអង្គជាព្រះនារាណ៍ ដែលទេពធិតាទាំងទិសទសនិមន្តឲ្យចុះមកប្រាក់ទសមុខមារជាចោរ លួចសម្ព័ន្ធនិងទេពីទេពតាទូទាំងឆកាមាសួគ៍មិនត្រឹមតែលួចទេពីទេពតាលួចទាំងមហេសីព្រះរាមមកទៀត។ ជាយូរក្រែងហើយដែលសារជ័យព្រះអង្គអត់អាហារទ្រង់ផ្តាំឲ្យរាពណ៍ឯងចាត់ចែងទ័ពទៅធ្វើសង្គ្រាម នឹងព្រះអង្គរហើយទសមុខឯងនឹងជាអាហារជ័យរបស់ព្រះអង្គជាមិនខាន។ អង្គទថាហើយក៏យាងយកស្លាពីពានរាពណ៍មកស៊ីដោយគ្មានកោតក្រែងបណ្តោយឲ្យរាពណ៍ក្រោធ អត់មិនបានក៏ស្ទុះទៅទះអង្គទពេញកំហឹងអង្គទគេចផុតក៏ទះដៃរាពណ៍នឹងទះតបវិញ រាពណ៍ត្រូវដំណាំដួលសន្ធប់។ ពលយក្សនាំគ្នារោមចាប់សង្កត់អង្គទៗប្រឡាយកន្ទុយក្រសោបយក្សហើយស្ទុះ ហោះធក់ទៅលើព្រះសិររាពណ៍ អសុរទាំងនោះក៏ដាច់ខ្ទួនជាដំណាត់ៗធ្លាក់មកលើកំពូលប្រាសាទធ្ទុះធ្លាយ ហើយហោះហើរទៅ។

ពពណ៍ភ្ញាក់ឡើង ក្រោធចាប់ព្រះខ័ន្ធមហាវជីរត្នចក្រប្រុងហោះទៅតាមតយុទ្ធតែអង្គរក្ស០៤នាក់ទូលឃាត់ហើយទៅតាមអង្គទចាប់យកឲ្យបាន។ យក្សទាំងបួនហោះទៅតាមស្វាហើយចោមប្រយុទ្ធតែត្រូវកំបុតក្បាលទាំង ០៤ ធ្លាក់មកដីដោយកម្លាំងដៃសេនាព្រះរាម។

ទសមុខឃើញពលយក្សស្លាប់ច្រើននាក់ក៏ក្រោធញ័រញាក់ ដូចភ្លើងឆេះកល្បទើបត្រាស់ប្រើកុម្ភកាណ៌ឲ្យលើកទ័ពទៅប្រយុទ្ធ នឹងទ័ពព្រះរាមកុម្ភកាណ៌ទូលថាឲ្យយកនាងសិតាទៅថ្វាយព្រះរាមវិញរឹតតែក្រោធច្រឡោត ដៀលកុម្ភកាណ៌ក៏លើកទ័ពទៅច្បាំងទីបំផុតក៏ត្រូវសរព្រះលក្សណក្ស័យជាមួយពល។ លើកទីពីរ ពពណ៍ចាប់ឥន្ទ្រជិតជាព្រះរាជបុត្រច្បងនាំទ័ពទៅច្បាំង ឥន្ទ្រជិតបានស្វែងសានាគបោសរួបរឹតព្រះលក្សណ និងពលស្វាជាប់ក្រញង់ ពពណ៍បានជ្រាបដំណឹងអរណាស់ហៅនាងសិតាមកផ្អាញ់ផ្អាលឲ្យតែទីបំផុតឥន្ទ្រជិតស្លាប់បណ្តោយឲ្យពពណ៍ក្រោធខ្លាំង ឲ្យយកនាងសិតាពីរពរសាកឧស្សានមកដៃម្ខាងចាប់ព្រះកេសានាង ដៃស្តាំកាន់ព្រះខ័នបម្រុងកាត់ព្រះសិរព្រះនាងសិតា តែអាមាត្យម្នាក់ឈ្មោះពិតរ័ក្ខទូលហេតុផលរំលឹក ពពណ៍ស្តាប់បានក៏ឲ្យយកនាងសិតាទៅទុកនៅឧស្យានវិញ។ តពីរនេះពពណ៍បានចាត់មហាទ័រឲ្យលើកទ័ពទៅច្បាំង តែត្រូវអង្គទវ័ធកាត់កក្ស័យទៅ។ ពពណ៍បានប្រើទ័ពឲ្យទៅស្លាប់ក្នុងសង្គ្រាមជាបន្តបន្ទាប់គ្នា គឺអតិកាយ ត្រីសីរ នពត័ក មហាក្បាល ទូរមុខ មុខរក្ខ័ស កុម្ភគ្រទាធរ មាលូមាទ។ មេទ័ពពូកែៗទាំងនេះក្សិនក្ស័យជាមួយនឹងទ័ពយក្ស ដោយចាញ់មេទ័ពនឹងពលស្វារបស់ព្រះរាម។

កាលព្រះអនុជ និងមេទ័ពដែលជាព្រះរាជបុត្រស្លាប់អស់ហើយពពណ៍រឹតតែក្រេវក្រោធ ក្តៅក្រហាយតប់ប្រមល់ទល់ទុក្ខណាស់ ត្រាស់ប្រើពលដែលសល់ពីស្លាប់ទៅនគរបាតាលដើម្បីឲ្យក្រុងមូលផល័មជាសម្លាញ់លើកទ័ពមកច្បាំង នឹងព្រះរាមៗក៏បញ្ជូនទៅស្រុកខ្មោចដូចពលយក្សដែរ ហើយទីបំផុតក្រុងពពណ៍ឯងក៏ត្រូវសរព្រហ្មាស្ត្រព្រះរាមក្សិនក្ស័យទៅហោង។

## ស្នាច់

ស្នាច់គឺជាមុខវិជ្ជាមួយដែលយើងស្រួលសិក្សាជាងគេនៅក្នុងសិល្បៈខ្នុក វាធ្វើឡើងដោយប្រើសម្ភារតិច និងមានវិធីងាយស្រួលបំផុតការធ្វើ ប៉ុន្តែស្នាច់វាជាបច្ចេកទេសដំបូង ឬជាមូលដ្ឋាននៃខ្នុក។ ស្នាច់សូម្បីតែវាមានលក្ខណងាយស្រួលខ្លះក៏ពិតមែនចំពោះពេលដែលយើងតម្លើងជាពុម្ពស្នាច់នេះហើយក្នុងមុខវិធីវាតម្រូវ នូវបច្ចេកទេសច្រើនដែលស្ថិតលើគំនិតមុន និងបានស្នាច់ជារូបអាស្រ័យហេតុនេះយើងនឹងចាប់ចែកចេញជាផ្នែកមួយៗរបស់ស្នាច់មុននិងចូលដល់ខ្នុក។

### ១. ឧបករណ៍តម្លើងរូប

មុននិងចាប់ផលិតចេញជារូបរាងជាទម្រង់នៃរូបនីមួយៗសិល្បករត្រូវ មានឧបករណ៍ផលិត និងប្រដាប់បូកដី ប៉ាន់ដី កាបិតចិតដី ស្ពាបព្រាមានមុខដូចរណាជាដើម។

ក្រៅអំពីសម្ភារអស់នេះ គេនៅមានក្រដាស់ខែង ក្រដាស់សម្រាប់ស្នាច់ នឹងម្សៅបាយមានទុកត្រៀមនៅពេលស្នាច់។

### ២.វិធីប៉ាន់រូប

បន្ទាប់ពីមានឧបករណ៍គ្រប់គ្រាន់ហើយ យើងត្រូវចាប់ផ្តើមរៀបចំដីឥដ្ឋដើម្បីប៉ាន់រូបទៅតាមលំនាំដើមពិតប្រាកដ។

ការប៉ាន់តម្រូវឲ្យសិស្សប្រមូលយកដីណាដែលជាដីឥដ្ឋ ឬក៏ដីដំបូកក៏បានមកបុកកំទេចឲ្យម៉ត់ល្អមទើបច្របាច់ជាមួយទឹកធម្មតាជាន់ឲ្យម៉ត់ចូលគ្នា លុះល្មមបោកបានយើងក៏ចាប់ផ្តើមបោកលុះត្រាតែដីស្វិត គឺថាដីស្អិតរមួតចូលគ្នា (បោកមិនជាប់ក្តារ) ទើបយកមកគរត្រួតជាទម្រង់រូបតាមគំនិតបច្ចេកទេសរៀងខ្លួន។ រួចហើយទើបគេយកឈើសំប៉ែតល្មមប៉ុនបួនធ្នាប មកវាយបង្ហាប់យកជារូបរាងទៅតាមខ្នាតពិតរបស់រូប។

វិធីប៉ាន់តម្រូវយើងស្គាល់យ៉ាងច្បាស់អំពីខ្នាតរូបនីមួយៗដូចជា៖

- យក្សមានខ្នាតមុខពីរកន្ទះ គឺចាប់ពីគល់ច្រមុះមកចង្កាមួយពីគល់ពេជន៍ទៅគល់មុដ មួយទៀតសល់ពីគល់មុដមកគល់ច្រមុះត្រង់កន្ទៃងថ្ពាស់ និងភ្នែក

កន្ទះខ្នាត មុដមាន ០២ខ្នាតកន្ទះដោយយកខ្នាតដើមរបស់វា (ពីគល់ច្រមុះមកចង្កា)

- ស្វា មានខ្នាត ០២កន្ទះដូចយក្សដែរពុំសូវខុសគ្នាប៉ុន្មានទេគ្រាន់មានទម្រង់និងរូបរាងខុសគ្នាពីយក្ស

សារសំខាន់មួយទៀតគឺនៅលើខ្សែបន្ទាត់ (លីង) ដែលទាញពីពេជន៍ចាប់ពីកំពូលមកចុងច្រមុះត្រង់រួចចាប់ទៅចង្កាដែលមានមុំ $130^0$ ទៅ $140^0$ ជាកំណត់ចំពោះយក្សៗ

ចំណែកស្វាវិញមានមុំ $120^0$ ពីពេជន៍មកចង្កា ចំពោះលីងប្រជុំទម្ងន់គឺនៅខ្សែកណ្តាលយើងពុំបានបញ្ជាក់ព្រោះផ្នែកនេះនៅលើតិចនិករបស់ជាងម្នាក់ៗ ស្គាល់ខ្នាតច្បាស់យើងក៏ចាប់ផ្តើមប៉ាន់ចេញជារូបរាងទៅតាមតិចនិក។

- រៀបចំពុម្ព

បន្ទាប់មកក្រោយពីបានសម្រិតសម្រាំងស្អាតបានរួចអស់ហើយយើងក៏ចាប់ចាក់ពុម្ព។ ការចាក់ពុម្ព យើងត្រូវប្រេងម៉ាស៊ីនមកលាបរូបពីលើឲ្យសព្វបើកដាក់ក្នុងពុម្ព។ ចំពោះវិធីលាយបាយអរចាក់គឺយើងរែងខ្សាច់ឲ្យម៉ត់ទុកឲ្យបានច្រើន ទើបលាយជាមួយស៊ីម៉ង់បៀកលាយ គឺយកស៊ីម៉ង់១/២នៃខ្សាច់។ ប៉ុន្តែជាដំបូងយើងចាក់ស៊ីម៉ង់សុទ្ធខាងមុខលើរូបឲ្យបានសព្វទើបចាក់ស៊ីម៉ង់លាយខ្សាច់បំពេញ។ យើងពុំចាក់ទាំងអស់ម្តងទេ ត្រូវចាក់មួយចំហៀងម្តងខាងណាក៏បានដែរ តែកុំភ្លេចលាបប្រេងមុខដំណរនៅពេលចាក់មួយចំហៀងទៀត។ រួចដល់ពេលបកត្រូវយកពុម្ពទៅត្រាំទឹកចោលមួយយប់សិមចាប់សម្អាតយ៉ាងស្អាតទើបយើងស្នាច់។

- វិធីស្នាច់

ស្នាច់ជាដំបូងត្រូវមានទឹកសម្រាប់លាបមុខពុម្ព ហើយទើបគេស្នាច់ក្រដាស់ខ្វៃងជាមួយទឹកមួយជាន់សិនចាំដាក់បាយម៉ានសព្វទឹកខ្វៃង ហើយទើបចាប់ស្នាច់ក្រដាស់ជាមួយបាយម៉ានជាបន្តរបន្ទាប់រហូតបានច្រើនជាន់ (១០ជាន់រូបធំ) ទើបឈប់។

លុះដល់បកមកយើងឃើញមានក្រដាស់ខ្លះហាបបន្ទាប់ យើងពុំទាន់ធ្វើយ៉ាងណាទុកវាហាលថ្ងៃមួយសន្ទុះធំសិនទើបបិតមុខវា និងម្សៅបាយម៉ានទើបមានកន្លែងណាពុំទាន់ស្រួលយើងស្នាច់បន្ថែមរហូតបានស្អាតសមដូចបំណង់។ វិធីស្នាច់សម្អាត គឺយើងត្រូវប្រើក្រដាស់ខ្វែងដោយតំរៀបតាមលំដាប់ រួចទាញជក់កណ្តាលកុំទាញចុះឡើងនាំឲ្យខូចក្រដាស់ស្នាច់មិនល្អ។

រួចអស់ហើយយើងចាប់ ផ្តុំរូបទាំងពីរចំហៀងឲ្យមូលដោយកាន់ស្បែក ឬដេរភ្ជាប់ទើបស្នាច់សម្អាតមុខជាការស្រេច។

- ការតម្រៀបគ្រឿង

យើងចាប់បិតក្រដាស់កាតុងចំនួនបីជាន់ ដោយសង្កត់ និងក្តារស្មើទុកចំនួនមួយល្ងាចទើបបើកហាលថ្ងៃទុកឲ្យស្ងួត ហើយយើងក៏ធ្វើពុម្ពគ្រឿងរបស់រូប។

រួចទើបយើងយកគ្រឿងមួយៗមកកាលបញ្ចូលនៅលើ ក្រដាស់កាតុងបិទបានរូបរាងហើយយើងកាត់ទុកឲ្យគ្រប់ចំនួនចង់បានទើបចាប់តម្រៀបក្នុងរូបរបស់យើង។ ការតម្រៀបនេះត្រូវបិតវាដោយជ័រស្បែកដាក់ទៅតាមកន្លែងដែលត្រូវដាក់ ចំណែកចង្កូមធ្វើឡើងដោយល្ពៅ ឬឫស្សីបិតជារាងមូលស្រួច ពត់និងភ្លើងឲ្យកោងយកវាមកដេរ និងអំបោះភ្ជាប់ទៅនឹងរូបទើបយើងស្នាច់សម្អាតមុខបន្តទៅទៀតរហូតបានស្អាតគ្រប់សព្វចាប់ផ្តើមលាបថ្នាំ។

- វិធីលាប

ដំបូងយើងលាបដីលែងកូរជាមួយការស្បែក តែយកដីកន្លែងណាដែលនៅក្រើមទើបចាប់ផ្តើមលាប។ ការលាបត្រូវមានចានដីថ្នាំពណ៌ កុំប្រើច្របូកច្របល់គ្នានាំឲ្យពណ៌ពុំបានដូចបំណង។ លុះលាបបានចំនួនបីសាររួចហើយទើបចាប់លម្អិតមួយៗទៅតាមក្បាច់ គឺយើងឲ្យពណ៌នៅលើចិញ្ចើម ត្រចៀក ពេជន៍ ព្រុយ ស្រកីមាត់ឡើងទៅ។ រួចអស់ទុកឲ្យស្ងួតចាប់ផ្តើមកាត់សរសៃទៅតាមរាងចិញ្ចើម មាត់ ព្រុយ ត្រចៀក ទើបកាត់សរសៃ និងដាក់លេខ ០១,០២ឬលេខ០៤ក៏បានបច្ចេកទេសកាន់មាននៅក្នុងរូបថតនេះ។

- ក្បាច់

ចំពោះក្បាច់យើងគូរតាមលំនាំក្បាច់ត្របកឈូក និងក្បាច់ភ្ញី ទេសា ដោយលើកយកភ្ញីទេសចង្កើលមកលម្អផ្ទាសខាងក្រោយ។

- ខ្មុក

១. យើងបានដឹងរួចមកហើយអំពីវិធិស្មាច់ និងបច្ចេកទេសរបស់វា។ ដោយខ្មុកមានមូលដ្ឋានពិតប្រាកដរបស់វា គឺស្មាច់។ ដូច្នេះ គ្មានអ្វីគួរឲ្យសង្ស័យទៀតទេ ចំពោះបញ្ហានេះ គឺវាគ្រាន់តែជាវិធីមួយប្លែកពីស្មាច់បន្តិច ហើយមានសោភ័ណ្ឌល្អជាងនឹងវាជាតិចនិចពីបូរាណកាលទៀតផងនោះ ដូច្នេះសិស្សត្រូវតែសិក្សាជៀសមិនរួចអំពីបញ្ហាខ្មុក ទោះបីជាយើងពុំទាន់អនុវត្តន៍មានទ្រឹស្តីជាមូលដ្ឋានផងដែរ។

ខ្មុកជាមុខវិជ្ជាមួយដែលអ្នកបច្ចេកទេសត្រូវធ្វើការស្រាវជ្រាវរកប្រភពកំណើត រកវិធីធ្វើនឹងការផ្សំប៉ុន្តែពេលនេះយើងសូមមិត្តយល់ឲ្យច្បាស់ថាតើខ្មុកត្រូវផ្សំឡើងពីអ្វីខ្លះក្នុងនេះ។

- ការផ្សំខ្មុក

ការបង្កើតចេញជាខ្មុកពិតប្រាកដនេះ គឺគេច្រើនយកវត្ថុធាតុដើមខ្លះៗពីដើមរុក្ខជាតិដូចជា៖

ជ័រគ្រើស ស្រង់ចេញពីដើមគ្រើស

ជ័រចុង ស្រង់ចេញពីដើមថ្នុងត្បែង

ជ័រទឹក ស្រង់ចេញពីដើមឈើទាល

ប៉ុន្តែចំពោះជ័រម្រក្ស័ គឺត្រូវស្រង់ពីដើមណាដែលមានអាយុពី ៣០ឆ្នាំ ទៅ ៤០ឆ្នាំទើបជ័រមានគុណភាពប្រពៃ។

របៀបផ្សំ គឺគេយកម្រក្ស័ចំនួន ១០គីឡូ ជ័រចុង ១០ គីឡូ និងអាចម៍លាក់ ០៤គីឡូ ចំពោះវិធីផ្សំធ្វើតោកចំពោះខ្មុករូប គឺយកជ័រម្រក្ស័ ០៩គីឡូ បូកនិងជ័រចុង ០២គីឡូ បូក

ជាមួយជ័រទឹក ០៥គីឡូ។ បុកជ័រចុងឲ្យម៉ត់រួចចាក់បញ្ចូលគ្នាចូលក្នុងខ្ទះមួយស្អាតទើបដាក់នៅលើឡើង។

- ស្ងួរ

វិធីស្ងួរខ្មុកគេមិនដុតអុសទេ នាំឲ្យឆាបឆេះដល់ជ័រ គឺគេដុតធ្យូងហើយប្រយ័ត្នបំផុត។ បើសិនជាមានហេតុការណ៍ផ្សេងៗគេចាក់ផេះស្ងឹកឆ្នោតលាយ ឬថែមជ័រទឹកទៀតដើម្បីឲ្យវាសមល្មមម្រក័្យ លុះស្ងួរវាបានរយៈពេល ០២, ០៣ ម៉ោងក្រោយមកទើបយើងចាប់ម្រក័យបិទពុម្ព។

- ការបិទពុម្ព

ពុម្ពដែលគេឆ្លាក់ក្បាច់នៅនឹងថ្មកែវ ឬឆ្លាក់ដីចាក់ពុម្ពស៊ីម៉ង់ គេត្រូវយកមកទុកនៅជិតចង្ក្រានរួចទើបលាងដៃដោយសាប៊ូរដើម្បីស្រួលចាប់ជ័រមកបិទពុម្ព។ វិធីបិទ គឺយើងមានឈើមូលមួយទំហំប៉ុនមេដើងប្រវែងមួយចំអាមលុះយើងបិទជ័ររួចហើយទើបលន់លើពីលើជ័រចុះឡើងរួចក៏បកបោះទៅក្នុងទឹកដែលបានទុកជាស្រេចជិតខ្លួន ចលនាចេះតែប្រព្រឹត្តទៅដដែលៗរហូតបានគ្រប់ចំនួន។

- ផ្គុំ

បន្ទាប់ពីបក់ពុម្ពរួចយើងស្រង់វាពីក្នុងទឹកយកមកកាត់សម្អាតម្តងមួយៗទុក។ នៅពេលផ្គុំ គឺគេយកវាទៅពោលភ្លើងឲ្យទន់បន្តិច ទើបលាបការស្បែក បិទទៅតាមកន្លែងនៃក្បាច់ត្រូវដាក់ (ចន ពេជន៍ ក្បាំង ត្រចៀក ស្រគី) ប៉ុន្តែក្នុងការបិទត្រូវប្រយ័ត្នកុំឲ្យឃើញមុខដំណរនៃក្បាច់ គឺយើងត្រូវកាត់តម្រឹមឲ្យបានស្មើចាំបិទ បន្ទាប់មកគឺនៅមានការសម្អាតបន្តរបន្ទាប់ទៀតទំរាំបានស្អាត។ ប្រយ័ត្នផ្គុំរួចត្រូវទុកដាក់ឲ្យបានស្រួលកុំឲ្យធ្លាក់ព្រោះម្រក័្យស្រួលនាំឲ្យបែកជាមិនខាន។

ប្រយ័ត្នមួយទៀតត្រូវហាមក្មេងចូលជិត ឬ ឈរក្រោមផ្សែង ឬខ្យល់បណ្តាលឲ្យពោទ៍ហើមមុខមាត់ក៏មាន។

- លាប

ដំបូងយើងលាបម្សៅ ហុងតានពណ៌ក្រហមមួយជាន់សិនសិមលាបពណ៌មាស់ពីលើ បន្ទាប់មកទើបយកថ្នាំមកដាក់ពណ៌មានខ្វះ គេកាត់កញ្ចក់ដាក់បង្កប់ដូច្នេះយើងពុំចាំបាច់លាបពណ៌ថែមទេ នាំឲ្យខូចសមាសភាពពណ៌។

- ការរៀបចំគ្រឿងលើរូប

ចំពោះរូបដែលផ្ដុំខ្នុក គឺត្រូវការតាក់តែងគ្រឿងច្រើនហើយសុទ្ធតែធ្វើឡើងពីសម្ភារមាំៗទៀតផង។ គ្រាន់តែវិធីស្នាច់យើងបានដឹងរួចមកហើយថាគេស្នាច់ និងជ័រតាកោរទើបជាប់ល្អឯចំណែកគ្រឿងក៏យ៉ាងនេះ គេច្រើនធ្វើពីស្បែកសត្វគោដោយធ្លាក់ជាក្បាច់ដូចជាមាននៅជនត្រចៀក ត្រចៀក ពេជន៍ ក្រៅពីនេះគេពត់ល្ពៅយកមកដាក់វ័ណ្ឌជុំវិញពេជន៍នីមួយតាមថ្នាក់របស់វារួចហើយទើបគេបិទក្រដាស់ក្បាច់ពេជន៍ ពីក្រៅស្រួលក្នុងការទប់ក្បាច់ឲ្យជាប់ឯចង្កូមក៏ត្រូវធ្វើពីល្ពៅដែរ។

- ថ្នាំ

ចំពោះថ្នាំពណ៌គេពុំយកពណ៌ប្រេងដូចអីលូវទេ គឺគេយកពណ៌ម្សៅមកលាយជាមួយ និងការស្បែកកូរឲ្យម៉ត់ល្អទើបគេលាប យកតែម្ដងៗ ពណ៌ម្សៅមានលក្ខណៈងាយជាងពណ៌ប្រេង គឺវាអាចផ្ដល់លទ្ធភាពរហ័សទាន់ចិត្ត។ លាបតែក្នុង ១៥នាទីស្ងួតបានកាត់សរសៃ ភ្លាមៗ។ លុះលាបកាត់សរសៃរួចទើបគេយកហ្វាក់នី មកលាយប្រេងសាំងលាបនោះបើចង់មានពណ៌រលោងល្អ។

២. ចំពោះតោកក៏មានវិធីវាដូចរូបខ្នុកដែលគ្រាន់តែមានវិធីប្លែកបន្តិចប៉ុណ្ណោះដូចជា៖

- ការលាយជ័រមានបីមុខ គឺជ័រម្រក័្យ ១០គីឡូ ជ័រចុង ១០គីឡូ អាចម៍លាក់ ០៤ គីឡូ។
- របៀបសូរដូចគ្នាមិនខុសគ្នាទេ។

- ការរៀបចំតម្រូវឲ្យមានការខុសគ្នា ដូចជាយើងឃើញគេបិទឬស្សី ឬក៏ល្ពៅមកក្រងបញ្ចូលគ្នា ហើយរៀបចេញជារូបរាងតោតែលមានលំហួតពេជន៍ ត្របកឈូកជាក់។

- ប្រភេទ

តោកមានបីបែបផ្សេងគ្នា គឺមួយធ្វើឡើងដោយគ្រាន់តែស្វរខ្លួនដូចខ្មុករូបដែលចំណែកវិធីរៀបចំមិនខុសគ្នាទេ។

ចំពោះប្រភេទតោកមួយទៀត គឺត្រូវធ្វើក្នុងរយៈពេលជាច្រើនខែថ្ងៃទើបគឺជាតោកដាំសំបកខ្យងរបៀបស្វរម្រក្សមានដូចវិធីស្វរខាងលើ ដោយមានបូកបញ្ចូលអាចម៍លាក់បន្ថែមចំណែកវិធីធ្វើក៏មានលក្ខណខុសពីតោកប្រភេទទីមួយដែរ។ ដូចនេះក្នុងទំព័រមេរៀនយើងសូមលើកយកតែតោកដាំខ្យង់ និងដាំកញ្ចក់មកសិក្សាព្រោះវាជាវិធីដែលពិបាកសិក្សាជាងក្នុងមុខវិជ្ជាខ្មុកស្នាច់។

ឧទាហរណ៍

យើងដឹងហើយថាធ្វើអ្វីក៏ដោយត្រូវតែពឹងផ្អែក លើឧបករណ៍ទាំងអស់ដូច្នេះដើម្បីឲ្យស្គាល់ការធ្វើឡើងរបស់តោកដាខ្យង ដាំកញ្ចក់យើងត្រូវដឹងអំពីឧបករណ៍របស់វាសិនតើមានអ្វីខ្លះ?

ទីមួយមានផេះស្ទឹកត្នោតសម្រាប់ខាត់ និងក្រដាស់ខាត់រលីង $N^0$-1 មានរណាអារខ្យងដែលធ្វើពីដែករល័រ ឬហ្វ្រាំងកង់ ឬម៉ូតូបើលួសត្រូវកាប់មុខបន្តិចៗដូចមុខរណាទើងអារបានបើហ្វ្រាំងម៉ូតូគឺ ពុំចាំបាច់ទេ។ រណានេះមានរាងដូចរណាអារដែកៈ

- មានដែកឆ្ងាក់មានមុខស្រួចដូចម្ជុលសម្រាប់គូរក្បាច់
- មានឃ្នាប់ឈើសម្រាប់កៀបសំបកខ្យង ដែលត្រូវអារមុខជាពីស្រួលក្នុងការកៀបប៉ុន្តែត្រូវប្រយ័ត្នកុំកៀបខ្លាំងនាំឲ្យបែកសំបកខ្យង។

ប្រើដែកដុតកំដៅជ័រ ប៉ុនបាតដៃរមុននឹងដាំខ្យងបន្ទាប់ពីដាំខ្យងរួចត្រូវទុកដាក់វាយ៉ាងប្រយ័ត្នបន្ទាប់ពីម្រក្សមានអាយុបានមួយអាទិត្យ ទើបយើងខាត់និងក្រដាស់ខាត់ម៉ត់

ទន់លេខ០១ (ខាត់ទឹក) ឬនៅពេលបានស្រួលហើយយកផេះមកខាត់បន្ថែមទៀតដើម្បីឲ្យភ្លឺមានពណ៌ល្អ។

- បិទខ្យង

នៅពេលបានប្រក្ស័គ្រប់គ្រាន់ ហើយមានឧបករណ៍ធ្វើក៏មានគ្រប់គ្រាន់ដែរនោះ យើងត្រូវចាប់ផ្ដើមដាំខ្យង។

ការដាំខ្យងត្រូវធ្វើឡើងដោយយើងអារខ្យងជាក្បាច់ផ្សេងៗ តាមសេចក្ដីត្រូវការរបស់យើងទុកបានមួយកំប៉ុងពីកំប៉ុងរួចហើយ។ ដុតដែកប៉ុនបាតដៃឲ្យក្ដៅយកមកពោទ៍មុខបន្ថែមៗឲ្យរលាយជ័រទើបចាប់ផ្ដើមបិទក្បាច់ ឬកញ្ចក់ទៅតាមលំនាំនៃក្បាច់ចង់បានពេលនោះយើងសាច់ជ័ររលាយចេញមកលើពុំទាន់ ដោយហេតុយើងបង្កប់ខ្យងចូលទៅក្នុងជ័រ។ បន្ទាប់ពីទុកដាក់ស្រួលបួលមួយអាទិត្យកន្លងមក គេយកវាមកខាត់និងក្រដាស់ខាត់ម៉ត់បំផុតជាមួយទឹក ឬក៏ខាត់ជាមួយផេះស្ងឹកត្នោតក៏បានការខាត់នេះគេមិនបង្ខំពេកទេ។ លុះខាត់រួចហើយយើងឃើញតោកឡើងភ្លឺថ្លាមានពណ៌ប្រដេញគ្នាយ៉ាងល្អបំផុត។

- បញ្ចោក់

ហេតុអ្វីបានជាយើងនិយាយថាខ្ចុកប្រើរយៈយូរក្នុងការធ្វើ ដូចបានជំរាបហើយពីបញ្ហាទាំងឡាយខាងលើ គឺថាក្នុងរយៈកាលមួយនៃការក្របឫស្សី ឬល្ពៅបានប្រើពេលយ៉ាងយូទៅហើយ លុះដល់ស្វរខ្ចុកក៏ត្រូវផ្អែកលើមូលដ្ឋានបច្ចេកទេសច្រើនដែរ ប៉ុន្តែកិច្ចការដែលពិបាកជាងគេ គឺការកាត់ខ្យងចេញជាក្បាច់ភ្ញីទេស ល្អិតៗបន្តិចម្ដងៗតើត្រូវប្រើរយៈពេលប៉ុន្មានទៀត។

ចំពោះការលាបម្រក្ស័គេពុំយកជក់លាបទេដំបូង គឺគេចាក់ម្រក្ស័បំពេញឲ្យបានសព្វលុះស្ងួតទើបគេលាបនិងជក់ទំរាំដល់ពេលគេដាំសំបកខ្យង។

### ៣. វិធីធ្វើម្កុដ

ក្នុងប្រភេទខ្នុកយើងឃើញវិជ្ជាមួយទៀតសំខាន់ណាស់ ក្នុងការកតុបតែងលម្អដល់សិល្បករបរបាំ និងល្ខោន ខោល គឺមុខវិជ្ជាធ្វើម្កុដ ប៉ុន្តែមុននិងស្គាល់ពីវិធីធ្វើរបស់យើងគួរដឹងថាតើម្កុដមានប្រវត្តិយ៉ាងណាដែរ?

- ប្រវត្តិ

ម្កុដបើតាមការសិក្សាយើងឃើញមានប្រភពមកពីការរាវរក សោភ័ណ្ឌនៃមនុស្សជំនាន់ដើម។ ដំបូងអ្នករាំរបាំ ឬក៏ស្តេចពុំមានម្កុដពាក់ទេ គេធ្វើសក់របស់គេជារាងផ្កាភ្ញី ឬក៏ក្រងសក់ឡើងទៅលើលុះដល់តំណាក់កាលក្រោយមកគេក៏ បង្កើតជាម្កុដឡើងតាមគំនិតរបស់ជាងដែលជាសិល្បករ ប៉ុន្តែយើងឃើញម្កុដដើមនៅពុំទាន់មានសមាសភាពប៉ុន្មានទេគឺវាមានរាងស្រដៀង និងក្បួងសក់ដល់ក្រោយមកអរិយធម៌ជាតិឡើងខ្ពស់គេឃើញមានម្កុដផុសព្រោងព្រាតនៅសម័យសាងប្រាសាទអង្គរវត្ត និងប្រាសាទបន្ទាយស្រីជាដើម។ ដូច្នេះយើងដឹងថាម្កុដពិតជាមានប្រភពកំនើតពីក្បួងសក់ជាមិនខាងឡើយ។

- ប្រភេទ

ម្កុដខ្នុកមានពីប្រភេទគឺ ម្កុដនាពេងនិងម្កុដនាងទាសាសាមញ្ញជាម្កុដប្រុស និងម្កុដស្រី។

ម្កុដប្រុសពុំសូវមានក្បាំងខាងមុខដូចជាម្កុដស្រីឡើយ ហើយមានល្បះប្រាំជាន់ត្រួតគ្នាឡើងបន្តរបន្ទាប់ទៅលើឯចំណែកការតុបតែងមានលក្ខណប្រហែលគ្នា។

ម្កុដស្រីមានក្បាំងពីមុខ កាច់ក្បាំងចនក្បីទៅតាមលំនាំល្អវិចិត្រ ប៉ុន្តែយើងឃើញមានល្បះពេជន៍តែបីជាន់ប៉ុណ្ណោះការតុបតែងដូចគ្នា និងម្កុដប្រុសដែរ។

- វិធីធ្វើ

ដោយខ្នុកមានមូលដ្ឋានពិតគឺស្នាប់ ដូច្នេះម្កុដក៏ត្រូវធ្វើពិស្នាប់មកមុនដែរ ដំបូងគេចិតដីរាងមូលប៉ុនក្បាលមនុស្សមានទម្រង់ទ្រវែងឡើងលើ ទើបចែកជាថ្នាក់ល្បះពេជន៍តាម

ដាន់របស់វាបន្ទាប់មកគេស្នាច់ក្រដាស់មួយដាន់ពីដាន់ ហើយលាបដីលែងពុម្ពទុកលុះពីថ្ងៃក្រោយគេក៏ចាក់ស្នាច់យកតែម្ដង។

ចំពោះការតុបតែង គឺគេយកដែកលួសធ្មារតូចមកវុំនិងដែកមួយតូចល្មមជាផ្កាញ័រប្រវែង 50mm ឲ្យបានច្រើនគេកាត់ក្បាច់ជារាងផ្កាចន្ទន៍តូចសមល្មមមកចងនឹងចុងរញ៉័រហៅថា ផ្ការញ័រយកទៅផ្គុំតាមថ្នាក់ល្បះមួយៗឡើងទៅ ប៉ុន្តែមិនឲ្យញឹកញាប់ទេ។ គេធ្វាក់ក្បាច់ទម្លុះ (ចន) ជាក្ដីវល្លិ៍តាមលំនាំយកមកបិតខាងមុខបញ្ចេញជាក្បាំងមុខ ហើយកាន់ស្បែកមួយទៀតធ្វើចនត្រចៀកទៀត សូមកុំភ្លេចថាសម្ភារនេះត្រូវធ្វើឡើងពីស្បែកគោខាងក្នុង (ស្បែកទន់)។

បន្ទាប់មកទើបគេចាប់ផ្ដើមស្ទួរជ័របិត (ផ្គុំ) តាមលំដាប់ឯតិចនិកស្ទួរជ័រគឺដូចគ្នានិងការស្ទួរជ័របិររូបខ្នុកដែរមិនដូចតោកទេ។ រួចស្រេចហើយគេក៏កម្រិតវាឲ្យល្អស្រួលបួលទើបចាប់ផ្ដើមលាបម្សៅហុងតែន។ លុះស្ងួតទើបលាបមាសរំលេចឡើង សូមបញ្ជាក់ថានៅតាមកញ្ចាំងគេមានកាត់កញ្ចក់បង្កប់មួយៗតាមផ្កាញ័រគឺ មានបង្កប់កញ្ចក់ដែរដើម្បីឲ្យភ្លឺត្រូវនិងភ្លើងបញ្ចាំង។

## សំលៀកបំពាក់

មុខវិជ្ជាខ្នុកដែលយើងសិក្សារៀនសូត្រមកនេះ យើងក៏បានប្រទះឃើញនូវមុខវិជ្ជាមួយទៀតដែលត្រូវចេះរៀបចំវាទៅតាមសាច់រឿងនៃតួនេះ គឺការកាត់សំលៀកបំពាក់និងការតែងលម្អជាពណ៌សំបុល ជាបច្ចេកទេសរៀបចំដើម្បីសោភ័ណ្ឌនៃតួអង្គនីមួយៗក្នុងរឿង។

វាមានរូបរាងស្រដៀងគំនូរបូរាណដែរគ្រាន់តែខ្នុកជាបច្ចេកទេសជាក់ស្ដែង ហើយបានកែច្នៃតម្រូវទៅតាមចំណង់ចិត្តនៃអ្នកសម្ដែង។ សួរថាតើខ្នុកហេតុអ្វីបានជាទៅដេរ សំលៀកបំពាក់ទៅវិញយើងម៉េចមិនប្រគល់ឲ្យទៅផ្នែកដេប៉ាក់ យើងនិងឆ្លើយដោយពុំបាច់ឆ្ងល់ថាផ្នែកខ្នុកក៏ត្រូវចេះដេរ ចេះប៉ាក់ ចេះគូរ ចេះឆ្លាក់ដូចផ្នែកដទៃទៀតដែលព្រោះផ្នែកនេះធំទូលាយជាងផ្នែកដទៃ។ ហើយជាផ្នែកដែលសិល្បរបាំ សិល្បល្ខោនត្រូវការវាចាំបាច់បំផុតបាត់មិនបាន អាស្រ័យហេតុនេះជាងត្រូវតែចេះគ្រប់មុខវិជ្ជទាំងអស់មិនប្រកាន់តែខ្នុក

តោកខ្នុករូបស្នាច់នេះទោះជាមានតុ ទូ កៅអី ក្តា បង្អួច ខ្នុកធ្វើបានតាមត្រូវការជូនគ្មានទាស់ត្រង់ណាឡើយ។

ប៉ុន្តែខ្នុកទាមទារចាំបាច់បំផុតនូវវត្ថុធាតុដើមសំខាន់ នៅក្នុងស្រុកដោយពុំចាំបាច់វត្ថុធាតុបរទេសឡើយ។

ដើម្បីកុំឲ្យវែងឆ្ងាយចាកប្រធានយើងសូមនិយាយតែពីសំលៀកបំពាក់ប៉ុណ្ណោះ ដើម្បីជាកញ្ចក់ដល់អ្នកសិក្សាក្រោយទៀតថាយល់កាន់តែច្បាស់ពីមុខវិជ្ជាសំលៀកបំពាក់ និងខ្នុកតោករបស់យើង។

## ក្បាច់

ក្នុងការលម្អក្បាច់គេមិនយកក្បាច់អង្គរមកលម្អ គឺច្រើនយកក្បាច់ភ្ញីទេសជូនមានរាងជាចាក់ចន្ទន៍ ជួនមានរាងក្បាច់ជួនប្រែប្រួលបានដូចជា ហនុមានគេគូរក្បាច់ជាក្រយៅបក្សភ្ញីទេសរាងចាក់ ព្រះរាមភ្ញីទេសសន្ទឹកត្រួតលើគ្នាជាដើម។

## ពណ៌សំលៀកបំពាក់

សំលៀកបំពាក់របស់តួអង្គនៃរឿងយើងបានឃើញមកហើយថា ព្រះរាមមុខខៀវ ដូច្នេះ សំលៀកបំពាក់ត្រូវរំលេចពណ៌ខៀវទៅតាមមុខដែរ៖

- ហនុមានពណ៌សយើងធ្វើសំលៀកបំពាក់ពណ៌ស
- យក្សពណ៌ខ្មៅឬខៀវសំលៀកបំពាក់ពណ៌ក៏ខ្មៅឬខៀវដែរ។

ដូចគ្នាខ្លះត្រង់ខុនណាងដែលមានជ័រដើងពណ៌លឿងហើយក្បាច់ជូនគូពណ៌ ជូនប៉ាក់ឱនចំណែករជ្ជសាអេរ ស្រង់ករគឺមានពណ៌ ដើងពណ៌លឿងដូចគ្នា រីឯពណ៌ស្តានគឺរត់ទៅតាមលំនាំនៃតួនីមួយៗ។

ចំពោះក្បាច់គេច្រើនប៉ាក់ឱនជាក្បាច់រំលេចជាក្រយៅ ជាភ្ញីទេស ជាចាក់ចន្ទន៍ទៅតាមនេះ។

## *ការវិវឌ្ឍនខ្នុក*

*ពីជំនាន់មួយមកជំនាន់មួយ បញ្ហាវិជ្ជាខ្នុកដែលមានកម្រិតដល់កំពូលទៅសម័យរុងរឿងរបស់ខ្មែរ គេសង្កេតឃើញខ្នុកមានច្រើនឥតគណនាធ្វើពីមាសផង កញ្ចក់ផង (ពីមាសដាំកញ្ចក់) ជួនជាស្បែកផ្តៅ សំបកសត្វដូចជាគ្រុំ ខ្យងជាដើម។ ជួនកាលទៀតគេយកស្នែងសត្វ សំបកស៊ុត ដូចជាសំបកពងមាន់ពងទាជាដើមមកធ្វើការលម្អ។ ភស្តុតាងប៉ុន្មានមកខ្វះនៅទល់សព្វថ្ងៃ ខ្វះរលាយបាត់ស្រមោល មានតែនៅក្នុងផ្នត់គំនិត និងខួរក្បាលខ្មែរមួយភាគខ្វះតែប៉ុណ្ណោះ ឥឡូវនៅសល់តែម្នាក់គត់ គឺលោកសាស្ត្រាចារ្យ (អ.សុខ)។*

*គេហ្នឹងនិយាយដោយគ្មានទើសទាល់ពីបញ្ហា ដែលធ្វើឲ្យខ្នុកចេះតែជួបការពិបាក។ យើងក៏ដឹងដែរថា តើប្រទេសយើងជួបនិងការពិបាកប៉ុន្មានជំនាន់មកហើយៗជំនាន់មួយៗជំនាន់ណាខ្លាំងជាងគេ? ដូចជាជំនាន់នៅទួលប្រាក់ដួង ជំនាន់អណានិគមនិយមក្រុងឧត្តង្គ អាណានិគមនិយមក្រុងអង្គរដែលមានថៃជាអ្នកកាន់ អណានិគមនិយមក្រុងចតុមុខដែលមានបារាំងជាអាណាព្យាបាលសម័យចក្រពត្តិអាមេរិច រហូតដល់សម័យវិនាសខ្ទេចខ្ទីនៃវប្បធម៌ និងជីវិតប្រជាជនគឺប៉ុលពតសត្រូវចុងក្រោយនៃមាតុភូមិ រឿងអីមិនវិនាសបើបញ្ញាជនកំពូលៗត្រូវដេកក្នុងផ្នុកឈាម សេដ្ឋកិច្ចត្រូវធ្លាក់ចុះក្រោមសូន្យអ្វីៗទាំងអស់វាក៏ត្រូវបាត់ដែរ បាត់រហូតគ្មានដំណឹងឬយ៉ាងណា? យើងសូមចោទសួរហើយសួរទៀតចំពោះបញ្ហាក្នុងកូនខ្មែរ ដែលជាអ្នកបន្តវេនបដិវត្ត តើអ្នកត្រូវធ្វើអ្វី? មានតែបាតដៃទទេគ្មានអ្វីទាំងអស់ តើគេអាចធ្វើបានឬទេ? គឺពិតជាធ្វើបាន ធ្វើដោយឆន្ទះជាខ្មែរក្នុងការរកឲ្យឃើញពីបញ្ហាខ្នុកបូរាណនេះ ដែលកប់ចោលច្រើនឆ្នាំត្រូវកកាយយកមកវិញហើយ។ យើងសូមធ្វើការរំលឹកខ្វះៗពីរបៀបនឹងរូបរាងខ្នុកពីបូរាណ ដើម្បីប្រៀបធៀបមកខ្នុកសម័យតើមានការប្លែកគ្នាត្រង់ណាដែរ?*

*ពីសង្គមមុនខ្នុកមានកន្ទែងខ្វះ គេយកស្បែកសត្វកាត់ជារូបរាងរួចលាបជ័រម្រក៍តែម្តង ដូចជាក្បាំងអប្សារា ច្រចៀកស្វា យក្សនិងពេជន៍ជុំវិញសុទ្ធតែធ្វើអំពីស្បែកសត្វ ការប្រើថ្នាំជក់តឡើងដោយម្សៅហុងតែល ឬលក្ខណពណ៌គេសង្កេតឃើញមានការស្នាប់ម៉ត់ចត់ហើយល្អទៀតផង រីឯតោកក៏មានច្រើនឥតកំណត់ហេតុនេះហើយមាននៅសល់ដល់សព្វថ្ងៃដូចជាតោកដាំកញ្ចក់ ដាំខ្យង ដាំម្រក័ជាដើម រីឯរូបយក្សស្វាដែលធ្វើពីមាសសន្ទឹកគេ*

សង្កេតឃើញមាននៅវិហារព្រះកែវមរកតមានមួយជាគម្រូស្រាប់។ ពីមុនគេធ្វើចង្កូមយក្ស ដោយយកធ្មឹងសត្វមកបិទ ឬយកល្ពៅក៏មានដែរ មានការវិវឌ្ឍនខ្លះទៀតត្រង់ត្រចៀកយក្ស និងស្វា និងចញ្ចើមហើយក្នុងការកាត់សរសៃរក៏មានការប្រែកខ្លះដែរដូចជាៈ

ការវិវឌ្ឍនត្រង់ពីបូរាណគេតែងធ្វើរូបយក្ស ស្វាដោយដាំជាកញ្ចក់ ឬម្រក្បុំខ្មុក ហើយរូបរាងក៏មានការប្រែកគ្នាច្រើនណាស់ដែរ។

បច្ចុប្បន្នយើងធ្វើខ្នុកដោយមិនបានដាំកញ្ចក់ដូនកាលទៀត យើងគ្រាន់តែស្នាច់លាបថ្នាំតែប៉ុណ្ណោះទម្រង់និងបូរាណរាងមានប្រែកគ្នាខ្លះ។

សរុបសេចក្តីមក យើងបានដឹងថាការវិវឌ្ឍននៃវិជ្ជាខ្នុកមកដល់បច្ចុប្បន្នមានការចុះអន់ថយសំបើមណាស់នៅសម័យនេះដោយផ្អែកទៅលើវត្ថុធាតុដើមដែលមានតម្លៃខ្ពស់មួយទៀតដោយសេដ្ឋកិច្ច ក្នុងប្រទេសនៅទាបនៅឡើយទើបបណ្តោយឲ្យសិល្បធ្លាក់ដល់កម្រិត ប៉ុន្តែដោយការខិតខំស្រាវជ្រាវឡើងវិញពីសំណាក់សាស្ត្រាចារ្យ និងលោកគ្រូអ្នកគ្រូទើបដំណើរការមុខវិជ្ជាខ្នុកមានសោភ័ណ្ឌបន្តិចឡើងវិញក្នុងសាច់ឈាមសិល្ប។ យើងយល់ថាបើសិនជាជំនាន់ក្រោយទៀតពុំបានខិតខំស្រាវជ្រាវអំពីវិជ្ជាខ្នុកនេះបានស៊ីជម្រៅទេ នោះវិជ្ជាដ៏មានតម្លៃស្មើមាស និងរលាយរូបរាងបន្តិចម្តងៗទៅផង តែបើយើងកុំប្រទ្បំថាវិជ្ជាខ្នុកជាវិជ្ជាគ្មានតម្លៃនោះទើបយើងខិតជិតវា និងបានភ្ញីភ្នែកពីវិជ្ជានេះជាមិនខាន។ តើវាមានសារសំខាន់យ៉ាងណា?

ចំពោះវិជ្ជាខ្នុក បើធ្វើការសិក្សាស្រាវជ្រាវបន្តទៅទៀតទៅមានច្រើនណាស់សម្រាប់អ្នកសិក្សា អំពីវិជ្ជាខ្នុកដ៏មានអត្ថប្រយោជន៍ដល់អ្នកហើយៗជាវិជ្ជាខ្លាំងជាងគេក្នុងចំណោមវិជ្ជាសូនរូបទាំងឡាយ ចូលយើងឈប់ប្រទ្បំទៀតទៅហើយនាំគ្នាក្រឡេកមើលឲ្យស៊ីជម្រៅឡើង។

យើងមិនចង់និយាយទេចំពោះរឿងទាំងឡាយ ដែលបច្ចុប្បន្ននេះខ្មែរជាអ្នកបង្កើតសិល្បពុំដឹងថាសិល្បខ្លួនមានអត្ថប្រយោជន៍ប៉ុណ្ណាផង រួចគេថែមទាំងពុំដឹងថាវិជ្ជាខ្នុកគេសិក្សាអំពីអ្វី? ដើម្បីអ្វី? ហើយខ្នុកនេះទៀតសោត តើរបៀបណាខ្លះដែរ ជាប្រជាជននៅខាងក្រៅសប្បាចុះពុំសូវដឹងពុំឃើញ ចុះអ្នកនៅក្នុងសិល្ប នាំសិល្បពាក់រូបខ្នុកកាន់មើលខ្នុក មួយទៀតក៏ជាអ្នកសូនរូបនេះតែម្តងដែរមិនយល់ជាងអ្នកសិល្បដទៃទៀតទៅដែរ។

ហាក់ដូចជាពុំបានរិះគិតដល់បញ្ហានេះ។ បើសិនយល់ក៏មិនយល់ចុះថែមទាំងពេបមាត់រិះគន់ខ្នុកថាជាវិជ្ជាស្រាលបំផុតសម្រាប់គេ តើវិជ្ជានេះស្រាលដែរឬទេ? ទុកសម្រាប់អ្នកបកស្រាយតាមមាត់ម្នាក់ៗ។

យើងគ្រាន់តែនិយាយឯកសារ ដែរសរសេរយ៉ាងច្រើនសន្ធឹកមកក៏វាអាចបញ្ជាក់បានខ្លះដែរចំពោះអ្នកសិក្សា។

តោងយល់ថាយើងជាខ្មែរតោងយល់ពីតម្លៃសិល្បខ្លួនថា តើសិល្បនៃជាតិនិមួយៗមានយ៉ាងដូច្នេះជាពិសេសសិល្បជាតិខ្លួននេះតែម្ដង។

## ខ្នុកសម័យ

យើងបានបញ្ជាក់ខ្លះៗរួចមកហើយ ចំពោះវិជ្ជាខ្នុកដែលមានច្រើនឥតគណនាដូចជានៅសម័យបូរាណសូម្បីតែធុងទឹក កញ្ជើ ល្អី តុ ទូ កៅអី ជញ្ជាំង ក្ដា ថាស ស្ទាបព្រា ចាន ដង  កណ្ដៀវ។ល។

និយាយឲ្យអស់ទៅឲ្យតែសម្ភារប្រើប្រាស់ចាស់ៗ សម័យដើមសុទ្ធតែដាំខ្នុកទាំងអស់ ដូចយើងបានឃើញខ្លះៗហើយនៅសារមន្ទីជាតិភ្នំពេញ ឬក៏នៅព្រះវិហារព្រះកែវមរកតជាដើម។ អីលូវមកដល់នេះយើងក៏ឃើញមានខ្នុកមួយទៀតដែរមានឈ្មោះជាខ្នុកទំនើប តើវាមានសារៈសំខាន់យ៉ាងណាដែរ?

តាមពិតខ្នុកទំនើបមានជាយូរណាស់មកហើយ គ្រាន់តែវាពុំទាន់សុក្រិតនៅឡើយរហូតមកដល់សម័យជឿនលឿន ដោយមានអរិយធម៌ហូរចូលមកពីប្រទេសនានាដូចជាជប៉ុន អ៊ីតាលី អូស្ត្រាលី ចិន វៀតណាមផងទើបគេសង្កេតឃើញសិល្បខ្មែរមានលំនាំមួយទៀតគឺ (លាក់ការ) បែបខ្នុកសម័យនេះតែម្ដង។ តាមការសិក្សាយើងពុំដឹងវាមានប្រភពមកពីណាទេ ត្រង់ខ្នុកសម័យនេះ តាមការសន្និដ្ឋានខ្លះយើងអាចបញ្ជាក់ថាពិតជាមានប្រភពមកពីការផ្ទេងអរិយធម៌ទៅវិញទៅមកពីពួកបូព៌ាប្រទេស ជាមិនខាន ជាពិសេសប្រទេសចិនតែម្ដង ព្រោះអីកាលពីសម័យហ្វូនន់ ប្រទេសកម្ពុជាមានទំនាក់ទំនងយ៉ាងច្បាស់ក្រឡែតជាមួយប្រទេសចិន ទើបបណ្ដោយឲ្យមានឥទ្ធិពលចិនក្នុងប្រទេសបែបនេះ។

ប្រភេទ

ខ្មុកសម័យចែកចេញជាប្រភេទផ្សេងៗណាស់ ហើយមានតម្លៃថោកជាងខ្មុកបូរាណ និងប្រើរយៈពេលឆាប់ជាងខ្មុកបូរាណទៀតផង។ ខ្មុកនេះអាចយកទៅប្រើការបានគ្រប់កន្លែង ដូចជាធ្វើនៅលើ តុ ទូ កៅអី ជញ្ជាំង ស្លាបព្រា ចានៗលៗ រហូតដល់ធ្វើនៅលើសសរព្រះវិហាធំៗទៀតផង។ សំខាន់គឺ មាននៅតាមសម្ភារប្រើប្រាស់របស់ប្រជាជនតាំងពីសម្ភារតូចតាច កំប៉ិចកំប៉ុកឡើង។ អាស្រ័យហេតុនេះហើយបានជាយើងឃើញខ្មុកមានច្រើនសប្បូរបែបជាង សិល្បផងទាំងឡាយដែលគេបានជួបប្រទះរួចហើយ។

បច្ចេកទេសខ្មុកលើក្ដាបន្ទះ

បច្ចេកទេសនោះបើយើងប្រៀបធៀបទៅនិងប្រទេសជប៉ុន យើងនៅខ្វះលក្ខណៈខ្វះដែល ផ្អែកទៅលើវត្ថុធាតុដើម។ នៅជប៉ុនគេយកស្បែកមកក្រាលមួយជាន់រួចហើយគេចេះតែលាបម៉ាស់ស្ដិចមួយជាន់ហើយមួយជាន់ទៀត រហូតដល់ទៅស្មើស្អាត ទើបគេចាប់ ផ្តើមគូសម៉ាស់ស្ដិចលុះដល់ស្ងួតស្រួលបួលហើយទើបខាត់ និងទឹកការខាត់ត្រូវយកឈើមួយបន្ទះប៉ុនបាតដៃរុំក្រដាស់ខាត់ គេចេះតែខាត់គ្មានបន្ធូរហូតដល់ផ្ទៃក្ដាស្មើដូច ផ្ទែកញ្ចក់អាចឆ្លុះមុខបានហើយគេចាប់លាបម្រក្ស័ ឬថ្នាំម្យ៉ាងរបស់គេតែម្ដងមួយជាន់ ឬពីជាន់ទៀតរួចខាត់ទៀតតែត្រូវយកក្រដាស់ខាត់ទឹកធុងលេខ០១ឬលេខ០២ រហូតដល់ស្អាតស្មើទើបចាប់ប៉ូលាដែលមានថ្នាំវាសម្រាប់ប៉ូលាស្រាប់ ការប៉ូលាគឺគេចេះតែប៉ូលាទៅកុំបន្ធូមួយៗរហូតដល់ទៅភ្លឺរលោងទើបគេគូរ ការគូរចង់គូរជាគំនូរវិចិត្រសម័យថ្មីក៏បាន បូរាណក៏បានប៉ុន្ដែមិនជាវិចិត្រកម្មពេកទេគឺរបៀបលម្អក្រណាត់ ដែរគេប្រើពណ៌ប្រដេញផ្សំគ្នាទៅតាមលំនាំបច្ចេកទេសរបស់ខ្លួន។ លុះគូររួចបើចង់កុំឲ្យមានភាពគគ្រើងគគ្រើម តើគេត្រូវធ្វើដូច ម្តេច? គឺគេត្រូវលាបហ្វាក់ទី ដោយជ្រើសរើសធុងលេខ០១ទើបឆាប់ស្ងួតវិធីលាបហ្វាក់ទី គឺកុំជ្រលក់ជក់ទៅក្នុងថ្នាំទាំងអស់ពេក គឺគេជ្រលក់ពាក់កណ្ដាល ហើយលាបមួយដងមួយដងកុំលាបជាន់គ្នាច្រំដែរៗនាំឲ្យខូចខាតទាំងក្ដាខូចទាំងរូបភាពដែលគូររួច លុះស្ងួតសឹមលាបទៀតបានលាបបីបួនជាន់ហើយទើបយើងយកសាំក្រអូបចាក់លាយជាមួយទៀនសយកមកខាត់បណ្ដើរៗ ហើយបន្ថែមបន្តិចជាមួយនិងក្រដាស់ស លុះត្រាតែរលោង ភ្លឺល្អស្អាតទើបសម្រេចជារួចហើយ។

## បច្ចេកទេសលើថូ

នៅលើថូ គេពុំចាំបាច់កោសម៉ាស់ស៊ីចពីរលើវាទេ គឺគេលាបថូយកតែម្ដង បន្ទាប់ពីក្រឡឹងរួចយើងខាត់យ៉ាងស្អាត ទើបយកម៉ាស់ស៊ីចមកលាបពីរលើថូ ម៉ាស់ស៊ីចយើងលាយជាមួយម្រក្សមៅ ឬជ័រខ្មែរលាយជាមួយសាំងក្រអូប។ លុះលាបបានពីរបីជាន់រួចមកយើងចាប់ខាត់វា និងក្រដាស់ខាត់លេខ 0.2 (ខាត់ជាមួយទឹក) បន្ទាប់មកយើងខាត់វានិងក្រដាស់ខាត់លេខ 0.1 ម៉ត់បំផុត។ លុះស្មើស្អាតយើងចាប់បូណ និងលាយជាទៀនសបូកសាំងក្រអូប ឬប្រើថ្នាំ បូណក៏បាន។ សូមបញ្ជាក់ថាបើយើងខាតនៅមានឃើញសាច់លើទេ នោះត្រូវលាបបន្តរប្រយ័ត្នត្រូវឲ្យស្មើដៃកុំលាបច្រំដែលៗនាំឲ្យខូច។ បូណរួចយើងចាប់ ផ្ដើមគូរដាក់ពណ៌។

បច្ចេកទេសនេះមិនត្រឹមតែអនុវត្តនៅលើថូមួយមុខនោះទេ ទោះជានៅលើសម្ភារអ្វីក៏ដោយក៏គេប្រើបច្ចេកទេសនេះដែរ ដូចជានៅលើកំរបដែកកេស ស្នូកអណ្ដើក កន្ទៀ លើស្នែនសត្វ លើក្រាស់ លើសំបកខ្យង ក៏គេត្រូវប្រើវិធីបូណ និងខ្នុកម្រក្សដូចនេះដែរ។

## របៀបខាត់

បញ្ជាក់ថាគេត្រូវខាត់ដូចជាខាត់នៅលើឈើរនេះពេលខាត់យើងមានកៅស៊ូប្រវែង 10cm X 3cm វាងសំប៉ែតយកមករុំដោយក្រដាស់ខាត់ ដាក់ជ្រលក់ក្នុងទឹករួចទើបខាត់ (ខាត់ទឹក) ការខាត់ជៀសវាងការខាត់បង្ខំ ឬខាត់គ្មានការប្រុងប្រយ័ត្ន គឺត្រូវខាត់មួយៗវែងៗស្រាលដៃកុំសង្កត់ រហូតដល់បានស្មើសព្វកន្លែងទើបបញ្ជាក់ថារួចហើយ។

## គូរ

គូរលើថូគេគូរបៀបលម្អពណ៌ មិនគូរដូចគំនូរវិចិត្រកម្មទេ (ដូចនៅលើខ្នុកក្ដា) គឺគូរដោយយកពណ៌ជិតល្អមករៀបចំ ជួនគេប្រើពណ៌ប្រដេញទៅពណ៌ឋាន ជួនគេផ្ដាច់ចេញប៉ុន្តែក្នុងបួងលម្អដដែរ ជួនកាលគេបញ្ចេញជារូបបន្តិចបន្តួចទៅតាមការគិតរបស់សិល្បករ។ ជួនខ្លះគេពុំគូរទេ គេប្រើវិធីដាំសំបកខ្យង សំបកពងមាន់ ជារូបផ្សេងៗខ្លះដាក់កញ្ចក់ក៏មានចំពោះថូបូរាណខ្មែរគេពុំគូទេ គឺគេប្រើខ្នុកក្បាច់មកបិទបន្ថែមនៅលើថូ ជួនគេ

ធ្លាក់លង្កិនមកបិទ គេសង្កេតឃើញមានគំនូនៅលាក់ទំនើបទើបតែមាននៅស.តទី ២០ នេះហើយ (ក្នុងអតីតវាំង) ដែលស្តីអំពីទុំលើតោកនេះជាខ្នុកសម័យមួយដែលមានការជឿនលឿនខាងអរិយធម៌ រីឯលាក់សម័យដទៃទៀតនៅរបៀបបូរាណខ្មែរនិយមដាំ ឬបញ្ចុះសំបកសត្វមានខ្យង ពងមាន់ ឬកញ្ចក់ ឬក៏គូររបៀបគំនូបូរាណនៅលើក្បាលយកតែម្តងជួនកាលគេជាក្បាច់ភ្ញីទេស ជាក្បាច់អង្គរ រំលេចចរនាសម្ព័ន្ធក្បាច់យ៉ាងវិចិត្រជួនគេពុំគូរអ្វីទេ គឺលាតយកតែម្តង។

គេឃើញមាននៅតាមស៊ុំកញ្ចក់ ក្នុងអតីតវាំងដែលលាក់បង្កប់ទៅដោយជាតិស្នែងឬក្អុកដំរីរបៀបតោកបញ្ចុះខ្យង ប៉ុន្តែគ្រាន់តែលាក់មានលក្ខណស្រស់ស្អាតខ្នុកលើតោកចំពោះបច្ចេកទេសនៃលាក់បង្កក់ក្អុកដំរីមិនខុសគ្នា និងខ្នុកតោកប៉ុន្មានទេ គឺថារបៀបបញ្ចុះមានលក្ខណដូចគ្នាគេដុតដែកកម្តៅជ័រឲ្យរលាយ ហើយទើបបញ្ចុះរួចខាត់និងទឹកឬក៏ខាត់ផេះខុសគ្នាត្រង់លក្ខណរៀបចំធ្វើលាក់និងខ្នុក។ បច្ចេកទេសធ្វើលាក់មានដូចរៀប រាប់រួចហើយ គឺខុសពីការស្ងួរជ័រធ្វើខ្នុក ធ្វើតោកឆ្ងាយណាស់។

ដោយលាក់យើងធ្វើពុំទាន់បាន ដូច្នេះយើងសូមបិទរូបលាក់ធ្វើនៅសូវៀតជាគំរូព្រោះ លាក់យើងក៏ធ្វើដូចគ្នានិងលាក់នៅសូវៀតដែរគ្រាន់តែលក្ខណលម្អមានការខុសគ្នាបន្តិត បន្តួចប៉ុណ្ណោះ។ ចំណែកបច្ចេកទេស គឺមានលក្ខណដូចគ្នាទាំងការរៀបចំប្លង់ និងការធ្វើគ្រឿងសម្ភារបរិក្ខាសព្វបែបយ៉ាងដូចគ្នា គ្រាន់តែក្បាច់ពុំដូចគ្នាពណ៌ពុំដូចគ្នា និងការរៀបចំពណ៌ពុំដូចគ្នាដូច្នេះ យើងអាចយកលក្ខណខ្លះជាគំរូបាន។

បច្ចេកទេសខ្នុកលក់នៅសូវៀត។ លាក់ខ្មែរចូលចិត្តពណ៌ធ្ងន់ជាងនេះហើយមានលក្ខណស្របទៅនិងធម្មជាតិ ស្រុកទេសទៀតផង ដូចជាលាក់សូវៀតនេះគេគូរទៅតាមលក្ខណធម្មជាតិស្រុករបស់គេ ចំពោះខ្មែរគូរក្បាច់បូរាណខ្មែរ ឬក៏គូរទៅតាមលំនាំខ្មែរដែលចង់បានតែម្តង។ ប៉ុន្តែមានលក្ខណប្រើទឹកមាសដូចគ្នា គ្រាន់តែខ្មែរពុំសូវប្រើច្រើនដូច្នេះពេកទេ ឬក៏ដាក់ពណ៌ដល់ទៅក្រហមថើរដូចសូវៀតពេកក៏មិនមែនដែរ យើងប្រើពណ៌ដូចនេះមែនតែធ្ងន់។

មានលក្ខណខ្លះប្រហាក់ប្រហែលខ្មែរដូច្នេះ យើងអាចយកជាគំរូបានដើម្បីសិក្សាទៅមុខទៀត។

រូបនេះគ្រាន់តែជាមូលដ្ឋានរបស់យើងតែប៉ុណ្ណោះ។ តែបើនិយាយពីរបៀបធ្វើនិងការរចនាជាក្បាច់ជារូបភាពមិនខុសគ្នា ប៉ុន្មានទេគឺយើងធ្វើការរៀបលម្អពណ៌ដូចគ្នា។

## ប្រៀបធៀបខ្នុកបុរាណ សម័យ

រហូតមកដល់ត្រឹមនេះ យើងបានដឹងសព្វគ្រប់អំពីវិជ្ជាមូលដ្ឋាននៃបច្ចេកទេសខ្នុកទាំងបុរាណទាំងសម័យ។ ចុះអីលូវយើងសាកល្បងប្រៀបធៀបសិល្បទាំងពីរនេះម្តងថាតើវាមានលក្ខណវិវឌ្ឍនរីកលូតលាស់យ៉ាងណាទៅវិញ

ពីបុរាណកាលមកខ្មែរនិយមធ្វើសម្ភារអ្វីៗទាំងអស់សុទ្ធតែធ្វើឡើងពីខ្នុកដូច ធុងទឹក ចាន កណ្តៀវ ចង្កេ កញ្ជើរហូតខ្នុកគោកដែលជាសិល្បអស្ចារ្យរបស់ខ្មែរ មិនតែប៉ុណ្ណោះខ្មែរបានប្រើម្រក្បុំឡៅខ្នុកនៅតាមជញ្ជាំងប្រាសាទ អាគារសំណាក់ ដោយរំលេចក្បាច់លម្អផូរផង់ និងមានរូបភាពសំបើមអស្ចារ្យ សឹងលែងជឿរថាមនុស្សអ្នកធ្វើឡើយ។ សិល្បមាននៅតាមប្រជាជនដូចជាគេយកម្រក្បុំមកលាបកញ្ជើរ ល្អី បង្គី ចង្កេ និងទូរទេះកណ្តៀវជាដើមសុទ្ធតែធ្លាក់ទៅដោយក្បាច់ភ្ញីដ៏វិចិត្រ។

ចំណែកនៅក្នុងសិល្បៈវិញ គេឃើញសិល្បករច្នៃរូបភាពក្នុងរឿងរាមកេរ្តិ៍ខ្មែរមកស្វរកែច្នៃធ្វើជារូបពិតដាំខ្នុកបញ្ចុះកញ្ចក់ បិទមាសសន្ទឹកភ្ញីប្រដេញ និងពន្លឺភ្លើងចន្ទុះគួរឲ្យចង់គយគន់។ ទាំងអស់នេះសុទ្ធសឹងតែជាស្នាដៃដ៏វិចិត្ររបស់សិល្បករខ្មែរ។

រហូតមកទល់ពេលនេះយើងឃើញមានសិល្បមួយទៀតគឺទំនើបជាងមុន គេធ្វើវានៅលើក្តាបន្ទះនៅលើសំបកសត្វ នៅលើស្នែងនៅថូផ្កានៅលើកៅអីជាដើមដូនគេឃើញវាមានដាំខ្សង ដាំក្អុក ដាំស្នែង ឬគូរជាគំនូរវិចិត្រកម្មរំលេចចេញជារូបភាពស្តីអំពីជីវិតរស់នៅបច្ចុប្បន្នកាល និងក្នុងអតីតកាល។ សិល្បនេះយើងឲ្យឈ្មោះថាសិល្បខ្នុកទំនើប។

សិល្បទាំងពីរមានលក្ខណល្អវិចិត្រដូចគ្នាទាំងការតុបតែងទាំងការរៀបចំ។ ប៉ុន្តែបើយើងរិះគិតបន្តិចទៅយើងនឹងដឹងថាសិល្បដែលជឿនលឿនជាងគេនេះ គឺខ្នុកសម័យព្រោះវាមានតម្លៃថោក ហើយប្រើរយៈឆាប់រហ័សជាងខ្នុកបុរាណដែលប្រើពេលពីមួយឆ្នាំទៅមួយឆ្នាំក្នុងការផលិតគោកមួយ។ ខ្នុកសម័យពុំបានរើសខ្លួនជាស្តេចដូចខ្នុកបុរាណទេវាអាចបម្រើដោយគ្មានទើសទាស់ទាំងប្រជាជនសាមញ្ញតូចតាច កសិករ កម្មករ បញ្ញវន្តក៏

អាចប្រើប្រាស់វាបានតាមចិត្ត និងសេចក្តីត្រូវការដែរ។ គ្រប់សម្ភារប្រើប្រាស់ទាំងអស់ខ្មុក សម័យបានប្រើសិល្បរបស់ខ្លួនគូរវាស់នៅជញ្ជាំងក្តារនៅលើតុ ទូ កៅអី ព្រមទាំងសម្ភារតូចតាចដូចជាក្រាស់សិតសក់ ដែកកេស ឃ្នាបសក់ជាដើមឡើងទៅ ចុះខ្មុកបូរាណវិញៗ វាធ្វើបានតែចំពោះវណ្ណស្តេច មន្ត្រី ព្រោះថាត្រូវការសម្ភារច្រើនឥតគណនា ហើយមានរយៈពេលយូរ ដូច្នេះហើយទើបគេឃើញមានខ្មុកបូរាណនៅតែជាមួយស្តេចសំបូរហូរហារពាស់ពេញក្នុងព្រះរាជវាំងស្តេច គ្រប់កន្លែងនៃស្តេចគង់នៅខ្មុកបូរាណមាននៅទីនោះដែរ។

បច្ចុប្បន្នយើងខ្ញុំទាញខ្មុកបូរាណឲ្យចុះទាបមកវិញមានតម្លៃមធ្យមដើម្បីសេចក្តីត្រូវការរបស់ប្រជាជនប៉ុន្តែស្រុកទេសពុំបានផ្តល់លទ្ធភាពឲ្យយើងផលិតវាបានឡើយ ព្រោះខ្មុកបូរាណត្រូវការចាំបាច់នូវសម្ភារក្នុងស្រុកដូចជា ជ័រម្រក្ស័ ជ័រចុង ជ័រទឹកជាដើម សុទ្ធតែដុះក្នុងព្រៃធំៗឯណោះៗ រីឯខ្មុកសម័យយើងក៏កំពង់ដំណើរការបណ្តើរទៅមុខដែរដោយផ្អែកលើវត្ថុធាតុដើមឯបរទេស។

សរុបសេចក្តីមកសិល្បដែលចម្រើនជឿនលឿនជាងគេគឺ សិល្បខ្មុកសម័យនេះដែលបានផ្សាយខ្លួនវាទៅនិងមជ្ឈដ្ឋានរស់នៅរបស់ប្រជាជន វាបម្រើបានដោយគ្មានទាល់នូវសម្ភារប្រើប្រាស់ក៏ដូចខាងស្មារតី នយោបាយដែរវាបានរួមចំណែកផ្សាយនយោបាយមនោគមវិជ្ជារបស់ខ្លួនទៅតាមផ្ទាំងគំនូររស់រវើករបស់ផ្ទាំងវិចិត្រករនាក់ ដែលគូសវាស់នៅលើក្តាខ្មុកល្អវិចិត្រនៅតាមថូផ្កាក៏មានរូបភាពអស្ចារ្យគួរគយគន់ពន់ប្រមាណដែរ។

ប៉ុន្តែយើងមិនថាខ្មុកបូរាណឥតប្រយោជន៍ទេៗ ខ្មុកបូរាណជាខ្មុកដែលបញ្ជាក់ពីផ្នត់គំនិតប៉ិនប្រសប់របស់ខ្មែរ ពីការអំណត់អត់ធ្មត់របស់ខ្មែរពីទេពកោសលរបស់ខ្មែរ ពីអរិយធម៌រុងរឿងរបស់ខ្មែរវាបញ្ជាក់ពីព្រលឹងរបស់ជាតិ វាជាអាយុជីវិតរបស់អរិយធម៌ខ្មែរទើបយើងខំសង្កេតមើលវាយូទៅយើងនឹងឃើញពីជីវភាពរស់រវើករបស់ខ្មែរជំនាន់ដើម វានឹងឲ្យយើងឃើញពីការសប្បាយរីករាយរបស់ខ្មែរដើម និងឲ្យយើងឃើញផ្នត់គំនិតរបស់ខ្មែរដើម។ ដូចយើងបានឃើញហើយសិល្បខ្មុកគ្រប់ប្រភេទលើលោក គ្មានសិល្បខ្មុកដូចសិល្បខ្មែរឡើយ ទោះបីជាថៃដែលមានខ្មុក ដូចគ្នាក៏មិនងាយធ្វើខ្មុកតោកខ្មុកក្បាលដូចខ្មែរ នេះជាលក្ខណពិសេសមួយរបស់ខ្មុកក្នុងសញ្ញាណនៃផ្នត់គំនិតខ្មែរដើម។

ចុះបើយើងប្រៀបធៀបខ្នុកបូរាណមកសម័យនេះគឺខុសគ្នាឆ្ងាយណាស់។ បច្ចុប្បន្ននេះយើងមិនហៅថាខ្នុកទេ គឺជាស្នាច់ដូចបានបញ្ជាក់នៅទំព័រមុនរួចហើយខ្នុកផ្សេងស្នាច់ផ្សេង។ ដោយស្រុកទេសពុំទាន់មានលទ្ធភាព ទើបយើងយកមុខវិជ្ជាស្នាច់នេះមកសិក្សាបណ្ដើរៗទំរាំមានវត្ថុធាតុដើមទើបយើងចាប់ផលិតខ្នុកបូរាណរបស់យើង។

## *អវសានបទ*

ស្ដាយណាស់ដោយពេលវេលាមានរយៈពេលខ្លីពេកយើងពុំបានរៀបរៀងឲ្យបានក្បោះក្បាយល្អជូនប្អូនៗឡើយ ដូច្នេះដើម្បីឲ្យតម្លៃសិល្បរបស់យើងកាន់តែមានសម្រស់ស្រស់ទៅមុខទៀតសូមប្អូន បង និងបណ្ដាមិត្តទាំងអស់ជួយកែលម្អត្រង់ចន្លោះខ្វះៗក្នុងសៀវភៅរបស់ខ្ញុំដើម្បីស្វែងរកការរីកចម្រើនក្នុងសិល្បៈខ្មែរ។

ដោយរយៈពេលសិក្សារបស់ខ្ញុំមានការឆាប់រហ័សប្រាំឆ្នាំ យើងសិក្សាបានតែឯកទេសស្នាច់តែប៉ុណ្ណោះ ប៉ុន្តែដោយឆន្ទះជាកូនចៅនៃអ្នកសិល្បយើងឈោងចាប់បាននូវអ្វីដែលចង់បានរួមផ្សំ និងការប្រតិបត្តិព្យាយាមសំគីតាមទ្រឹស្ដី សុជីសាពុលកៈរបស់អង្គព្រះពុទ្ធ ទស្សនវិជ្ជាមនោគមសាសនាកំពូល និងរួមជាមួយទស្សនមនោគមវិជ្ជាម៉ាក្សទៀតផងយើងចាប់បាននូវចំណេះយ៉ាងសំខាន់ៗដូចជាខ្នុកបូរាណ ខ្នុកសម័យដោយពិបាកធ្វើទាំងអស់នោះជាខ្វះខាតនូវសម្ភារប៉ុណាក្ដី។

យើងសង្ឃឹមថាប្អូនៗបណ្ដាស.ម និងមិត្តពិតជាមានលិទ្ធភាពស្វែងយលល់បានច្រើនជាងខ្ញុំ ដែលជាអ្នកទីមួយដំបូងបំផុតក្នុងការសិក្សាមុខវិជ្ជា គឺមានការពិបាកសព្វបែបយ៉ាងតាំងពីឯកសារសិក្សា សម្ភារបង្រៀន វត្ថុធាតុដើមសម្ភាររៀបចំបច្ចេកទេសជាដើមមួយទៀតខ្មែរពុំទាន់ស្គាល់តម្លៃខ្មែរ ពុំបានឲ្យតម្លៃសិល្បខ្នុកនេះឡើយម្ល៉ោះហើយទើបសិល្បតែងតែទទួលការពិបាកគ្រប់បែបយ៉ាងទាំងអស់។

ប៉ុន្តែការពិបាកវាគ្រាន់តែជាលក្ខណៈបណ្ដោះអាសន្នតែប៉ុណ្ណោះទន្ទឹង និងនេះក៏មានលក្ខណងាយស្រួលចំពោះជាតិ និងអន្តជាតិផងដែរ។ ខ្នុកបានបង្ហាញស្នាដៃរស់រវើកទៅគ្រប់មជ្ឈដ្ឋានអន្តជាតិ ហើយមួយថ្ងៃម្ដងៗខ្នុកចេះតែដំណើរការទៅកាន់ភាពសុក្រឹតជាលំដាប់។ គេសង្កេតឃើញមានការប្លែកគ្នាខ្វះពីទម្រង់ដើម ហើយច្នៃបង្កើតកាន់តែសុក្រឹត

ទាំងបូរាណទាំងសម័យនេះមកពីណា គឺមកពីមនសិការដ៏ប្រសប់ និងការជួយជ្រុំជ្រែងពីសំណាក់លោកសាស្ត្រចារ្យ គ្រូបង្រៀនជាពិសេសលោកបន្ទុកដែលបានយកចិត្តទុកដាក់ជួយបង្រៀនយើងខ្ញុំគ្រប់វិនាទីទាំងអស់ក្នុងផ្នែកខ្នុកនេះ។

តែទោះជាយ៉ាងនេះក៏ដោយដ៏យើងសន្មត់ថាពុំអាចចេះសព្វគ្រប់ទាំងអស់នោះទេ រយៈពេល និងផ្លូវធ្វើដំណើរនៅវែងឆ្ងាយណាស់ការដឹងបន្តិចបន្តួចនេះវាគ្រាន់តែជាមូលដ្ឋានសិល្បខ្នុកតែប៉ុណ្ណោះ យកល្អសិល្បប៊ិនប្រសប់គឺការអនុវត្តន៍បច្ចេកទេសរៀងរាល់ថ្ងៃរួមជាមួយទ្រឹស្តីផងនេះ ព្រមទាំងមានគំនិតស្រាវជ្រាវវត្ថុធាតុដើមដោយផ្ទាល់ខ្លួនដោយពុំចាំបាច់ពឹងបរទេសគឺជាការប្រសើរបំផុតចំពោះយើងជាខ្មែររស់លើទឹកដីដែលសំបូរដោយវត្ថុធាតុដើម។ តើមិត្តត្រូវធ្វើយ៉ាងណាឲ្យសមដូចបំណង ឃ្លាមួយពោលថា "បាត់បង់ទ្រព្យ គឺជាការបាត់បង់ដ៏ធំមួយប៉ុន្តែបើមិត្តបាត់បង់សេចក្តីក្លាហាន គឺមិត្តបាត់អ្វីៗទាំងអស់" បើយ៉ាងនេះសូមកុំបាត់វារលាយសោះកិច្ចការពិបាក ដែលមានវាគ្រាន់ជាចលនានៅស្ងៀមបណ្តោះអាសន្នតែប៉ុណ្ណោះឯកម្លាំងនៃចលនានៅតែដើរទៅមុខមិនយូរមិនឆាប់ សិល្បខ្នុកនិងមានសំរស់ល្អស្រស់ជាមិនខាន បើសិនជាមិត្តយល់ថាវាមានតម្លៃប៉ុណាសម្រាប់ជាតិកម្ពុជានេះ។

ជាទីបញ្ចប់នៃអត្ថបទយើងពុំបានផ្តែផ្តាំអ្វីដល់មិត្តទេគ្រាន់តែសូមកុំឲ្យមិត្តបោះបង់ចោលសិល្បខ្នុកនេះឲ្យសោះ ហើយកុំនាំគ្នាស្អប់វា ស្រលាញ់វាលើកវាឡើងគ្មានរណាលើកយើងទេមានតែខ្មែរដែលជាកូនចៅអង្គរនេះហើយត្រូវរួមគ្នាលើកតំកើនសិល្បជាតិ។ ព្រោះវាមិនឥតប្រយោជន៍ទេ វាមានតម្លៃជាងគំនូរវិចិត្រកម្មជាងសិល្បស្និត និងគំនូរផ្សាយទៅទៀត បើមិត្តចូលមកធ្វើការសិក្សាពីវា ព្រោះវាជាសិល្បសាមញ្ញ សិល្បប្រជាជន។ ដូច្នេះយើងកុំបំផ្លាញវាឲ្យសោះ ហើយត្រូវតែយល់ថាខ្នុកជាវិជ្ជារបៀបណា ស្នាច់របៀបណាលាក់ការរបៀបណាប្រយោជន៍យ៉ាងណាក្នុងឯកទេសខ្នុកមួយៗរបស់វា។

ដើម្បីកុំឲ្យវែងឆ្ងាយពេកយើងសូមឲ្យមិត្តទាំងអស់យល់ពីសិល្បខ្នុក ហើយខិតខំស្រាវជ្រាវបន្ថែមបន្តរទៅទៀតផង ដើម្បីឲ្យកាន់តែច្បាស់ឡើងពីការសិក្សាខ្នុកស្នាច់ដែលជាសិល្បដ៏កំពូលរបស់ខ្មែរ។

ចុងបញ្ចប់ខ្ញុំសូមលំឱនកាយគោរពមិត្ត ប្អូន បង និងបណ្តាស.មទាំងអស់ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ជាទីគោរព សូមឲ្យលោកព្រមទាំងមិត្តបណ្តាស.ម ប្អូន បង

ប្រកបទៅដោយភាពកិច្ចជ័យជំនះបដិវត្តខ្ពស់បំផុតក្នុងជីវិតលោក និងគ្មានឧបសគ្គអ្វីទាំងអស់មកយាយីឡើយ។

សូមអគុណ

បណ្តាំចុងក្រោយដែលជាជីវិតរបស់សិល្បករចាត់ទុកថាជា "ព្រលឹងខ្ញុំ"

វិរជនពោរពេញទៅដោយទេពកោសលខ្ពស់គ្រប់ជំនាន់គ្រប់សម័យកាលសុទ្ធតែជាបណ្តាមនុស្សដែលយល់ដឹងពីជម្រៅជីវភាពប្រជាជន អ្នកទាំងអស់នោះតែងចុះជាប់នឹងមហាជន ហើយសរសេរដោយឥតលាក់លាមពីប្រជាជននូវបណ្តាគុណសម្បត្តិល្អៗ សេចក្តីសប្បាយ ទុក្ខវេទនាការលំបាកនៃប្រជាជន។ ក្នុងការតស៊ូដើម្បីរំដោះខ្លួន ប្រជាជនបានបង្ហាញយ៉ាងច្បាស់នូវតួនាទីរបស់ខ្លួនទុកក្នុងប្រវត្តិសាស្ត្រ។

ដូចគ្នានេះដែរទុក្ខវេទនារបស់ប្រជាជន ជាទុក្ខវេទនារបស់សិល្បករដែលជាកូនចៅប្រជាជន ដូច្នេះសិល្បករត្រូវធ្វើយ៉ាងណាឲ្យប្រជាជនចូលចិត្ត អាណិតស្រលាញ់ដោយមានគោលគំនិត ឆន្ទៈ សញ្ចេតនាស្របជាមួយគោលគំនិត ឆន្ទៈ សញ្ចេតនារបស់ប្រជាជនជាពិសេសសិល្បករត្រូវសម្តែងយ៉ាងណា ដើម្បីរកវិធីលូតលាស់រីកចម្រើនពីមហាជនដូចឃ្លាមួយពោលថា "កិច្ចការពិបាកធ្ងន់ធ្ងរ តែបើមានមហាជនចូលរួមវាជាកិច្ចការមួយធូរស្រាលបំផុត"។ ព្រលឹងខ្ញុំគឺមហាជន គ្មានមហាជនគឺគ្មានគំនិតច្នៃប្រឌិត គ្មានកម្មវត្ថុសិក្សាឡើយ។

## លោកគ្រូ ដេត សុវត្ថា

កើតនៅឆ្នាំ ១៩៥៣

បានបញ្ចប់ការសិក្សានៅសាលាវិចិត្រសិល្បៈនៅឆ្នាំ ១៩៧៣ ជំនាញខ្នុកស្នាច់។

បានចូលបំរើការងារជាមន្ត្រីរាជការចាប់ពីឆ្នាំ ១៩៧៩ រហូតមកដល់បច្ចុប្បន្ន។

ស្នាដៃរបស់លោកត្រូវបានក្រុមសិល្បៈល្ខោនខោលនៃនាយកដ្ឋានសិល្បៈទស្សនីយភាព និងក្រុមសិល្បៈដទៃទៀតពាក់សម្តែង។

មុខខ្នុករបស់លោកត្រូវបានគេដាក់តាំងពិពរណ៌នៅក្នុងស្រុក និងក្រៅស្រុកផងដែរ។



លោកគ្រូ ជេត សុវត្ថា



មុខក្រុងភពណ៍



មុខក្រុងរាពណ៍មើលពីចំហៀង



មុខស្តេចកុជង្គនាគ (វីរុលធាត)



មុខស្ដេចកុជង្គនាគ (វិរុលធាត) មើលពីចំហៀង



មុខព្រះមុនីឥសី



មុខព្រះមុនីឥសី



មុខព្រះលក្ខ្មណ៍



មុខព្រះលក្ស្មណ៍មើលពីចំហៀង



មុខព្រះលក្ស្មណ៍



មុខព្រះលក្ម្ស៍មើលពីចំហៀង



មុខព្រះមុនីឥសី



មុខព្រះមុនីឥសី



មុខហនុមាន



មុខហនុមានមើលពីចំហៀង



មុខរាមសូរ



មុខរាមសូរមើលពីចំហៀង



មុខព្រះភិរុទ្ធ មើលពីមុខ



មុខព្រះភិរុទ្ធ មើលពីចំហៀង



មុខព្រះរាម



មុខព្រះរាមមើលពីចំហៀង



មុខតោះ



មុខងោះ



មុខស្វាពល



មុខស្វាពលមើលពីចំហៀង



មុខកុម្ភកាណ៌ ឫពលយក្ស



មុខកុម្ភកាណ៍ ឫពលយក្សមើលពីចំហៀង



មុខរូបយក្ខិនី (តួអង្គយក្សស្រី)



មុខរូបយក្ខិនី (តួអង្គយក្សស្រី)



មុខពលយក្ស



មុខពលយក្សមើលពីចំហៀង



មុខហនុមាន



មុខហនុមានមើលពីចំហៀង



មុខរូបយក្ខិនី



មុខរូបយក្ខិនីមើលពីចំហៀង



មុខពលយក្ស



មុខពលយក្សមើលពីចំហៀង



មុខគុជគីរីវនី (យក្សប្រម៉ោយដំរី)



មុខគុជគីរីវនី (យក្សប្រម៉ោយដំរី)មើលពីចំហៀង



មុខរាមលក្ស្មណ៍ ឬជប់ល័ក្ខណ៍



មុខរាមលក្ស្មណ៍ ឬជប់ល័ក្សណ៍ មើលពីចំហៀង



មុខព្រះមុនីឥសីមើលពីចំហៀង



មុខព្រះមុនីឥសីពីមុខ



មុខព្រះមុនីឥសីមើលពីចំហៀង



មុខព្រះមុនីឥសីមើលពីមុខ



មុខព្រះរាជា ឫទេវតាមើលពីចំហៀង



មុខព្រះរាជា ឬទេវតា



មុខហនុមានមើលពីចំហៀង



មុខហនុមាន



មកុដក្បាលមាន់ថៃ



មុដក្បាលមាន់ថៃ



មួកក្បាលសត្វ



មួកក្បាលសត្វ



មកុដក្បាលនាគមើលពីចំហៀង



មកុដក្បាលនាគ



មកុដតួនាគ



មកុដតួនាគ



មុខត្លុកកំប្លែង



មុខត្លុកកំប្លែង



មុខខ្មុកតាំងនៅក្នុងរោងជាង




លោកគ្រូ ដេត សុវត្ថា ជាមួយនិងកូនសិស្សដេរប៉ាក់ក្នុងរោងជាង

## លោក ហួ ពិសុទ្ធ

កើតនៅឆ្នាំ ១៩៧០ នៅភូមិរកាកោង ឃុំរកាកោង ស្រុកមុខកំពូលខេត្តកណ្តាល។

លោកចូលរៀនសាលាវិចិត្រសិល្បៈនៅឆ្នាំ ១៩៨៥ បញ្ចប់ការសិក្សានៅឆ្នាំ ១៩៩០ បានរៀនមុខវិជ្ជាទូទៅគ្រប់ជំនាញបន្ថែនៅឆ្នាំ ១៩៨៧ បានជ្រើសរើសយកឯកទេសខ្នុកស្នាច់។

គ្រូបង្ហាតផ្ទាល់គឺលោកគ្រូ អន សុខ បន្ទាប់មកបានសិក្សាបន្ត និងស្រាវជ្រាវបន្ថែមជាមួយលោកគ្រូ អន ស៊ីថា។ នៅឆ្នាំ ១៩៩១ រហូតមកដល់បច្ចុប្បន្នជាគ្រូបង្រៀនមុខវិជ្ជាខ្នុកស្នាច់នៅសាលាមធ្យមវិចិត្រសិល្បៈ។ លោកបានបណ្តុះបណ្តាលសិស្សជាច្រើនជំនាន់លើមុខជំនាញខ្នុកស្នាច់នេះ។



លោកគ្រូ ហួ ពិសុទ្ធ កំពុងបង្រៀនសិស្ស



មុខរាមសូរមើលពីមុខ



មុខរាមសូរមើលពីចំហៀង



មុខពិភេក មើលពីមុខ



មុខពិភេក មើលពីចំហៀង



មុខរាមសូរមើលពីមុខ



មុខរាមសូរមើលពីចំហៀង



មុខគ្រុឌ (សម្ពលីគ្រុឌ) មើលពីមុខ



មុខគ្រុឌ (សម្ពលីគ្រុឌ) មើលពីចំហៀង



មុខស្វាពល មើលពីមុខ



មុខស្វាពល មើលពីចំហៀង



មុខស្វាអង្គត មើលពីមុខ



មុខស្វាអង្គត មើលពីចំហៀង



មុខស្វាពល មើលពីមុខ



មុខស្វាពល មើលពីចំហៀង



មុខព្រះមុនីឥសី



មុខព្រះមុនីឥសី មើលពីចំហៀង



មុខយក្សពល



មុខយក្សពល មើលពីចំហៀង



មុដស្តេចនាគ វីរុលធាតមើលចំហៀង



កុដស្ដេចនាគ វីរុលធាតមើលពីមុខ



សកម្មភាពរៀនមុខវិជ្ជាធ្វើពុម្ពសម្រាប់ស្មាច់រូបខ្នុក



សកម្មភាពរៀនមុខវិជ្ជាធ្វើពុម្ពសម្រាប់ស្មាច់រូបខ្ចុក



សកម្មភាពសិស្សរៀនវិជ្ជាឆ្លាក់ស្បែកនៅសាលាមធ្យមវិចិត្រសិល្បៈ



កិច្ចការបង្រៀនរបស់លោកគ្រូ ហួ ពិសុទ្ធ



លោកឈឹម សុធី ជួបជាមួយលោក ហួ ពិសុទ្ធ

# លោកគ្រូ **អន ស៊ីថា**

កើតនៅឆ្នាំ ១៩៦៤ នៅសង្កាត់លេខ ៤ ក្រុងភ្នំពេញ។

បានចូលរៀនសាលាវិចិត្រសិល្បៈនៅឆ្នាំ ១៩៨៣ លើមុខជំនាញខ្នុកស្មាច់ បន្ទាប់មកបានបន្តការសិក្សាផ្នែកខ្នុកម្រក័រនៅប្រទេសវៀតណាម បានបញ្ចប់ការសិក្សានៅឆ្នាំ ១៩៩៣។ បច្ចុប្បន្នជាសាស្ត្រាចារ្យបង្រៀនមុខវិជ្ជាខ្នុកស្មាច់នៅសាលាមធ្យមវិចិត្រសិល្បៈ។

លោកគ្រូ **អន ស៊ីថា** ជាបុត្រច្បងរបស់លោកគ្រូ **អន សុខ** ហើយជាអ្នកបន្តមរតកជំនាញខ្នុកស្មាច់បន្តជាប់រហូតមក។





មកុដតួនាង



មកុដនាយ (សម្រាប់តួអង្គប្រុស)



មកុដនាយ (សម្រាប់តួអង្គប្រុស) មើលពីចំហៀង



មកុដតួនាង



មុដតួនាង មើលពីចំហៀង



មកុដព្រះព្រហ្ម និងព្រះនារាយណ៍នៅពីលើ



មុដព្រះព្រហ្ម និងព្រះនរាយណ៍នៅពីលើ មើលពីចំហៀង



មុខហនុមាន មើលពីមុខ



មុខហនុមានមើលពីចំហៀង



មុខក្រុងរាពណ៍ មើលពីមុខ



មុខក្រុងរាពណ៍មើលពីចំហៀង



រូបគុជគីរីធរ មើលពីមុខ



*រូបគុជគីរីធរ មើលពីចំហៀង*



មុខពិភេក មើលពីមុខ



មុខពិភេក មើលពីចំហៀង



មុខព្រះមុនីឥសី មើលពីមុខ



មុខព្រះមុនីឥសី មើលពីចំហៀង



មុខរាមសូរ មើលពីមុខ



មុខរាមសូរ មើលពីចំហៀង



មុខយក្សស្រី (យក្ខិណី)



មុខយក្ខិណី ពាក់ក្បាំង



តោក



*ពេជដាជ៍ឌ្ឋកស្មាច់របស់លោកគ្រូ* ***អន ស៊ីថា***

## លោកគ្រូ **អន សុខ**

កើតនៅឆ្នាំ ១៩៤១ នៅភូមិបាណា ឃុំសឹង្ហ ស្រុកសំរោង ខេត្តតាកែវ។

ចូលរៀនសាលារចនានៅទសវត្សទី៥០ មុខជំនាញសិល្បៈខ្នុកស្នាច់។ ក្រុមគ្រួសារលោកគ្រូជាអ្នកប្រកបមុខរបរខ្នុកស្នាច់តាំងពីយូរយាណាស់មកហើយ។

ហើយមានឈ្មោះល្បីល្បាញក្នុងស្រុកជាពិសេសស្នាដៃរបស់លោកគ្រូត្រូវបានទទួលស្គាល់ពីសំណាក់ក្រុមគ្រួសារព្រះរាជវង្ស។

កិច្ចការរបស់លោកគ្រូត្រូវបានដាក់តាំងនៅក្នុងព្រះបរមរាជវាំង និងនៅតាមបណ្តាលផ្ទះអតិថិជនមួយចំនួន។



រូបភាពលោកគ្រូ **អន សុខ** កំពុងធ្វើកិច្ចការខ្នុកស្នាច់

## *លោកគ្រូ **អន តុលា***

*កើតនៅឆ្នាំ ១៩៧១ ចូលរៀននៅសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈនៅឆ្នាំ ១៩៩២ និងបញ្ចប់ការសិក្សារលើមុខជំនាញសិល្បៈសូនរូបផ្នែកខ្នុកស្នាច់នៅឆ្នាំ ២០០២។ បច្ចុប្បន្ននេះលោកគ្រូ **អន តុលា** បង្រៀននៅសាលាមធ្យមវិចិត្រសិល្បៈ។ លោកជាបុត្រពៅរបស់លោកគ្រូ **អន សុខ** ហើយចាប់យកអាជីពបន្តមរតកខ្នុកស្នាច់ពីឪពុករហូតមក។*

*កិច្ចការរបស់លោកគ្រូមានដូចជា៖ ធ្វើមុខយក្ស ស្វា សម្រាប់សម្តែងល្ខោនខោល។ ធ្វើគ្រឿងបរិក្ខាសម្រាប់ព្រះសង្ឃមានដូចជា ចាមរ តោក ភាជន៍ កាប៉េស ផ្ចិត ប៉ាក់ឱនសំលៀកបំពាក់ និងគ្រឿងប្រដាប់សម្រាប់សិល្បករ។ល។*




*រូបភាពលោកគ្រូ **អន តុលា** កំពុងធ្វើកិច្ចការខ្នុកស្នាច់*



មកុដតួនាង



មកុដនាយរោង



មុខយក្ខិណី (នាងសុបនខា)



មុខយក្ខិណី មើលពីមុខ



មុដនាយពេង សម័យអង្គរ



មកុដនាយរោង សម័យអង្គរ (មើលពីក្រោយ)



មុខយក្សពល មើលពីមុខ



មុខយក្សពល មើលពីក្រោយ



មុខហនុមាន មើលពីមុខ



មុខហនុមាន មើលពីចំហៀង



មុខហនុមានសម័យអង្គរ



មកុដរត្ន័ក្ខារ



មុខស្វាពល



មុខយក្សពល

# លោកគ្រូ **ផា ហ៊ា**

មានអាយុ ៨៨ ឆ្នាំ កើតនៅភូមិចំការសំរោង០១ ឃុំ ចំការសំរោង០១ ខេត្ត បាត់ដំបង។ កាលពីអាយុ ១២ ឆ្នាំ លោកបានរៀនជាមួយលោកគ្រូ ពេជ្រ នៅឯចំការដំរី (ព្រៃកោង) ខេត្ត បាត់ដំបង រៀនខ្លុកបាន ០៥ ឆ្នាំ លោកបានបួសជាព្រះសង្ឃបន្ទាប់ពីលាចាកសិក្ខាបទ បានចាប់បន្តកិច្ចការខ្លុកម្រក្សនេះទៀត។

លោកគ្រូបានបម្រើការឲ្យក្រុមល្ខោនខោលមួយរង់នៅខេត្តបាត់ដំបង។

<u>សម្ភារៈបច្ចេកទេស:</u>

ដើមដង្កោយកជ័រ ដីឥដ្ឋ ក្រដាសស៊ីម៉ង់ ជ័រទឹក ជ័រចុង ថ្នាំកំប៉ុង។ល។



លោកគ្រូ **ជា ហ៊ា** ធ្វើកិច្ចការនៅក្នុងរោងជាង



មុខស្វាពល មើលពីមុខ



មុខស្វាពល មើលពីចំហៀង



មុខយក្ស



មុខយក្ស មើលពីចំហៀង



មុខតួអង្គព្រះរាម ឬនាយរោង មើលពីមុខ



មុខតួអង្គព្រះរាម ឬនាយរោងមើលពីចំហៀង



មុខតួអង្គព្រះរាម ឬនាយរោង មើលពីក្រោយ



មុខយក្សពល



ខ្នុកមុខសត្វទន្សាយ មើលពីមុខ



ខ្នុកមុខសត្វទន្សាយ មើលពីចំហៀង



មុខក្រុងភពណ៍ មើលពីមុខ



មុខក្រុងភពណ៍មើលពីចំហៀង



មុខស្វាស (ហនុមាន) មើលពីមុខ



មុខស្វាស (ហនុមាន) មើលពីចំហៀង



មុខយក្សពល មើលពីមុខ


មុខយក្សពលមើលពីចំហៀង



មុខសុគ្រីព មើលពីមុខ



មុខសុគ្រីព មើលពីចំហៀង



មុខពលយក្ស មើលពីមុខ



មុខពលយក្ស មើលពីចំហៀង



មុខខ្នុកក្បាលដំរី មើលពីមុខ



មុខខ្នុកក្បាលដំរី មើលពីចំហៀង



មុខយក្សម្កុដក្បាលនាគ មើលពីមុខ



មុខយក្សមកុដក្បាលនាគ មើលពីចំហៀង



មុខព្រះលក្ស្មណ៍ មើលពីមុខ



មុខព្រះលក្ស្មណ៍ មើលពីចំហៀង



មុខយក្សឥន្ទជិត មើលពីមុខ



មុខយក្សឥន្ទជិត មើលពីចំហៀង



*មុខបក្សីក្អែក ឬកាកណាសូរមើលពីចំហៀង*



មុខស្មាច់ពុំទាន់លម្អ (ក្រុងរាពណ៍)



មុខព្រះមុន្នីឥសី មើលពីចំហៀង



មុខព្រះមុន្នីឥសី មើលពីមុខ



មកុដតួនាង





ធ្នើដាក់តាំងមុខខ្នុករបស់លោកគ្រូ **ជា ហ៊ា** (ខេត្តបាត់ដំបង)



ធ្នើដាក់តាំងមុខខ្លុករបស់លោកគ្រូ **ជា ហ៊ា** (ខេត្តបាត់ដំបង)



លោក **សាយ សារ៉េត**

កើតនៅឆ្នាំ ១៩៦៣ នៅស្រុក កណ្ដាលស្ទឹង ខេត្ត កណ្ដាល។ ចូលរៀននៅសាលាវិចិត្រសិល្បៈនៅឆ្នាំ ១៩៨០ បានសិក្សាមុខវិជ្ជាឆ្លាក់រយៈពេល ០៥ឆ្នាំ និងរៀនមុខវិជ្ជាគំនូរវិចិត្រកម្មរយៈពេល ០២ឆ្នាំ។បច្ចុប្បន្នជាគ្រូបង្រៀនចំណេះទូទៅនៅសាលាមធ្យមវិចិត្រសិល្បៈផ្នែកទស្សនៈវិជ្ជា។

ការងារបច្ចេកទេស:

បានសិក្សាមុខវិជ្ជាឆ្លាក់ពីលោកគ្រូ អន សុខ រៀន ស្នាច់ គូរក្បាច់ បន្ទំ   ម្រក្សំ បិតមាស សន្ទឹកតាមរបៀបបូរាណ។



*លោកគ្រូ **សយ សាវ៉េត** បង្ហាញពីការធ្វើរ ខ្លុកស្ពាប់*



មុខយក្ស មើលពីមុខ



មុខយក្ស មើលពីចំហៀង



មុខយក្ស មើលពីក្រោយ



មុខសុគ្រីព មើលពីមុខ



មុខសុគ្រីព មើលពីចំហៀង



មុខមេទ័ពស្វា មើលពីមុខ



មុខមេទ័ពស្វា មើលពីចំហៀង



មុខយក្ខិណី មើលពីមុខ



មុខយក្ខិណីមើលពីចំហៀង



មុខហនុមាន (ពុម្ពក្រដាសស្អាប់)



មុខហនុមាន មើលពីចំហៀង (ពុម្ពក្រដាសស្អាប់)



លោកគ្រូ **សាយ សារ៉េត** កំពុងធ្វើកិច្ចការខ្នុក



រោងជាងធ្វើខ្នុករបស់លោកគ្រូ សាយ សារ៉េត




លោកឈឹម សុធី ជួបជាមួយលោកគ្រូ សាយ សារ៉េត

## លោក ថុន ភារម្យ

កើតនៅឆ្នាំ ១៩៩៧ នៅស្រុក ល្វាឯម ខេត្ត កណ្តាល។

បានចូលរៀនសាលា មធ្យមវិចិត្រសិល្បៈនៅឆ្នាំ ២០១២ បញ្ចប់នៅឆ្នាំ ២០១៧

បានសិក្សាមុខជំនាញខ្នុកស្នាច់ជាមួយលោកគ្រូ អន តុលា លោកគ្រូ ហួ ពិសុទ្ធ និងលោកគ្រូ អន ស៊ីថា។

ស្នាដៃសិល្បៈខ្នុកស្នាច់របស់លោកត្រូវ បានចូលរួមដាក់តាំងពិពរ័ណ៌នៅក្នុងប្រទេស និងអន្តរជាតិ។

ក្នុងឆ្នាំ ២០១៨ នេះនាឱកាសប្រារព្ធមហោស្រពសិល្បៈជាតិខ្នុកស្នាច់ ស្តីពីមុខហនុមាន លោកបានទទួលចំណាត់ថ្នាក់ជ័យលាភីលេខ០១។ បច្ចុប្បន្ននេះលោក ថុន ភារម្យ និងក្រុមគ្រួសារប្រកបមុខរបរធ្វើមុខ ស្វាយក្ស ធ្វើតោក កាប៉េស និងកិច្ចការសិល្បៈផ្សេងៗទៀតសម្រាប់ព្រះរាជពិធី បុណ្យសាសនានានាផងដែរ។



យុវសិល្បករ **ថុន ភារម្យ** ជាមួយនិងស្នាដៃខ្នុក



មុខនិលផាត់ មើលពីមុខ



មុខនិលផាត់ មើលពីចំហៀង



មុខពិភេក មើលពីមុខ



មុខពិភេក មើលពីចំហៀង



មុខហនុមាន មើលពីចំហៀង



មុខហនុមានមើលពីមុខ



មុខកុម្ភកាណ៌ ឬយក្សពល



មុខនិលផាត់



មុខហនុមាន មើលពីចំហៀង



មុខប្រើស



មុខព្រះមុន្នីឥសី (ពុម្ពក្រដាសស្នាប់)



មុខព្រះមុន្នីឥសី (ពុម្ពក្រដាសស្នាប់)



ក្រដាសស្នាច់មុខយក្ស មើលពីចំហៀង



ក្រដាសស្នាច់មុខយក្ស មើលពីមុខ



កុដរត្ន័ក្ងារ (សម្រាប់តួស្រី)



តោកដាំក្បាច់បិតមាសសន្ទឹក



តោកជ្រុងដាំក្បាច់បិតមាសសន្ទឹក

# លោកគ្រូ **ប៉ូច ផៃ**

លោកគ្រូ ប៉ូច ផៃ

កើតនៅឆ្នាំ ១៩៥៤នៅស្រុកល្វាឯម ខេត្តកណ្តាល ជាអតីតនាយកសាលាស្វាយអណ្តែត និងជាប្រធានគណៈកម្មការគ្រប់គ្រងក្រុមសិល្បៈល្ខោនខោលវត្តស្វាយអណ្តែត។

លោកគ្រូប៉ូច ផៃ ពុំមានចំណេះជំនាញខាងសិល្បៈខ្នុកស្នាច់ទេ តែលោកជាអ្នកថែរក្សាមុខខ្នុក និងបណ្តុះបណ្តាលក្មេងៗជំនាន់ក្រោយ ដោយរួមសហការជាមួយលោកគ្រូអ្នកគ្រូជំនាញជាច្រើនរូបទៀតនៅសហគមន៍ស្វាយអណ្តែត ស្រុកល្វាឯម ខេត្តកណ្តាល។ មុខខ្នុកទាំងឡាយដែលសំរាប់សម្តែងល្ខោនខោលផ្តល់ដោយនាយកដ្ឋានទស្សនីយភាពនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ព្រះបរមរាជវាំង និងអង្គការយូណេស្កូ។





មុខអង្គត មើលពីមុខ



មុខអង្គត មើលពីចំហៀង



មុខហនុមាន មើលពីចំហៀង



មុខសុគ្រីព មើលពីចំហៀង



មុខហនុមានមើលពីមុខ



មុខហនុមាន មើលពីចំហៀង



មុខស្វា និលផាត់



មុខព្រះមុន្នីឥសី



កុដតួនាង មើលពីចំហៀង



កុដតួនាង មើលពីក្រោយ



មុខក្រុងរាពណ៍ ទសមុខ



មុខក្រុងរាពណ៍ ទសមុខ មើលពីចំហៀង



មុខរាមសូរ មើលពីមុខ



មុខពនស្វរ មើលពីចំហៀង



មុខឥន្ទជិត មើលពីមុខ



មុខឥន្ទជិត មើលពីចំហៀង



មុខយក្ខិណី (សុបនខា ឬអសមុះ)



មុខពិភេក



ការហាត់សម្តែងល្ខោនខោល



សកម្មភាពហ្វឹកកាត់ល្ខោនខោលរបស់សិស្សសាលាវត្តស្វាយអណ្តែត



ការហាត់សម្តែងក្រុមល្ខោន



ការហាត់សម្តែងក្រុមស្វាពល

# ការដេរខ្នុកស្នាច់របស់នាយកដ្ឋានសូនរូប





ក្រុងរាពណ៍ មើលពីមុខ



ក្រុងរាពណ៍



មុខរាមសូរ មើលចំពីមុខ



មុខរាមសូរ មើលពីចំហៀង (ម្កុដកន្ទុយហង្ស)



មុខសុគ្រីព



មុខសុគ្រីព មើលពីចំហៀង



មុខពិភេកហោរា



មុខពិភេក មើលពីចំហៀង



ម្កុដក្បាលនាគ សម្រាប់ស្ដេចនាឋានកុជង្គនាគ (វីរុលធាត)



កុដក្បាលនាគ សម្រាប់ស្ដេចនាឋានភុជង្គនាគ (វីរុលធាត)



មុខហនុមាន មើលពីមុខ



មុខហនុមាន មើលពីចំហៀង



ក្បាលនាគនៅលើម្កុដ សម្រាប់ស្ដេចនាឋានកុជង្គនាគ (វីរុលធាត)

## លោកស្រី សួន ស៊ីវត្ថា

កើតនៅឆ្នាំ ១៩៦៥ នៅភូមិក្បាលជ្រោយ សង្កាត់ ព្រែកឯង ក្រុងភ្នំពេញ។

បានចូលរៀនមុខវិជ្ជា លម្អក្រណាត់ និងខ្នុកស្នាច់នៅឆ្នាំ ១៩៨០។ ចាប់ពីឆ្នាំ ១៩៨៧ រហូតមកដល់បច្ចុប្បន្នលោកស្រីបានចាប់យកមុខជំនាញខ្នុកស្នាច់នេះរហូតមកដល់បច្ចុប្បន្ន។

កិច្ចការធ្វើមុខយក្ស មុខស្វា របស់លោកស្រីភាគច្រើនជាមុខសំប៉ែតមួយចំហៀង ពុំមានប្រើក្បាច់បន្ទុំម្រក័ រឬដាំត្បូងឡើយ ជាមុខខ្នុកសាមញ្ញសម្រាប់មហាជន។



លោកស្រី សួន ស៊ីវត្ថា និងលោក ឈឹម សុធី



សកម្មភាពការងាររបស់លោកស្រី សួន ស៊ីវត្តា



មុខយក្ខិណី



មុខយក្ខិណី



មុខយក្ខិណី



មុខស្វាពល មើលពីមុខ



មុខស្វាពល មើលពីចំហៀង



មុខហនុមាន មើលពីមុខ



មុខហនុមាន មើលពីចំហៀង



មុខស្វាពល មើលពីមុខ



មុខស្វាពល មើលពីចំហៀង



មុខស្វាខ្មៅ និលឯក មើលពីមុខ



មុខស្វាខ្មៅ និលឯក មើលពីមុខ



មុខស្វាពល



មុខស្វាពល មើលពីចំហៀង



មុខស្វា



ក្រដាសស្នាប់មុខស្វា បកពីពុម្ព



កិច្ចការខ្នុកស្មាច់ (ការស្មាច់រូបលើពុម្ព)



សំភារៈសម្រាប់ធ្វើខ្នុកស្មាច់



ផលិតផលសម្រាប់ ការផ្សារខ្មុកស្នាប់របស់លោកស្រី សួន ស៊ីវត្ថា



លោកស្រី សួន ស៊ីវត្ថា និងលោក ឈឹម សុធី

## លោក ថៃ សាន

កើតនៅឆ្នាំ ១៩៨១ នៅខេត្ត បន្ទាយមានជ័យ ចូលសិក្សានៅសាលាវិចិត្រសិល្បៈ ឆ្នាំ ២០០៣ ផ្នែកគំនូរវិចិត្រកម្ម បានបញ្ចប់ការសិក្សាផ្នែកសិល្បៈនៅឆ្នាំ ២០០៧។

លោកបានរៀនមុខវិជ្ជាខ្នុកស្នាច់ពីមិត្តភ័ក្តិដែលជាសិល្បករខ្នុកស្នាច់។

លោក ថៃ សាន មានទេពកោសល្យពិសេសខាងគំនូរសៀវភៅរឿងសម្រាប់អប់រំកុមារ។ ចំពោះកិច្ចការខ្នុកស្នាច់លោកចូលចិត្តការរចនាជាគ្រឿងអលង្ការ មុដតួរាង នាយពេង មុខយក្ស មុខស្វា។ល។





លោក **ថៃ សាន** និងកិច្ចការសិល្បៈខ្មុក



មកុដតួអង្គប្រុស (នាយរោង)



មុខព្រះរាម (នាយរោង)



មុខព្រះរាម (មើលពីមុខ)



មុខងោះ



មុខតាឥសី



ម្កុដរត្នក្វារ



ស្លឹកពោធិ៍



សុវណ៌ក



សុវណ៌ក



ក្បាំងសម្រាប់ព្រះរាជា



មុដក្បាលនាគ



ក្បាច់កន្ទុយហង្ស



ក្បាច់លម្អសុរង្គ ក



ក្បាច់លម្អដង្ខ្លួន



ខ្យងស័ង្ខលម្អដោយក្បាច់ស្រោបមាស



ខ្យងលម្អដោយក្បាច់ស្រោបមាស

# លោក ប៉ុល មករា

កើតនៅឆ្នាំ ១៩៨៩ នៅភូមិ គៀនឃ្លាំង ឃុំ ព្រែកលាភ ស្រុក មុខកំពូល ខេត្ត កណ្តាល។ លោកបានចូលរៀននៅសាលាមធ្យមវិចិត្រសិល្បៈ ឆ្នាំ ២០០៤ នឹងបានបញ្ចប់ការសិក្សានៅឆ្នាំ ២០០៧ ហើយបានចូលរៀនមុខវិជ្ជាខ្នុកស្មាច់ជាមួយលោកគ្រូ អន ស៊ីថា អន តុលា និងលោកគ្រូ ហួ ពិសុទ្ធ។ នឹងបច្ចុប្បន្នជាគ្រូបង្រៀនមុខវិជ្ជាគំនូរនៅវិទ្យាល័យឧត្តុង្គ។

លោក ប៉ុល មករា ប្រកបរបរវិជ្ជាជីវៈខ្នុកនេះជារបរប្រចាំគ្រួសារ។ រូបមុខខ្នុករបស់លោកធ្វើភាគច្រើនជាមុខ យក្ស ស្វា ព្រះមុនីឥសី។ លោកបានចូលរួចដាក់តាំងពិពរ័ណ៌បង្ហាញស្នាដៃនៅក្នុងប្រទេស និងអន្តរជាតិជាច្រើនរីឯបច្ចេកទេសនៃការធ្វើខ្នុកគឺមិនខុសពីសិល្បករខ្នុកដទៃទៀតឡើយ។



លោកពុល មករាជាមួយកិច្ចការរបស់គាត់



មុខព្រះមុន្នីឥសី មើលពីមុខ



មុខព្រះមុន្នីឥសី មើលពីចំហៀង



មុខរាមសូរ មើលពីមុខ



មុខយក្សពល



ទសមុខមើលពីមុខ



ទសមុខ



ពុម្ពដីឥដ្ឋមុខយក្ស




រោងជាងធ្វើខ្នុកស្នាច់របស់លោក ពុល មករា




ពោធិជាងធ្វើខ្លុកស្នាច់របស់លោក ពុល មករា



ពោធិជាងធ្វើខ្លុកស្នាច់របស់លោក ពុល មករា



ពុម្ពស៊ីម៉ងត៍សម្រាប់ស្នាច់រូប



ពុម្ពស៊ីម៉ងត៍សម្រាប់ស្នាច់រូប



លោក ម៉េង សុខឡេង សិល្បករល្ខោនខោល និងធ្វើមុខខ្នុក



មុខកុម្ភកាណ៌ ឬយក្សពល មើលពីមុខ



មុខកុម្ភកាណ៌ ឬយក្សពល មើលពីចំហៀង



ស្នាច់រូបសត្វក្លោក




ស្នាច់រូបមុខយក្ស



ស្នាច់រូបមុខគ្រុឌ មើលពីមុខ



ស្បែកទ្រង់រូបមុខគ្រុឌ មើលពីចំហៀង




ស្នាច់រូបមុខយក្ស



មុខស្វាពល

# ការប៉ាក់ឱនគ្រឿងប្រដាប់ និងសម្លៀកបំពាក់សម្រាប់សម្តែងសិល្បៈ





សកម្មភាពក្រុមការងារប៉ាក់ឱន



សកម្មភាពក្រុមការងារប៉ាក់ឌិន



សកម្មភាពក្រុមការងារប៉ាក់ឌិន



ការផាវប៉ាក់ឱនស្បៃ



ការផាវដេប៉ាក់សុខផឹក



អសនៈព្រះរាជគ្រូ



សំលៀកបំពាក់សម្ដេង



សំលៀកបំពាក់សម្តេង



ដៃអាវ



ជើងខោរ



ឥន្ទនូ



ក្បាច់ផ្កាចាន់លម្អផ្ទៃអាវ



អសនះព្រះរាជគ្រូ



រោងជាងថែរក្សាមុខខ្នុក និងការផាររប៉ាក់ជិន